# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

## វិទ្យាស្ថានជាតិអប់រំ

National Institute of Education

## និក្ខេបបទ

# ការអនុវត្តការអប់រំប្រកបដោយបរិយាបន្ន

# ទៅលើកុមារមានពិការភាពនៅកម្ពុជា

(ករណីសិក្សានៅវិទ្យាល័យអប់រំពិសេសនៅកម្ពុជា)

The Implementation on Inclusive Education

for Children with Disabilities in Cambodia

(Case Study at Special High Schools in Cambodia)


ដោយ/by

**ទុយ សុវណ្ណារិទ្ធ**

TUY SOVANNARITH


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦

ឯកទេសៈ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៧-២០១៩


ឧបត្ថម្ភដោយៈ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation (CIESF)

# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education

**និក្ខេបបទ**

# ការអនុវត្តការអប់រំប្រកបដោយបរិយាបន្នទៅលើកុមារ
# មានពិការភាពនៅកម្ពុជា

**(ករណីសិក្សានៅវិទ្យាល័យអប់រំពិសេសនៅកម្ពុជា)**

The Implementation on Inclusive Education

for Children with Disabilities in Cambodia

(Case Study at Special High Schools in Cambodia)

**ដោយ**/by

**ទុយ សុវណ្ណារិទ្ធ**

TUY SOVANNARITH

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**
**ឯកទេសៈ គ្រប់គ្រងអប់រំ**
**ឆ្នាំសិក្សា ២០១៧-២០១៩**

**សាស្ត្រាចារ្យដឹកនាំ ៖ បណ្ឌិត សិត សេង**
**សាស្ត្រាចារ្យដឹកនាំរង ៖ លឹម វ៉ាន់**

**ឧបត្ថម្ភដោយៈ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៩៦២៩ **អយក.** ព្រស

(**ភារសម្ងាត់**)

## លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ រីភ័ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុជន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យួន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទឆាយា | នាយកដ្ឋានបណ្ដុះបណ្ដាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា **“ការអនុវត្តការអប់រំប្រកបដោយបរិយាបន្នទៅលើកុមារមានពិការភាពនៅកម្ពុជា”** សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានអប់រំគឺជាស្នាដៃផ្ទាល់របស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់សញ្ញាបត្រនៅវិទ្យាស្ថាននេះ សកលវិទ្យាល័យ ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយឡើយទេ។ គ្មានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទ ស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវនេះ ពិតជាចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃអង្គារ ១៤កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩
ហត្ថលេខាបេក្ខជន

**ទុយ សុវណ្ណារិទ្ធ**

# លិខិតបញ្ជាក់

លោកបណ្ឌិត **សិត សេង** ជាសាស្ត្រាចារ្យដឹកនាំ

លោក **លឹម វ៉ាន់** ជាសាស្ត្រាចារ្យដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

**លោក ទុយ សុវណ្ណារិទ្ធ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ការអនុវត្តការអប់រំប្រកបដោយបរិយាបន្នទៅលើកុមារមានពិការភាព នៅកម្ពុជា**" ពិតប្រាកដមែន។

ថ្ងៃអង្គារ ១៤កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩

| | |
|---|---|
| ............................................ | ............................................ |
| **បណ្ឌិត សិត សេង** | **លោក លឹម វ៉ាន់** |
| នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | អនុប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ |

# លិខិតថ្លែងអំណរគុណ

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ អ្នកមានគុណទាំងពីរ និងភរិយា ដែលតែងតែគាំទ្រទាំងផ្នែកថវិកា សម្ភារៈ និងផ្នែកស្មារតីដល់ខ្ញុំបាទក្នុងពេលសិក្សាកន្លងមក។

គណៈគ្រប់គ្រង និងសាស្ត្រាចារ្យទាំងអស់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ និងក្រសួងអប់រំ យុវជន និងកីឡាបានចំណាយពេលវេលា បង្ហាត់បង្រៀនដល់ខ្ញុំបាទដោយមិនគិតពីការនឿយហត់។

លោកបណ្ឌិត **សិត សេខ** ដែលជាសាស្ត្រាចារ្យដឹកនាំ និងសាស្ត្រាចារ្យដឹកនាំរង **លឹម វ៉ាន់** ដែលលោកតែងតែឆ្លៀតពេលដ៏មានតម្លៃរបស់លោក ក្នុងការផ្តល់គំនិតណែនាំ ជាពុទ្ធិ ទ្រឹស្តី និងផ្តល់កម្លាំងចិត្ត បញ្ញា ស្មារតី បច្ចេកទេស វិធីសាស្ត្រ និងឯកសារផ្សេងៗ ដែលទាក់ទងនឹងប្រធានបទ ព្រមទាំងជួយបង្ហាញទិសដៅ ដល់រូបខ្ញុំរហូតការសិក្សាស្រាវជ្រាវនេះ ទទួលបានជោគជ័យជាស្ថាពរ ។

មិត្តរួមថ្នាក់ជំនាន់ទី៦ ទាំងអស់ដែលតែងតែផ្តល់កម្លាំងចិត្តដល់រូបខ្ញុំបាទ តាមរយៈចែករំលែកចំណេះដឹង បទពិសោធន៍ និងព័ត៌មានទាំងឡាយ ធ្វើឱ្យខ្ញុំបាទមានទឹកចិត្តតស៊ូ និងពុះពាររាល់ការលំបាក និងឧបសគ្គទាំងឡាយ ដើម្បីសម្រេចគោលដៅ ។

លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូ ដែលធ្វើការផ្នែកអប់រំពិសេសទាំងអស់ ដែលបានសម្របសម្រួល ឆ្លើយនូវកម្រងសំណួរ និងសហការក្នុងការចុះប្រមូលទិន្នន័យ ធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបាន ជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំបាទសូមបួងសួងដល់អស់វត្ថុស័ក្តិសិទ្ធក្នុងលោក ពិសេសក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រសិទ្ធពរជ័យសិរីបវរមហាប្រសើរ ជូនចំពោះលោកអ្នកមានគុណទាំងពីរ ឯកឧត្តមបណ្ឌិត លោកសាស្ត្រាចារ្យ មិត្តរួមថ្នាក់ និងក្រុមគ្រួសារ និងភរិយាខ្ញុំ សូមមានសុខភាពល្អបរិបូរណ៍ កម្លាំងកាយប្រាជ្ញា និងស្មារតីមាំមួន ភ្លឺថ្លា មានសេចក្តីសុខ សេចក្តីចម្រើន សម្រេចបានជោគជ័យគ្រប់ភារកិច្ចជានិច្ចនិរន្តរ៍ និងជួបនូវពុទ្ធពរទាំងបួនប្រការគឺ៖ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**

# មូលន័យសង្ខេប

ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់គោលនយោបាយទី១ គឺកាធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា (ក្រសួង អយក, ២០១៨)។ ក្នុងន័យនេះ ការអប់រំប្រកបដោយបរិយាបន្ន គឺជាផ្នែកមួយសំខាន់ ដែលធ្វើយ៉ាងណា ត្រូវធានាថាកុមារទាំងអស់អាចមកទទួលសេវាអប់រំ មិនថាជាកុមារទូទៅ កុមារជួបការលំបាក កុមារជនជាតិដើមភាគតិច និងកុមារដែលមានពិការភាពនោះទេ។ ដោយឃើញថា ការអប់រំប្រកបដោយបរិយាបន្ន ជាផ្នែកមួយយ៉ាងសំខាន់នៃការគាំទ្រគោលនយោបាយអប់រំនេះ អ្នកសិក្សាស្រាវជ្រាវ បានជ្រើសរើសយកប្រធានបទ **“ការអនុវត្តការអប់រំប្រកបដោយបរិយាបន្នទៅលើកុមារមានពិការភាពនៅកម្ពុជា”** មកសិក្សាស្រាវជ្រាវ។

ក្រោមកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំប្រឹងប្រែងដែលអាចឱ្យកុមារមានពិការភាពទាំងអស់អាចចូលរៀន និងបន្តការសិក្សាឱ្យបានចប់គ្រប់ភូមិសិក្សា។ ការអប់រំកុមារមានពិការភាពនៅកម្ពុជាត្រូវបានធ្វើឡើងជាបីប្រភេទគឺ ការអប់រំនៅសាលាអប់រំពិសេស ការអប់រំដែលបញ្ចូលកុមារទៅក្នុងសាលាទូទៅថ្នាក់រៀនធម្មតា និងការអប់រំថ្នាក់សមាហរណកម្ម ដែលមានថ្នាក់ពិសេសនៅក្នុងសាលាទូទៅ។ ក្នុងចំណោមការអប់រំកុមារមានពិការភាពទាំងបីប្រភេទនេះ ការអប់រំនៅសាលាពិសេស ត្រូវបានទទួលបានការគាំទ្រយ៉ាងខ្លាំងពីសំណាក់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍនានា (ក្រសួង អយក, ២០១៨)។

ការសិក្សាស្រាវជ្រាវនេះ បានធ្វើឡើងនៅតាមវិទ្យាល័យអប់រំពិសេសទាំងប្រាំ នៅក្នុងប្រទេសកម្ពុជា (វិទ្យាល័យអប់រំពិសេសភ្នំពេញថ្មី ច្បារអំពៅ កំពង់ចាម សៀមរាប និងវិទ្យាល័យអប់រំពិសេសបាត់ដំបង)។ ការសិក្សាស្រាវជ្រាវនេះ ផ្តោតទៅលើការអនុវត្តការអប់រំកុមារពិការប្រកបដោយបរិយាបន្ន ដែលផ្អែកតាមសូចនាករសំខាន់ៗចំនួនប្រាំមួយ ដើម្បីរកឱ្យឃើញពីការអនុវត្តល្អ បញ្ហាប្រឈមនានា និងយុទ្ធសាស្ត្រគាំទ្របន្ថែម ដែលអាចយកទៅអនុវត្តការផ្តល់សេវាអប់រំសម្រាប់កុមារពិការ ឱ្យកាន់តែប្រសើរឡើង។ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់ឧបករណ៍កម្រងសំណួរ ដើម្បីធ្វើការចុះប្រមូលទិន្នន័យនៅវិទ្យាល័យអប់រំពិសេស ដោយផ្តល់ជូននាយក នាយិកា នាយករង នាយិការងចំនួន ១៤នាក់ លោកគ្រូ អ្នកគ្រូ និងបុគ្គលិកសិក្សាទាំងអស់គ្រូចំនួន១០៣នាក់។ ទិន្នន័យដែលប្រមូលបាន អ្នកសិក្សាស្រាវជ្រាវបានយកមកវិភាគតាមកម្មវិធី SPSS និង Exel ដោយវិភាគតាម Frequencies And Descriptive ដោយបង្ហាញជាតារាងស្ថិតិ និងដ្យាក្រាម ។

ការសិក្សាស្រាវជ្រាវ នេះបានបង្ហាញថាការអប់រំប្រកបដោយបរិយាបន្ននៅតាមវិទ្យាល័យអប់រំពិសេសមានលក្ខណៈដូចខាងក្រោម៖

១. ការចុះឈ្មោះចូលរៀន និងការកំណត់អត្តសញ្ញាណពិការភាព ត្រូវបានអនុវត្តទាំងស្រុងដែលមានកិច្ចសហការទាំងសាលា៨១.៦% ដៃគូ និងស្ថាប័នពាក់ព័ន្ធនានា១៨.៤%។ ក្រៅពីការកំណត់អត្តសញ្ញាណ ក៏មានការផ្តល់នូវឧបករណ៍ និងសេវាគាំទ្របន្ថែម ដើម្បីស្តា និងគាំទ្រដល់កុមារមានពិការភាពទាំងនោះ៦៨% ដើម្បីឱ្យទទួលបានការសិក្សាឱ្យសមស្រប និងទាន់ពេលវេលា។ ពិសេសបន្ថែមលើសពីនេះទៅទៀត

សិស្សានុសិស្សទាំងអស់ ត្រូវបានផ្តល់នូវប្រាក់អាហារូបករណ៍ពិសេស ចំនួន២០០,០០០រៀលក្នុង១ខែ(១០ខែក្នុង១ឆ្នាំ) សម្រាប់ការធ្វើដំណើរ ហូបចុក ស្នាក់នៅ ទាំងសិស្សនៅក្រៅសាលា និងសិស្សស្នាក់នៅក្នុងសាលា។

២. ការរៀបចំហេដ្ឋរចនាសម្ព័ន្ធ និងបរិស្ថានសិក្សាគាំទ្រដល់ការរៀន និងបង្រៀនមាន៦១% បានអនុវត្តតាមគំរូសមស្រប។ ប៉ុន្តែការសិក្សាស្រាវជ្រាវក៏បង្ហាញថា មាន៣៩%ទៀត មិនទាន់បានរៀបចំនៅឡើយ ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់ដល់កុមារពិការនៅឡើយ ដូចជាបណ្ណាល័យ បន្ទប់កុំព្យូទ័រ បន្ទប់ហ្វឹកហាត់ និងស្រាវជ្រាវ បន្ទប់ទឹក ផ្លូវដើរ និងកន្លែងស្នាក់នៅឡើយ នេះដោយសារកត្តាការចំណាយ និងបច្ចេកទេសខ្ពស់។

៣. ការបណ្តុះបណ្តាលគ្រូបង្រៀន និងការកសាងធនធានមនុស្សបន្ថែមទាក់ទងនឹងជំនាញអប់រំពិសេស៖ លោកគ្រូ អ្នកគ្រូត្រូវបានទទួលការបំប៉នទាំង បច្ចេកទេសបង្រៀន និងចំណេះលើបំណិនពិការភាពជារៀងរាល់ឆ្នាំ(១០០%)។ សម្រាប់ការបំប៉នជាប្រចាំឆ្នាំនេះ គឺជាការកសាងធនមនុស្ស ក្នុងការពង្រីកការអប់រំដល់កុមារដែលមានពិការភាពឱ្យបានទូលំទូលាយ និងប្រសើឡើង។ តែទោះជាយ៉ាងនេះក្តី គ្រូបង្រៀនមុខវិជ្ជានៅមធ្យមសិក្សាមិនទាន់បំប៉នពេញលេញ និងត្រូវការគ្រូនូវជំនាញអប់រំពិសេសបន្ថែម នេះនៅតែជាក្តីកង្វល់ក្នុងការបណ្តុះបណ្តាលមិនទាន់នឹងតម្រូវការគ្រូនៅតាមវិទ្យាល័យអប់រំពិសេសទាំង៥ និងនិនាការណ៍គោលដៅអប់រំ។ ជាការដោះស្រាយនោះ គ្រូបង្រៀនមុខវិជ្ជាសាស្ត្រម្នាក់ៗ ត្រូវបង្រៀនពីថ្នាក់ទី៧ ដល់ទី១២។

៤. កម្មវិធីសិក្សាត្រូវបានអនុវត្តស្របតាមកម្មវិធីសិក្សាសាលាចំណេះទូទៅ។ ដោយក្នុងនោះ សិស្សពិការភ្នែកចាប់ពីថ្នាក់ទី៣ និងសិស្សគថ្លង់ចាប់ពីថ្នាក់ទី៥ ត្រូវទៅរៀនឆ្លងវេនបន្ថែមជាមួយសិស្សធម្មតា ដែលមានការសម្របសម្រួលពីគ្រូអប់រំពិសេស។ ការធ្វើបែបនេះបានផ្តល់ឱកាសសិស្សដែលមានពិការភាពអាចចូលរស់នៅ សិក្សា និងទំនាក់ទំនងជាមួយសង្គមជាតិទាំងមូលបាន។ ដោយឡែកការអនុវត្តកម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សានៅតែជាបញ្ហាប្រឈមសម្រាប់កុមារដែលមានពិការភាព ដូចជា ចំនួនម៉ោងសិក្សាច្រើន ចំនួនមុខវិជ្ជានិងគ្រូច្រើន និងការគាំទ្រ សម្របសម្រួលពីគ្រូអប់រំពិសេសនៅមានកម្រិតតិចតួច។ ការអនុវត្តកម្មវិធីសិក្សានៅសាលាអប់រំពិសេសបានត្រឹមតែបន្ថែមលើចំណុចខ្វះខាតដែលសិស្សមានពីសាលាធម្មតាតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀតកម្មវិធីសិក្សាមិនទាន់មានភាពបត់បែន និងឆ្លើយតមតាមតម្រូវការនៃប្រភេទពិការនៅឡើយ ទាំងវត្ថុបំណងមេរៀន ការបណ្តុះបំណិន ជំនាញ ជំនាញវិជ្ជជីវៈ និងការសម្របសម្រួលក្នុងការពិនិត្យ តាមដានសមត្ថភាពសិស្ស។ ក្នុងនោះដោយសិស្សមានពិការភាពត្រូវចូលរួមប្រឡងជាមួយការប្រឡងសិស្សទូទៅធម្មតាតាមពេលវេលាដូចនឹងសិស្សទូទៅដែរ។

ការស្រាវជ្រាវបង្ហាញជារួមថា ការអនុវត្តការអប់រំនៅវិទ្យាល័យអប់រំពិសេសទាំង៥ គឺជាគំរូល្អប្រសើរទាំងការគាំទ្រ និងការស្តានីតិសម្បទា ការគាំទ្រសុខភាព ការពិនិត្យតាមដាន និងការធ្វើអន្តរាគមន៍ទាន់ពេលវេលា និងការចូលរួមគាំទ្រពីសហគមន៍ និងដៃគូនានាយ៉ាងសកម្ម។ តាមរយៈការអប់រំពិសេសនេះ អាចយកអនុវត្តតាមសាលាទូទៅ ក្នុងការប្រែក្លាយការអប់រំប្រកបដោយបរិយាបន្នសម្រាប់កុមារមានពិការភាពនៅតាមសាលា សាធារណៈទូទៅបានក្នុងពេលអនាគតនេះ៕

## Abstract

The Ministry of Education Youth and Sport has determined the Education Policy 1 to ensure the quality education equity inclusive education and persuade the opportunity of education for lifelong learning for all. These policy show that the inclusive education are the most importance part for ensuring the children with disabilities can get the education service not only the normal children but also the children with shortage, and mineral children. With the great benefit of inclusive education can support the education policy, the researcher chooses the dissertation “The Implementation on Inclusive Education for Children with Disability in Cambodia”.

With the cooperation the MoEYS with local and international development partner has best commitment to make the possibilities for children with disabilities enrolled and continue their study through all education levels. The education for children with disabilities has divided into three categories “Special School, Integrated Class, and Inclusive School”. With these categories, the special school are the best action with the most attention from government and development partners, (MoEYS, 2018).

This research is based on the five special schools in Cambodia (Phnom Penh Thmey, Chba Ampov, Kompong Cham, Sieam Ream and Battambong). This research only focuses the implementation on inclusive education with the six inclusive education indicators based for finding the best practices, challenges and other support strategies for improving the quality of education for children with disabilities. The researcher uses the questionnaire to collect the data with 14 school principal vice principals, and 103 teacher and non-teaching staff. The data was analyzed with SPSS and Excel on frequencies and descriptive.

Research show the inclusive education of five special high school following;

1. Enrollment and disabilities identification for student are regularly done by school81.6% and support by related organization and development partners 18.4%. In addition, school also support and provide the assistive tool to student with disabilities 68% in adjusted and intervention on time. especially all student with disabilities are provided the special scholarship of amount 200,000riel in a month (10 months in a year). This scholarship is paid for transportation meal accommodation uniform and support for daily living for student who stay at school or not stay at school.

2. Infrastructure and learning environment support for learning and teaching are well arrangement 61%. however, 39% of the rest arrangement need to improve like library computer lap, science lap, hall, toilet, ramp, and accommodation. all of this problem can be the cause of highly expense and mor expert requirement.

3. Teacher training and human resource: all teacher had received the professional development every year. It shows that improvement of human resource development. however, many teachers who have are profession with their subject's teaching need to learning the special education skill (braille and sign language). The concerning the secondary teacher recruitment happened for on time support and sustainable for special education. Now all secondary teacher needs to teacher from grade 7 to grade 12.

4. Curriculum are following the main stream school which require the blind and low vision students from grade 3 up and deaf student from grade 5 up integrate other learning shift with mean stream school and students. In other side for secondary students are facing the many learning and teaching subject time consumed needs. So Moeys need to adjust and develop the curriculum and learning assessment for student with special needs on only the special school but also the main stream school.

The researcher compromise that the resource and the implementation at special high school are the best modeling with support, assistive, assessment, and intervention by school and cooperation from communities and development partners. Based on this implementation will be best modeling for main stream school on inclusive education.

# មាតិកា

សេចក្ដីប្រកាសអះអាងរបស់បេក្ខជន ........ I
សេចក្ដីបញ្ជាក់ពីសាស្ត្រាចារ្យដឹកនាំ ........ II
លិខិតថ្លៃងអំណរគុណ ........ III
មូលន័យសង្ខេប ........ IV
Abstract ........ VI
បញ្ជីតារាង ........ XII

## ជំពូកទី១

## សេចក្ដីផ្ដើម

១. ១- លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
១. ២- ចំណោទបញ្ហាស្រាវជ្រាវ ........ ២
១. ៣- គោលបំណងនៃការស្រាវជ្រាវ ........ ២
១. ៤- សំណួរស្រាវជ្រាវ ........ ២
១. ៥- វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣
១. ៥. ១- វិសាលភាពនៃការស្រាវជ្រាវ ........ ៣
១. ៥. ២- ដែនកំណត់នៃការស្រាវជ្រាវ ........ ៣
១. ៦- សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
១. ៧- រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

## ជំពូកទី២

## រំលឹកទ្រឹស្ដី

២. ១- សាវតារ ........ ៥
២. ២- និយមន័យ ........ ៦
២. ២. ១- ការអប់រំបរិយាបន្ន ........ ៦
២. ២. ២- ពិការភាព ........ ៦
២. ៣- ការអប់រំបរិយាបន្ននៅកម្ពុជា ........ ៨
២. ៤- ការអប់រំកុមារពិការ ........ ៩
២. ៤. ១- ការអប់រំបរិយាបន្ននៅក្នុងថ្នាក់រៀនទូទៅ ........ ៩
២. ៤. ២- ការអប់រំនៅក្នុងថ្នាក់សមាហរណកម្ម ........ ៩

២. ៤. ៣- ការអប់រំនៅក្នុងសាលារៀនពិសេស........................................................................ ១០
២. ៥- សូចនាករណសម្រាប់អប់រំបរិយាបន្នប្រកបដោយគុណភាព.................................................. ១១
២. ៥. ១- ការផ្តល់គាំទ្រសមស្របដល់កុមារពិការ................................................................ ១១
២. ៥. ២- ការដាក់បញ្ចូលក្នុងលក្ខណៈបរិស្ថានស្របនឹងអាយុ.................................................. ១២
២. ៥. ៣- ការមិនឱ្យមានកុមារពិការច្រើនពេកនៅក្នុងថ្នាក់រៀនទូទៅ........................................ ១២
២. ៥. ៤- ការធានាថាកុមារពិការបានចូលរួមគ្រប់សកម្មភាព.................................................... ១២
២. ៥. ៥- ការសហការរវាងគ្រូ គ្រួសារ និងសហគមន៍............................................................ ១៣
២. ៥. ៦- ការបណ្តុះបណ្តាល និងបំប៉នគ្រូបង្រៀនកុមារពិការ.................................................. ១៣
២. ៦- តួនាទីគ្រូបង្រៀនក្នុងការរៀបំសាលារៀនអប់រំបរិយាបន្ន.................................................... ១៣
២. ៦. ១- ការបង្កលក្ខណៈឱ្យសិស្សមានពិការភាពមករៀន...................................................... ១៤
២. ៦. ១. ១- តួនាទីស្វែងរកការគាំទ្រ................................................................................ ១៤
២. ៦. ១. ២- តួនាទីជាគំរូ............................................................................................... ១៦
២. ៦. ២- ការជួយកាត់បន្ថយការរើសអើងចំពោះកុមារពិការ.................................................... ១៦
២. ៦. ២. ១- តួនាទីស្វែងរកការគាំទ្រ................................................................................ ១៧
២. ៦. ២. ២- តួនាទីគំរូ.................................................................................................. ១៧
២. ៧- តួនាទីគ្រូបង្រៀនក្នុងការរៀបចំថ្នាក់រៀនបរិយាបន្ន.......................................................... ១៧
២. ៧. ១- អាកប្បកិរិយាវិជ្ជមាន......................................................................................... ១៨
២. ៧. ២- ការរៀបចំថ្នាក់រៀនឱ្យបានល្អ............................................................................... ១៩
២. ៧. ២- ការគ្រប់គ្រងឥរិយាបថកុមារ................................................................................ ១៩
២. ៨- ផែនការអប់រំសម្រាប់កុមារ.......................................................................................... ១៩
២. ៨. ២- ការប្រឹក្សាជាមួយដៃគូពាក់ព័ន្ធ............................................................................ ២០
២. ៨. ៣- ធ្វើផែនការអប់រំសម្រាប់បុគ្គល............................................................................. ២០
២. ៨. ៤- ការអនុវត្តផែនការអប់រំសម្រាប់បុគ្គល................................................................... ២០
២. ៨. ៥- ការមើលផែនការឡើងវិញ និងការរកវិធីសាស្ត្រកែប្រែថ្មី............................................. ២០

## ជំពូកទី៣

## វិធីសាស្ត្រនៃការស្រាវជ្រាវ

៣. ១- ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ............................................................................ ២១
៣. ២- ទីកន្លែងស្រាវជ្រាវ................................................................................................. ២១
៣. ៣- ការជ្រើសរើសសំណាក............................................................................................. ២១

៣. ៤- ឧបករណ៍ស្រាវជ្រាវ...................................................................................... ២២
៣. ៥- កម្រងសំណួរ និងគោលបំណងនៃកម្រងសំណួរ................................................................ ២២
៣. ៥. ១- កម្រងសំណួរសម្រាប់នាយក.................................................................................. ២២
៣. ៥. ២- កម្រងសំណួរសម្រាប់គ្រូ........................................................................................ ២២
៣. ៦- ដំណើរការប្រមូលទិន្នន័យ........................................................................................ ២៣
៣. ៧- ការវិភាគទិន្នន័យ................................................................................................. ២៤
៣. ៨- ក្រមសីលធម៌នៃការស្រាវជ្រាវ.................................................................................. ២៤

## ជំពូកទី៤

## លទ្ធផលនៃការស្រាវជ្រាវ

៤. ១- ស្ថានភាពទូទៅ.................................................................................................... ២៥
៤. ២- ការផ្តល់ការគាំទ្រសមស្របដល់កុមារពិការ...................................................................... ២៦
៤. ២. ១- ប្រព័ន្ធកំណត់អត្តសញ្ញាណ និងការបញ្ជូនរកសេវាគាំទ្រផ្សេងៗ........................................ ២៦
៤. ២. ២- ហេដ្ឋារចនា និងបរិស្ថានសាលារៀន....................................................................... ២៨
៤. ៣- ការដាក់បញ្ចូលកុមារក្នុងលក្ខណៈបរិស្ថានស្របនឹងអាយុ.................................................... ២៩
៤. ៤- ការកំណត់ចំនួនសិស្សនៅក្នុងថ្នាក់រៀន......................................................................... ២៩
៤. ៤- ការធានាថាកុមារពិការបានចូលរួមគ្រប់សកម្មភាព........................................................... ៣០
៤. ៥. ២- ការបញ្ជូន និងសម្របសម្រួលកុមារ សាលាអប់រំពិសេស និងសាលាទូទៅធម្មតា.................. ៣០
៤. ៥. ២- ផែនការអប់រំជាបុគ្គល.......................................................................................... ៣១
៤. ៥. ៣- ឥរិយាបថគាំទ្រក្នុងថ្នាក់រៀន.................................................................................. ៣១
៤. ៦- ការសហការរវាងគ្រូបង្រៀន គ្រួសារ និងសហគមន៍.......................................................... ៣២
៤. ៧- ការបណ្តុះបណ្តាល និងបំប៉នគ្រូបង្រៀនដែលបង្រៀនកុមារពិការ.......................................... ៣៣
៤.៨- សរុបបញ្ហា.............................................................................................................. ៣៣

## ជំពូកទី៥

## សេចក្តីសន្និដ្ឋាន និងសំណូមពរ

៥. ១- សេចក្តីសន្និដ្ឋាន..................................................................................................... ៣៥
៥. ២- សំណូមពរ............................................................................................................. ៣៦
ឯកសារយោង................................................................................................................. ៣៨
ឧបសម្ព័ន្ធ.................................................................................................................... ៤១

# បញ្ជីតារាង


| | | |
|---|---|---|
| តារាងទី១ | សមាសភាពអ្នកចូលរួមផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវ................................ | ២៥ |
| តារាងទី២ | មានជំនាញអប់រំពិសេ និងគ្រូមិនមានការបណ្តុញបណ្តាលជំនាញអប់រំពិសេស ....... | ២៥ |
| តារាងទី៣ | ការទទួលចុះឈ្មោះចូលរៀន និងការកំណត់អត្តសញ្ញាណកុមារមានពិការភាព........ | ២៦ |
| តារាងទី៤ | ការស្វែងរកការគាំផ្សេងៗ (ផ្នែកឧបករណ៍ជំនួយ និងសេគាំទ្រសុខភាពផ្សេងៗ...... | ២៧ |
| តារាងទី៥ | ការរៀបចំហេដ្ឋារចនា និងបរិស្ថានសាលារៀន............................................ | ២៨ |
| តារាងទី៦ | ការគាំទ្រដោយប្រឹក្សាយោបល់ពីគ្រូជំនាញអប់រំពិសេស.................................. | ២៨ |
| តារាងទី៧ | ការរៀបចំសិស្សនៅវិទ្យាល័យអប់រំពិសេស................................................. | ២៩ |
| តារាងទី៨ | ការបញ្ជូនកុមាររៀនផ្លាស់វេនពីសាលាអប់រំពិសេ ទៅសាលាចំណោះទូទៅធម្មតា........ | ៣០ |
| តារាងទី៩ | ការជួយសិស្សជាការអប់រំបុគ្គលសម្រាប់សិស្សពិការម្នាក់ក្នុងថ្នាក់អប់រំទូទៅ............ | ៣១ |
| តារាងទី១០ | កាត់បន្ថយការរើសអើង..................................................................... | ៣២ |
| តារាងទី១១ | ជំនួបប្រឹក្សាជាមួយមាតាបិតា................................................................ | ៣២ |
| តារាងទី១២ | ការបំប៉នសមត្ថភាពគ្រូបង្រៀនកុមារពិការ................................................. | ៣៣ |

# ជំពូកទី១
# សេចក្តីផ្តើម

## ១. ១ លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងពិភពលោក មានជនមានពិការភាពប្រមាណជាង១ពាន់លាននាក់ ក្នុងនោះជនមានពិការភាពចំនួន ២០០លាននាក់កំពុងប្រឈមនឹងជីវភាពរស់នៅដោយលំបាក។ក្នុងចំនោមនោះ១០%នៃកុមារពិការភាពកំពុងរស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍ(ក្រុមប្រឹក្សាសកម្មភាពជនពិការ, ២០១៤)។ ឆ្លើយតបនឹងតបនឹងបញ្ហានេះ នៅឧសភាឆ្នាំ២០១៣ សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីស្តីពីទស្សនវិស្ស័ ជនមានពិការភាពប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិកបានចេញសេចក្តីប្រកាសទីក្រុងអ៊ីនឈាន់ និងក្របខណ្ឌសកម្មភាពឆ្ពោះទៅរកការអប់រំមានគុណភាព សមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ សេចក្តីប្រកាសនេះបានកំណត់ចក្ខុវិស័យអប់រំឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព បានកំណត់គោលនយោបាយអប់រំជានាឱ្យមានការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន និងការលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា (ក្រសួង អយក, ២០១៧)។

ដើម្បីឆ្លើយតបបនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពត្រង់ចំណុចទី៤ "ការអប់រំបរិយាបន្ន សមធម៌ គុណភាព និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា" ក្រសួងអប់រំ យុវជន និងកីឡាបានខិតខំយកចិត្តទុកដាក់លើកកម្ពស់គុណភាពអប់រំ ជាពិសេសបង្កើនអត្រាឡើងថ្នាក់ កាត់បន្ថយអត្រាបោះបង់ការសិក្សាផ្តោតសំខាន់លើការអនុវត្តសិទ្ធិកុមារជាមូលដ្ឋាន ដែលជានាសមធម៌នៃការរៀនរបស់កុមារគ្រប់ប្រភេទ (ក្រសួង អយក, ២០១៨)។

វិធីបង្រៀនការអប់រំបរិយាបន្នជាច្រើន ដែលផ្តោតលើកុមារពិការត្រូវបានបង្កើតឡើងចាប់តាំងពីឆ្នាំ២០០៣ ដោយក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាល(NGO) ដែលធ្វើការក្នុងវិស័យអប់រំ (ក្រសួង អយក, ២០១៨)។

អនុសញ្ញាអន្តរជាតិ និងគោលនយោបាយជាតិបានលេចចេញជារូបរាងសម្រាប់ជាមធ្យោបាយជួយឱ្យកុមារពិការក្នុងព្រះរាជាណាចក្រកម្ពុជាទទួលបានការអប់រំ (អង្គការសហប្រជាជាតិ, ២០១៥)។ កុមារគ្រប់រូបតែងមានលក្ខណៈខុសៗគ្នា និងមានតម្រូវការផ្សេងៗពីគ្នាទោះបីពួកគេមានពិការភាពដូចគ្នាក៏ដោយ។ តាមរយៈការអប់រំបរិយាបន្ន យើងទទួលស្គាល់សិទ្ធិកុមារពិការ គឺសិទ្ធិទទួលបានការគោរពជាបុគ្គលនៅក្នុងសង្គម និងទទួលបានការអប់រំជាមួយអ្នកមិនពិការ។ បច្ចុប្បន្នគោលការណ៍អប់រំបរិយាបន្នត្រូវបានទទួលស្គាល់ជាសកល និងត្រូវបានគេកំពុងអនុវត្តក្នុងបណ្តាប្រទេសជាច្រើនទាំងនៅក្នុងប្រទេសអភិវឌ្ឍ និងកំពុងអភិវឌ្ឍ។ ដោយសារការអប់រំបរិយាបន្នផ្អែកលើទស្សនៈសង្គមចំពោះពិការភាព ហេតុដូច្នេះការអប់រំបរិយាបន្នប្រកបដោយគុណភាព មិនត្រឹមតែផ្តោតការយកចិត្តទុកដាក់លើសិទ្ធិកុមារក្នុងការអប់រំប៉ុណ្ណោះទេ ថែមទាំងសិទ្ធិចូលរួមពេញលេញក្នុងគ្រួសារ សង្គម និងសហគមន៍ដែលបានបង្កើតឡើងដើម្បីគោរពសេចក្តីថ្លៃថ្នូរ និងតម្លៃរបស់កុមារគ្រប់រូប (ក្រសួង អយក, ២០១៨)។

## ១. ២ ចំណោទបញ្ហាស្រាវជ្រាវ

ឆ្លើយតបនឹងគោលនយោបាយដែលធ្វើការអប់រំ ប្រកបដោយបរិយាបន្ននេះ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំគោលនយោបាយ និងផែនការសកម្មភាពស្តីពីការអប់បរិយាបន្នដែលក្នុងនោះផ្តោតសំខាន់ ទៅលើការចូលរៀនរបស់កុមារមានពិការភាព (ពិការភ្នែក កាយសម្បទា គ-ថ្លង់ និងពិការសតិបញ្ញា) និងអ្នកសិក្សាពូកែដែលមានទេព្យកោសល្យ និង/ឬបញ្ញាខ្ពស់នៅក្នុងសាលាសាធារណៈទូទៅ និងសាលាអប់រំពិសេសទាំង៥ (ក្រសួង អយក, ២០១៨)។ ក្នុងឆ្នាំ២០១៧ ដោយមានការខិតខំប្រឹងប្រែងពង្រឹងគុណភាពអប់រំសម្រាប់កុមារពិការនៅកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា បានផ្ទេរសាលាកុមារពិការភ្នែក និងគ-ថ្លង់ពីអង្គការគ្រួសារថ្មី ឱ្យមកស្ថិតការគ្រប់គ្រងរបស់ក្រសួង និងបានប្រែក្លាយទៅវិទ្យាល័យអប់រំពិសេសទាំង៥ (ភ្នំពេញថ្មី ច្បារអំពៅ កំពង់ចាម សៀមរាប និងបាត់ដំបង)។ វិទ្យាល័យអប់រំពិសេសទាំង៥ ជាវិទ្យាល័យដែលមានលក្ខណៈពិសេស ដែលត្រូវគ្រប់គ្រង និងទទួលសិស្សចុះឈ្មោះចូលរៀនកុមារពិការដែលមានលក្ខណៈធ្ងន់ធ្ងរ(កម្រិតធ្ងន់) ពីគ្រប់រាជធានី ខេត្ត ក្រុង ស្រុក ក្នុងប្រទេសកម្ពុជា ពីកម្រិតមត្តេយ្យសិក្សា រហូតដល់មធ្យមសិក្សា(ថ្នាក់ទី១២)។ តាមរយៈគោលនយោបាយអប់រំជាតិ និងការខិតខំរបស់ក្រសួងអប់រំ យុវជន និងកីឡាកន្លងមក ការអប់រំកុមារពិការ ត្រូវបានចាត់ថាជាអាទិភាពពិសេសមួយដោយមានចំណុចល្អជាច្រើនត្រូវបានអនុវត្ត និងបញ្ហាប្រឈមដែលនៅលំបាក ដើម្បីធ្វើឱ្យ**ការអនុវត្តការអប់រំប្រកបដោយបរិយាបន្នទៅលើកុមារពិការនៅកម្ពុជាមានប្រសិទ្ធភាព** (ក្រសួង អយក, ២០១៨)។

## ១. ៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះ គឺសិក្សាពីប្រសិទ្ធភាពនៃការអនុវត្តការអប់រំប្រកបដោយបរិយាបន្ន និងបញ្ហាប្រឈមនានាការផ្តល់សេវាអប់រំកុមារមានពិការភាពនៅវិទ្យាល័យអប់រំពិសេសក្នុងប្រទេសកម្ពុជា។

## ១. ៤ សំណួរស្រាវជ្រាវ

សំណួរនៃការស្រាវជ្រាវសម្រាប់ការសិក្សានេះគឺ៖

១.តើមានចំណុចសំខាន់អ្វីខ្លះ ដែលអនុវត្តទទួលបានជោគជ័យក្នុងអប់រំកុមារមានពិការភាពកន្លងមកនៅវិទ្យាល័យអប់រំពិសេស?

២.តើមានបញ្ហាប្រឈមអ្វីខ្លះ ដែលនាំឱ្យមានការលំបាកក្នុងការអនុវត្តការអប់រំកុមារមានពិការភាព? (តាមទស្សនៈ និងបទពិសោធន៍របស់គ្រូ និងថ្នាក់ដឹកនាំ)

៣.តើមានធនធានណាខ្លះ ដែលត្រូវចូលរួមដើម្បីធ្វើឱ្យមានការអប់រំប្រកបដោយបរិយាបន្នទៅលើកុមារមានពិការភាព?

## ១. ៥ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

### ១. ៥. ១ វិសាលភាពនៃការស្រាវជ្រាវ

អ្នកស្រាវជ្រាវនឹងធ្វើការសិក្សាអំពី "ការអនុវត្តការអប់រំប្រែកបដោយបរិយាបន្នទៅលើកុមារមានពិការភាពនៅកម្ពុជា" ដោយបង្ហាញប្រសិទ្ធភាពក្នុងការអនុវត្តការផ្តល់សេវាអប់រំទៅដល់កុមារមានពិការភាពនៅវិទ្យាល័យអប់រំពិសេសទាំង៥កន្លងមក។

### ១. ៥. ២ ដែនកំណត់នៃការស្រាវជ្រាវ

អ្នកស្រាវជ្រាវ សិក្សានៅវិទ្យាល័យអប់រំពិសេសទាំង៥ (វិទ្យាល័យអប់រំពិសេសភ្នំពេញថ្មី និងច្បារអំពៅនៅរាជធានីភ្នំពេញ វិទ្យាល័យអប់រំពិសេសកំពង់ចាមនៅក្នុងខេត្តកំពង់ចាម វិទ្យាល័យអប់រំពិសេសសៀមរាបក្នុងខេត្តសៀមរាប និងវិទ្យាល័យអប់រំពិសេសបាត់ដំបងក្នុងខេត្តបាត់ដំបង) ជាមួយនាយក នាយិកា នាយករង នាយិការង ចំនួន ១៤នាក់ លោកគ្រូ អ្នកគ្រូ និងបុគ្គលិកសិក្សាទាំងអស់គ្រូចំនួន១០៣នាក់។

## ១. ៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ ជាគន្លឹះបន្ថែមទៀតដែលនឹងដែលជំរុញការអនុវត្តការអប់រំប្រែកបដោយបរិយាបន្ននៅវិទ្យាល័យអប់រំពិសេសឱ្យកាន់តែប្រសើរឡើង។ តាមរយៈការស្រាវជ្រាវនេះអាចឱ្យដឹងនូវ៖

១.តើមានចំណុចសំខាន់ ដែលអនុវត្តទទួលបានជោគជ័យក្នុងអប់រំកុមារមានពិការភាពកន្លងមកនៅវិទ្យាល័យអប់រំពិសេស

២.ឧបសគ្គ និងបញ្ហាប្រឈមក្នុងការផ្តល់សេវាកាអប់រំកុមារមានពិការភាព

៣. ធនធាន និងវិធីសាស្រ្តសំខាន់ៗ ដើម្បីយកទៅអនុវត្តនៅសាលាសាធារណៈទូទៅ លើថ្នាក់អប់រំបរិយាបន្ន និងថ្នាក់សមាហរណកម្ម សម្រាប់កុមារមានពិការភាពទូទាំងប្រទេសកម្ពុជា។

## ១. ៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកចេញជាប្រាំជំពូក រួមមាន៖

**ជំពូកទី១ សេចក្តីផ្តើម៖** សេចក្តីផ្តើម ក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវ នឹងលើកឡើងពីលំនាំបញ្ហាចំណោទ បញ្ហាគោលបំណងស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងវិសាលភាពនៃការស្រាវជ្រាវ។

**ជំពូកទី២ ការរំលឹកទ្រឹស្តី៖** រាល់ទ្រឹស្តីរបស់អ្នកសិក្សាស្រាវជ្រាវមុនៗ ដែលពាក់ព័ន្ធនឹងប្រធានបទនេះត្រូវបានលើកឡើងដើម្បីធ្វើជាគំនិត និងឆ្លុះបញ្ចាំង ទៅនឹងការរកឃើញថ្មី នៅក្នុងស្នាដៃស្រាវជ្រាវនេះផងដែរ។

**ជំពូកទី៣ វិធីសាស្រ្តស្រាវជ្រាវ៖** នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវបង្ហាញ នូវឧបករណ៍ស្រាវជ្រាវ វិធីសាស្រ្តប្រមូលទិន្នន័យ វិធីជ្រើសរើសគំរូសំណាក ព្រមទាំងវិធីសាស្រ្តវិភាគទិន្នន័យដែលប្រមូលបាន ។

**ជំពូកទី៤ លទ្ធផលនៃការស្រាវជ្រាវ៖** លទ្ធផលនៃការស្រាវជ្រាវ ត្រូវបានយកមកបកស្រាយ និង ពិភាក្សា យ៉ាងក្បោះក្បាយ ដើម្បីរកឱ្យឃើញនូវចំណុចល្អ និងចំណុចដែលត្រូវធ្វើឱ្យប្រសើរឡើងវិញ នៅក្នុង ស្ថានភាពជាក់ស្តែង របស់វិទ្យាល័យអប់រំពិសេស ។

**ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ៖** នេះជាផ្នែកដែលអ្នកស្រាវជ្រាវ ធ្វើការសន្និដ្ឋានទៅលើ ចំណុចទាំងអស់ ដែលបានយកមកវិភាគ ព្រមទាំងលើកឡើងនូវសំណូមពរ មួយចំនួនក្នុងបំណង លើកកម្ពស់ ការអប់រំកុមារពិការនៅតាមវិទ្យាល័យអប់រំពិសេសឱ្យបានប្រសើរឡើង និងបន្តនិរន្តរ៍ភាព ដែលជាគំរូដល់ការផ្តល់ សេវាអប់រំប្រកបដោយបរិយាបន្ននៅសាលារៀនទូទៅ។

# ជំពូកទី២

# រំលឹកទ្រឹស្តី

## ២. ១- សេចក្តីផ្តើម

បច្ចុប្បន្ននេះក្រសួងអប់រំ យុវជន និងកីឡាបានចាប់ផ្តើមរៀបចំស្ថិតិកុមារពិការនៅក្នុងប្រព័ន្ធ ព័ត៌មានគ្រប់គ្រងអប់រំជាបណ្តើរៗ។ ប៉ុន្តែតាមរយៈការអង្កេតសេដ្ឋកិច្ចសង្គមកិច្ចឆ្នាំ២០០៤ បានឱ្យដឹងថាជនដែលមានបញ្ហាមើល បញ្ហាចលនា និងបញ្ហាស្តាប់មានរហូតដល់៦៨%នៃចំនួនជនពិការទាំងអស់ ក្នុងនោះមានកុមារី ២.៦% និងកុមារា២.៩% ដែលមានអាយុចន្លោះពី៥ឆ្នាំ ទៅ១៧ឆ្នាំមិនបានចូលរៀនដោយសារពិការភាព (ក្រសួងសង្គមកិច្ច, ឆ្នាំ២០០៤)។

ប្រឈមនឹងបញ្ហាពិការភាពរបស់កុមារនៅកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាអង្គការជាតិ និងអន្តរជាតិ បានផ្តួចផ្តើមគំនិតសំខាន់ៗដូចជា៖

រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមជាហត្ថលេខី ក្នុងការផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញាអន្តរជាតិជាច្រើន។ រាជរដ្ឋាភិបាលកម្ពុជា បានគាំទ្រសេចក្តីថ្លែងការណ៍សាលាម៉ាន់កា ឆ្នាំ១៩៩៤ស្តីពីការអប់រំកុមារស្ថិតក្នុងសេចក្តីត្រូវការពិសេស ក្របខណ្ឌសកម្មភាពសហស្សវត្សរ៍ បីវ៉ាកូឆ្នាំ២០០៣ និងសេចក្តីថ្លែងការណ៍ក្រុងបាងកកឆ្នាំ ២០០៦ នៃអនុញ្ញាអន្តរជាតិ ស្តីពីសិទ្ធិជនពិការ ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ។ ការផ្តួចផ្តើមទាំងនេះផ្តល់ការគាំទ្រសិទ្ធិដល់កុមារក្នុងការទទួលការអប់រំប្រកបដោយសមធម៌ តាមរយៈការអប់រំបញ្ចូលគ្នាដែលជាមធ្យោបាយអទិភាព(អង្គការសហប្រជាជាតិ, ២០១៥)។

រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ គោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ជនពិការ។ ក្នុងមាត្រា៧៤ នៃច្បាប់រដ្ឋធម្មនុញ្ញដែលបានចែងថា រដ្ឋជួយឧបត្ថម្ភជនពិការ និងដល់គ្រួសារ យុទ្ធជនដែលបូជាជីវិតដើម្បីប្រទេសជាតិ(រដ្ឋធម្មនុញ្ញ, ១៩៩៣)។

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ចំពោះការអប់រំកុមារពិការ ដោយបង្កើតច្បាប់ស្តីពីការអប់រំ។ ជំពូកទី៧ មាត្រា៣៨ និង៣៩ បានលើកឡើងពីការអប់រំពិសេស ពីសិទ្ធិអ្នកសិក្សាពិការ ក្នុងការសិក្សាជាមួយសិស្សនិស្សិតទូទៅក្នុងកម្មវិធីធម្មតា និងកម្មវិធីអប់រំពិសេសសម្រាប់អ្នកសិក្សាពិការ (ច្បាប់ស្តីពីការអប់រំ, ២០០៧)។

គោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ធានាចំពោះកុមារ និងយុវជនកម្ពុជាទាំងអស់ ឱ្យមានឱកាសស្មើៗគ្នាក្នុងការទទួលបានកម្រិតអប់រំមូលដ្ឋាន ក្នុងនិងក្រៅប្រព័ន្ធដោយមិនប្រកាន់កម្រិតជីវភាព ភេទ ភូមិសាស្ត្រ កាយសម្បទា និងជនជាតិឡើយ ដើម្បីសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នា ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងកម្មវិធីគាំទ្រវិស័យអប់រំដែលធានាចំពោះកុមារទាំងអស់ នៅឆ្នាំ២០១៥ ក្នុងការទទួលបានកម្រិតអប់រំមូលដ្ឋានរយៈពេល៩ឆ្នាំ (ក្រសួងអយក, ២០១៥)។

ក្រសួងអប់រំ យុវជន និងកីឡាបានសហការជាមួយក្រុមប្រឹក្សាសម្មភាពជនពិការដោយមានការឧបត្ថម្ភថវិកាពីអង្គការយូនីសេហ្វ និងដៃគូអភិវឌ្ឍនានា។ ដៃគូអភិវឌ្ឍនានាបានផ្តល់សេវាអប់រំដល់កុមារពិការដូចជាអង្គការគ្រួសារថ្មីបានបង្កើតសាលាពិសេសសម្រាប់កុមារគ-ថ្លង់ និងពិការភ្នែក ព្រមទាំងជួយបណ្តុះបណ្តាលភាសាសញ្ញា និងអក្សរស្ទាបដល់គ្រូក្របខណ្ឌរដ្ឋ ដែលបង្រៀនថ្នាក់សមាហរណកម្ម (ក្រសួង អយក, ១៩៩៣)។

ក្រសួងបានបង្កើតក្រុមអនុវត្តថ្នាក់ខេត្តក្រុង ជាអ្នកពិនិត្យតាមដាន និងសម្របសម្រួលការអនុវត្តកម្មវិធីពិសេស តាមសាលារៀនផ្ទាល់ ក៏ប៉ុន្តែក្រុមការងារនេះនៅខ្វះជំនាញក្នុងការអប់រំដល់គ្រួសារកុមារពិការ និង

បច្ចេកទេសគរុកោសល្យដល់គ្រូបង្រៀនហើយមួយចំនួនទៀតទទួលបន្ទុកការងារច្រើនពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការអនុវត្ត កម្មវិធីអប់រំបញ្ចូលគ្នាឱ្យបានដិតដល់ ដែលជាហេតុធ្វើឱ្យដំណើរការនៃកម្មវិធីនេះពុំទាន់មានភាពរលូន និងទទួលបានលទ្ធផលល្អប្រសើរនៅឡើយ (ក្រសួង អយក, ២០១៥)។

## ២.២- និយមន័យ

### ២.២.១ ការអប់រំបរិយាបន្ន

ការអប់រំបរិយាបន្នគឺសំដៅទៅលើការបញ្ចូលកុមារទាំងអស់ឱ្យរៀនជាមួយគ្នា ទាំងនៅក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធអប់រំ ដោយមិនបែងចែកអំពីភេទ ចរិតលក្ខណៈ កាយសម្បទា បញ្ញាស្មារតី ស្ថានភាពសង្គម ភាសា វប្បធម៌ សាសនា ឬលក្ខណៈផ្សេងៗទៀតឡើយ (International Conference on Education, Geneva, ២០០៨)។

អង្គការUNESCO ឱ្យនិយមន័យការអប់រំបរិយាបន្នគឺជា "វិធីសាស្ត្រសកម្មនៃការឆ្លើយតបដោយវិជ្ជមានទៅកាន់ភាពចម្រុះគ្នានៃសិស្ស និងការមើលឃើញភាពខុសគ្នារបស់សិស្សមិនមែនជាបញ្ហា ប៉ុន្តែជាឱកាសសម្រាប់ធ្វើឱ្យការសិក្សាប្រសើរឡើង" (UNESCO, 2005)។

ការអប់រំបរិយាបន្ន គឺជាដំណើរការនៃការដោះស្រាយ និងការឆ្លើយតបទៅនឹងតម្រូវការ ផ្សេងៗ របស់កុមារ យុវជន និងមនុស្សពេញវ័យគ្រប់រូប តាមរយៈការបង្កើនការចូលរួមក្នុងវប្បធម៌សិក្សា និងសហគមន៍ ព្រមទាំងការកាត់បន្ថយ និងការលុបបំបាត់ការមិនរាប់បញ្ចូលនៅក្នុង និងពីប្រព័ន្ធអប់រំ (ក្រសួង អយក, ២០១៧)។ ដើម្បីធ្វើឱ្យអ្នកសិក្សាពិការអាចទទួលបានការអប់រំបរិយាបន្នប្រកបដោយប្រសិទ្ធភាពនេះ យើងនឹងសិក្សាលម្អិតនៃការអនុវត្តការរៀន និងបង្រៀននៅក្នុងសាលាដែលមានជនពិការ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធសិក្សា ដែលជួយសម្រួលបានសមស្របសម្រាប់អ្នកសិក្សាពិការ ការស្វែងរកសេវាគាំទ្រនិង បញ្ជូនកុមារពិការឱ្យទទួលសេវាអប់រំ ការខិតខំជំរុញលើកទឹកចិត្តឱកាសចូលរួមផ្សេងដល់ជនពិការ និងការរក្សានូវនិរន្តរ៍ភាពសម្រាប់ការអប់រំបន្តដល់ជនពិការ (ក្រសួង អយក, ២០១៨)។

### ២.២.២ ពិការភាព

យោងតាមចំណែកថ្នាក់ពិការភាពដែលបានកំណត់ដោយអន្តរក្រសួង (រាជរដ្ឋាភិបាលកម្ពុជា, ២០១១) បានបែងចែកប្រភេទពិការដូចជា៖

- **ពិការកាយសម្បទា**
  - **ពិបាកក្នុងការធ្វើចលនាៈ** ជនទាំងឡាយណាដែលមានលទ្ធភាពធ្វើចលនា(ដោយរាងកាយ) ផ្លាស់ទីដោយលំបាក ឬលំបាកកំរើកផ្នែកណាមួយនៃរាងកាយ ឬមិនអាចកំរើកបាន។ ឧទាហរណ៍ៈ ដាច់ដៃ ដាច់ជើង ស្វិតជើង ស្វិតសាច់ដុំ គាំងសន្លាក់ បាក់ឆ្អឹង សាច់ដុំរួញខ្លី ខូចប្រព័ន្ធបញ្ជាចលនារបស់ខួរក្បាល ជើងខ្វេ ជើងកែក ទន់ត្រឹមកដៃ ជើងទន់ ខូចទ្រង់ទ្រាយពីកំណើត ស្លាប់មួយចំហៀងខ្លួន / កំណាត់ / អវៈយវៈខូចសរសៃ (nerve)កំហូចរាងឆ្អឹងខ្នង (កោងទៅមុខ កោងទៅចំហៀង និងកោងទៅក្រោយ) ពិការដោយសារផលវិបាក នៃជំងឺ ខូចស្នាម្ខាង ភ្លាត់ត្រគាកធ្ងន់ធ្ងរ បួសខួរឆ្អឹងខ្នង គ្រិចធ្ងន់ធ្ងរ រលាកធ្ងន់ធ្ងរ (ភ្លើង ទឹកអាស៊ីត...)។

- **ពិបាកក្នុងការស្តាប់៖** ជនទាំងឡាយណាដែលពិបាកក្នុងការស្តាប់ ឬលទ្ធភាពនៃការស្តាប់ចុះខ្សោយ ឬមិនអាចស្តាប់បាន (ពីកំនើត ដោយសារគ្រោះថ្នាក់ ឬរបួស ឬជំងឺ ឬវ័យជរា...។ល។)។ ឧទាហរណៈ ថ្លង់ ត្រចៀកអត់រន្ធ ពុំមានក្រដាសត្រចៀក ធ្លាយក្រដាសត្រចៀក ហៀរអំបោអំបែក ធ្ងន់ធ្ងរ រន្ធត្រចៀកមានដុំពក។
- **ពិបាកក្នុងការនិយាយ៖** ជនទាំងឡាយណាដែលពិបាកក្នុងការនិយាយ និយាយមិនច្បាស់ ឬនិយាយមិនរួចទាល់តែសោះ ឬអ្នកដទៃពិបាកស្តាប់ (ពីកំណើតដោយសារគ្រោះថ្នាក់ ឬរបួស ឬជំងឺ ឬវ័យជរា...។ល។)។ ឧទាហរណ៍៖ និយាយត្រឡាន់(អណ្តាតធំ) / គ្រដិតធ្ងន់ធ្ងរ ឆែបក្រអូមមាត់ ក្រឡើត ក្រងួរ និយាយមិនច្បាស់ និយាយមិនចេញ គ ផលវិបាកនៃជំងឺ។
- **ពិបាកក្នុងការមើល៖** ជនទាំងឡាយណាដែលមានគំហើញចុះខ្សោយ ឬមិនអាចមើលឃើញ (ពីកំណើត ដោយសារគ្រោះថ្នាក់ ឬរបួស ឬជំងឺ ឬវ័យជរា...។ល។)។ ឧទាហរណ៍៖ ងងឹតភ្នែកម្ខាង ឬទាំងសងខាង ស្វិតសរសៃបាតភ្នែក ភ្នែកលៀនមើលមិនឃើញ កន្ទុយថ្លែនធ្ងន់ធ្ងរ ភ្នែកឡើងបាយ ត្រាក់កូមធ្ងន់ធ្ងរបណ្តាលឱ្យមានប្រែងចាក់ ភ្នែកស្រលៀង ភ្នែកមីញ៉ូប ធ្លាក់ត្របកភ្នែក សម្លាកកញ្ចក់ភ្នែក សម្ពាធទឹកក្នុងភ្នែកកើនឡើង រលាកសរសៃបាតភ្នែក ងងឹតពណ៌។
- **ពិបាកសរីរាង្គខាងក្នុង៖** ជនទាំងឡាយណាដែលវះកាត់សរីរាង្គខាងក្នុង សំខាន់ៗ (ដោយមានការបញ្ជាក់ពីគ្រូពេទ្យជំនាញ) ឬចុះខ្សោយមុខងារនៃភាពស៊ាំ និងមានជំងឺរ៉ាំរ៉ៃ...។ល។ ឧទាហរណ៍៖ ខ្សោយមុខងារសរីរាង្គ៖ បេះដូង ក្រលៀន ប្រព័ន្ធដង្ហើម តម្រងនោម ពោះវៀន ថ្លើម។

- **ពិការសតិបញ្ញា**

ជនទាំងឡាយណាដែលមានផលវិបាកក្នុងការចងចាំ ភ្លេចច្រើន ឬមិនអាចដូចមនុស្សដទៃទៀតដែលមានអាយុជំណាលគ្នា(ពីកំណើតដោយសារគ្រោះថ្នាក់ឬរបួស ឬជំងឺ....។ល។ ឧទាហរណ៍៖ បញ្ញាលូតលាស់យឺត រៀនខ្សោយ/ ការចងចាំមានកម្រិត (Cretinism) ខូចប្រព័ន្ធបញ្ញាក្នុងខួរក្បាល (Cerebral Palsy) និងជំងឺដោនសាំងដ្រូម មានចរិកទុយមុយ (Autism) ។

- **ពិការផ្លូវចិត្ត**

ជនទាំងឡាយណាដែលមានវិប្បត្តិផ្នែកអាកប្បកិរិយា អារម្មណ៍ និងការគិត ដែលកើតឡើងជាប្រចាំ ហើយរំខានដល់ការបំពេញមុខងារប្រចាំថ្ងៃ។ ឧទាហរណ៍៖ អាក្រាត និយាយ សើច យំ ច្រៀង រាំលេង តែម្នាក់ឯងខុសពីប្រក្រតី ស្ទឹងស្មាត ដេរគេដេរឯង វាយ ឬប្រព្រឹត្តអំពើហិង្សាដោយមិនដឹងខ្លួន មិនដឹងគ្រោះថ្នាក់ ជំងឺមន្ទិលសង្ស័យ វិកលចរិក ខូចសតិអារម្មណ៍ តានតឹងផ្លូវចិត្ត ជំងឺធ្លាក់ទឹកចិត្ត ថប់អារម្មណ៍ ជំងឺវង្វេង ។

- **ពិការផ្សេងៗ**

ជនទាំងឡាយណាដែលលំបាកក្នុងការបំពេញតួនាទីផ្នែករាងកាយ ឬតួនាទីក្នុងសង្គម ឬពិការដែលមិនអាចចាត់ចូលទៅក្នុងប្រភេទពិការណាមួយខាងលើ ឬពហុពិការ។ ឧទាហរណ៍៖ មុខមាត់ខូចទ្រង់ទ្រាយ ក្បាលធំ តឿ ក្រិន ពកក ផលវិបាកក្នុងការបំពេញមុខងារដោយសារគ្រោះថ្នាក់ និងជំងឺរ៉ាំរ៉ៃ ...។ល។

## ២.៣ ការអប់រំបរិយាបន្ននៅកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់គោលដៅអភិវឌ្ឍសហស្សវត្ស ដែលបង្កើតឡើងដោយធនាគារពិភពលោក និងអ្នកផ្តល់ជំនួយអន្តរជាតិ ពោលគឺសម្រេចឱ្យបាននូវការអប់រំមូលដ្ឋាន។ ក្នុងនាមជាប្រទេសចូលរួមវេទិកាអប់រំពិភពលោក ឆ្នាំ២០០២នៅក្រុងដាហ្កា ប្រទេសសេណេកាល់ រាជរដ្ឋាភិបាលបានកំណត់ទិសដៅការអប់រំសម្រាប់ទាំងអស់គ្នាឱ្យបាននៅត្រឹមឆ្នាំ២០១៥។ នៅក្នុងផែនការសកម្មភាពអប់រំសម្រាប់ទាំងអស់គ្នាគឺបានផ្តល់ការអប់រំបរិយាបន្នសម្រាប់ក្រុមកុមារងាយរងគ្រោះដូចជាកុមារី កុមារក្រីក្រកុមារជនជាតិដើមភាគតិច កុមារពិការ កុមាររស់នៅតាមតំបន់ជនបទ និងកុមារកំព្រា ឬកុមារទទួលរងគ្រោះដោយការជួញដូរជាដើម (ក្រសួង អយក, ២០០២)។

ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតឱ្យមានគោលនយោបាយកុមារមេត្រី ដែលជាការអនុវត្តតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌលដើម្បីធានាឱ្យកុមារទាំងអស់ទទួលបានការអប់រំប្រកបដោយគុណភាព (ក្រសួង អយក, ២០០៣) ។ គោលនយោបាយនេះមានប្រាំមួយសមាសភាគ ក្នុងនោះសមាសភាគទីមួយគឺកុមារទាំងអស់បានចូលរៀនដោយផ្តោតលើសិទ្ធិរបស់កុមារក្នុងការអប់រំ។ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើត គោលនយោបាយស្តីពីការអប់រំសម្រាប់កុមារពិការ ដោយប្រើក្របខណ្ឌសមាសភាគទាំងប្រាំមួយនៃគោលនយោបាយសាលាកុមារមេត្រីដើម្បីបង្ហាញយុទ្ធសាស្ត្រក្នុងការដាក់បញ្ចូលកុមារពិការក្នុងប្រព័ន្ធអប់រំ (ក្រសួងអយក, ២០០៨) ។

ជាកិច្ចខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា លើការផ្តល់ការអប់រំដល់កុមារពិការកម្ពុជា នៅឆ្នាំ២០១៨ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតគោលនយោបាយស្តីពីការអប់រំបរិយាបន្ន។ គោលនយោបាយនេះ មានចក្ខុវិស័យអភិវឌ្ឍជនស្ថិតនៅក្នុងសេចក្តីត្រូវការពិសេសគ្រប់រូបឱ្យទទួលបានការអប់រំពេញមួយជីវិតប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌ (ក្រសួង អយក, ២០១៨) ។ គោលដៅធំៗចំនួនបួននៃគោលនបាយនេះក្នុងការជួយគាំទ្រ និងផ្តល់ការគាំទ្រកុមារពិការមកទទួលបានសេវាអប់រំចាប់ពីកម្រិតមត្តេយ្យសិក្សា ដល់កម្រិតឧត្តមសិក្សា

**១.ធានាការកំណត់អត្តសញ្ញាណបឋម ការវាយតម្លៃ និងធ្វើអន្តរាគមន៍ទាន់ពេល**

**២.ការផ្តល់សេវាអប់រំមានគុណភាពប្រកបដោយបរិយាបន្ន សមធម៌ និងការសិក្សាពេញមួយជីវិត**

**៣.កសាងសមត្ថភាព និងលើកកម្ពស់ការអភិវឌ្ឍជំនាញដល់គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន**

**៤. លើកកម្ពស់ការយល់ដឹង និងការចូលរួម។**

វត្ថុបំណងនៃការអប់រំបរិយាបន្ននៅកម្ពុជាគឺធានា “ការអប់រំបរិយាបន្ន សមធម៌ គុណភាព និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា” មានន័យថាធ្វើយ៉ាងណាឱ្យកុមារទាំងអស់អាចមកទទួលការអប់រំបានល្អប្រសើរចាប់ពីកម្រិតមត្តេយ្យរហូតដល់ឧត្តមសិក្សា។ ឆ្លើយតបនឹងវត្ថុបំណងខាងលើនេះ រាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជាដែលជាហត្ថលេខីគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ ២០១៦-២០៣០ បានកំណត់គោលដៅបរិយាបន្នស្តីពីការកសាង និងធ្វើឱ្យប្រសើរឡើងនៅសម្ភារៈសិក្សាដែលឆ្លើយតបទៅនឹងពិការភាព យេនឌ័រ ព្រមទាំងផ្តល់នូវបរិស្ថានសិក្សាដែលមានសុវត្ថិភាព អហិង្សា បរិយាបន្ន និងប្រសិទ្ធភាពសម្រាប់ទាំងអស់គ្នា។(ក្រសួង អយក, ២០១៨)

## ២.៤ ការអប់រំកុមារពិការ

កុមារពិការមានសិទ្ធិទទួលបានការអប់រំក្នុងលក្ខណៈបរិស្ថានច្រើនបែបដោយមានការគាំទ្រសមស្រប។ ដើម្បីជួយកុមារពិការ ឱ្យសិក្សាទទួលបានជោគជ័យពួកគេត្រូវមានជំនួយសមស្របដូចជារទេះរុញសម្រាប់កុមារពិការជើង ឧបករណ៍ស្ទាបសម្រាប់កុមារពិការភ្នែក ឬគ្រូបង្រៀនទទួលបានការបណ្តុះបណ្តាលដើម្បីយល់ដឹងពីសេចក្តីត្រូវការរបស់កុមារពិការក្នុងថ្នាក់រៀន (ក្រសួង អយក, ២០១៨)។

លក្ខណៈបរិស្ថានបីសំខាន់ៗសម្រាប់កុមារពិការកម្ពុជាទទួលបានការអប់រំមាន៖

- ការអប់រំបរិយាបន្ននៅក្នុងថ្នាក់រៀនទូទៅ
- ការអប់រំក្នុងថ្នាក់សមាហរណកម្ម
- ការអប់រំនៅក្នុងសាលារៀនអប់រំពិសេស

### ២.៤.១ ការអប់រំបរិយាបន្ននៅក្នុងថ្នាក់រៀនទូទៅ

កុមារមានពិការត្រូវបានដាក់បញ្ចូលក្នុងថ្នាក់រៀនទូទៅជាមួយកុមារមិនពិការតាមដែលអាចធ្វើទៅបាន។ ការអប់រំបរិយាបន្ននៅក្នុងថ្នាក់រៀនទូទៅមានប្រសិទ្ធភាពដរាបណាកុមារមានពិការទទួលបានការគាំទ្រសមស្រប និងគ្រូបង្រៀនទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់(ក្រសួង អយក, ២០១៨)។

- ការអប់រំបរិយាបន្ននៅក្នុងថ្នាក់រៀនទូទៅជាមួយកុមារ មិនមែនមានន័យថា គ្រាន់តែដាក់ឱ្យកុមាររៀននៅទីនោះ ដោយសារតែយើងគិតថាវាមិនល្អដែលដាក់ពួកគេឱ្យនៅដោយឡែកនោះទេ។ ប៉ុន្តែពួកគេត្រូវតែទទួលបានការគាំទ្រនូវឧបករណ៍ជំនួយទៅតាមតម្រូវការដូចជារទេះរុញ ឧបករណ៍ជំនួយការស្តាប់ កែវពង្រីក ក្តារខៀនទំនាក់ទំនង(Communication Board) ដើម្បីពួកគេអាចរៀនជាមួយកុមារដទៃទៀត។
- លើសពីនេះទៅទៀត គ្រូត្រូវទទួលបានការបណ្តុះបណ្តាលសមស្រប និងគ្រប់គ្រាន់ដើម្បីបង្រៀនកុមារពិការ។ ពេលណាគ្រូទទួលបានការបណ្តុះបណ្តាលរួចមកពួកគាត់មានការផ្លាស់ប្តូរផ្នត់គំនិតព្រមទាំងមានឆន្ទៈទទួលយក និងបង្រៀនកុមារពិការ។ ទង្វើបែបនេះធ្វើឱ្យផ្លាស់ប្តូរអាកប្បកិរិយាសង្គមចំពោះជនពិការ។
- កុមារពិការរាងកាយដូចជា បញ្ហាចលនា បញ្ហាមើល និងបញ្ហាស្តាប់មិនខ្វះសមត្ថភាពខាងបញ្ញាទេ ពួកគេអាចរៀនដោយងាយស្រួលក្នុងថ្នាក់រៀនទូទៅជាមួយកុមារមិនពិការ។

ការអប់រំបរិយាបន្នផ្តល់ប្រយោជន៍ជាច្រើនដល់កុមារពិការ កុមារមិនពិការ និងសង្គមដូចជា៖

- បានផ្តល់ឱកាសឱ្យកុមារពិការមានមិត្តភក្តិបានចូលរួមសកម្មភាពក្នុងសាលារៀននិងសហគមន៍។
- បានផ្តល់ឱកាសដល់កុមារមិនពិការបានសិក្សាជាមួយកុមារពិការហើយមើលឃើញថាកុមារពិការអាចសិក្សាជាមួយកុមារពូកែបានផងដែរ។ ពួកគេទទួលស្គាល់គ្នា ហើយក្លាយជាមិត្តនឹងគ្នាដោយមិនរើសអើង និងមិនសើចចំអក។
- ជួយឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយាសង្គមចំពោះជនពិការ។

### ២.៤.២ ការអប់រំនៅក្នុងថ្នាក់សមាហរណកម្ម

កុមារពិការអាចចូលរៀននៅថ្នាក់សមាហរណកម្មដែលជាថ្នាក់រៀនសម្រាប់តែកុមារពិការប៉ុណ្ណោះ ហើយស្ថិតនៅក្នុងថ្នាក់រៀនទូទៅ (ក្រសួង អយក, ២០១៨)។

• កុមារពិការប្រភេទដូចគ្នាដូចជា បញ្ហាស្តាប់ ឬបញ្ហាត្រូវរៀនជាមួយគ្នាដើម្បីមានភាពងាយស្រួលក្នុងការណែនាំ និងការរៀនសូត្រ។

• នៅក្នុងថ្នាក់សមាហរណកម្ម កុមារពិការនឹងទទួលបាននូវសេវាពិសេសដូចជា ការណែនាំអំពីឧបករណ៍សម្រាប់ស្តាប ឬភាសាសញ្ញាតាមរយៈគ្រូដែលទទួលបានការបណ្តុះបណ្តាលពិសេសថែមទាំងមានឱកាសទំនាក់ទំនងជាមួយនឹងកុមារមិនពិការ។

• កុមារក្នុងថ្នាក់សមាហរណកម្មអាចផ្លាស់ទៅថ្នាក់រៀនទូទៅ បន្ទាប់ពីគេទទួលបានជំនាញដែលគេត្រូវការតាមរយៈសេវាទាំងនេះ ដូចជាការគូរូប ផាត់ពណ៌។ ពួកគេអាចផ្លាស់ទៅរៀននៅថ្នាក់ទូទៅបានប្រសិនបើគ្រូទទួលបានការបណ្តុះបណ្តាលពិសេស ឬពួកគេបន្តទទួលសេវាពិសេសនៅទីនោះ។ ឧទាហរណ៍៖ កុមារដែលប្រើភាសាសញ្ញាអាចផ្លាស់ពីថ្នាក់សមាហរកម្មទៅរៀនថ្នាក់រៀនទូទៅ ក្រោយពីគេបានរៀនភាសាសញ្ញាប្រសិនបើមានគ្រូជំនួយដែលបានបណ្តុះបណ្តាលភាសាសញ្ញាក្នុងថ្នាក់រៀនទូទៅ។

• គុណវិបត្តិរបស់ថ្នាក់សមហរកម្ម គឺកុមារពិការមានឱកាសតិចតួចធ្វើជាមិត្តជាមួយកុមារមិនពិការ។ កុមារពិការគ្រាន់តែជួបកុមារមិនពិការនៅពេលម៉ោងសម្រាក ហើយពួកគេមានអារម្មណ៍ខ្មាសអៀន ឬមិនហ៊ាននិយាយទៅកាន់កុមារពិការមិនពិការ។ ជាលទ្ធផល អាកប្បកិរិយារបស់គ្រូ និងកុមារមិនពិការក្នុងការទទួលយកកុមារពិការទាំងនោះ មិនទាន់ផ្លាស់ប្តូរ។

## ២. ៤. ៣ ការអប់រំនៅក្នុងសាលារៀនពិសេស

សាលារៀនពិសេសគឺជាសាលារៀនសម្រាប់តែកុមារពិការតែប៉ុណ្ណោះ((ក្រសួង អយក, ២០១៨)៖

• សាលារៀនពិសេសមិនត្រូវបានលើកទឹកចិត្តនោះទេ ពីព្រោះវាធ្វើឱ្យមានការចំណាយច្រើន និងធ្វើឱ្យកុមារពិការនៅដាច់ឆ្ងាយពីសង្គម ហើយអាចជួយកុមារបានតែមួយចំនួនតូចប៉ុណ្ណោះ។

• ការដាក់កុមារពិការទៅតាមលក្ខណៈបរិស្ថានផ្សេងៗគ្នានេះគួរតែធ្វើទៅតាមករណីជាក់ស្តែង ហើយ ផ្តល់ប្រយោជន៍ល្អបំផុតដល់កុមារតាមរយៈការពិនិត្យមើលចំណុចខ្លាំង តម្រូវការរបស់កុមារម្នាក់ៗ និងបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាល។

• កុមារថ្លង់ត្រូវទទួលបានការបង្រៀនពិសេស ដើម្បីសិក្សាភាសាសញ្ញា។ កុមារបែបនេះត្រូវដាក់ក្នុងថ្នាក់សមាហរណកម្ម ឬសាលារៀនពិសេសពីព្រោះបច្ចុប្បន្ននេះ នៅប្រទេសកម្ពុជាមានគ្រូតិចតួចប៉ុណ្ណោះដែលបានបណ្តុះបណ្តាលភាសាសញ្ញាដើម្បីប្រើប្រាស់ទាក់ទងជាមួយកុមារថ្លង់។ កុមារថ្លង់មានការលំបាកច្រើនក្នុងការសិក្សាជាមួយកុមារដទៃទៀតនៅថ្នាក់រៀនទូទៅ ពីព្រោះគេមិនអាចប្រាស្រ័យទាក់ទងជាមួយគ្រូបង្រៀន និងមិត្តរួមថ្នាក់ផ្សេងទៀត បញ្ហានេះមិនមែនមកពីខួរក្បាលរបស់គេគ្មានសមត្ថភាពនោះទេ។

ទោះបីជាសាលារៀនពិសេសផ្តល់នូវឱកាសដ៏ជាមធ្យោបាយមួយដើម្បីបង្កើនលទ្ធភាពទទួលបានការអប់រំសម្រាប់កុមារដែលមានតម្រូវការសិក្សាបន្ថែម។

ការដាក់កុមារពិការក្នុងរៀនទូទៅដោយការគាំទ្រសមស្រប គឺជាវិធីដ៏មានប្រសិទ្ធភាពបំផុតសម្រាប់ការអប់រំបរិយាបន្ន ពីព្រោះវាផ្តល់ឱកាសឱ្យកុមារសិក្សាពីគ្នាទៅវិញទៅមក និងក្លាយជាមិត្តនឹងគ្នា។ គេអាចដាក់កុមារពិការក្នុងថ្នាក់រៀនសមាហរកម្ម ដើម្បីសិក្សាជំនាញពិសេសដូចជា ឧបករណ៍សម្រាប់ស្ទាប ឬភាសាសញ្ញារបស់កម្ពុជា។ ដោយសារតែឱកាសបង្កើតមិត្តភាពជាមួយកុមារអាយុដូចគ្នាមានកម្រិត ក្នុងថ្នាក់រៀនដោយឡែកទើបកុមារដែលចេះប្រើឧបករណ៍សម្រាប់ស្ទាបអាចផ្លាស់ទៅរៀននៅថ្នាក់ទូទៅវិញ។ សាលារៀនពិសេស មានការចំណាយច្រើន និងមិនបានផ្តល់ឱកាសដល់កុមារពិការជួបគ្នាចងមិត្ត ហើយរៀនជាមួយកុមារមិនពិការឡើយ។

## ២. ៥ សូចនាករណាសម្រាប់អប់រំបរិយាបន្នប្រកបដោយគុណភាព

ការអប់រំបរិយាបន្នប្រកបដោយគុណភាព អាស្រ័យទៅនឹងការផ្តល់ការគាំទ្រសមស្របលក្ខណៈបរិស្ថាន នឹងអាយុ ចំនួនកុមារពិការតិចនៅក្នុងថ្នាក់រៀនទូទៅ ការធានាឱ្យមានការចូលរួមរបស់កុមារពិការគ្រប់សកម្មភាព កិច្ចសហការរវាងគ្រូបង្រៀន គ្រួសារ និងសហគមន៍ព្រមទាំងការបណ្តុះបណ្តាល និងបំប៉នគ្រូបង្រៀនកុមារពិការ។ ការអប់រំបរិយាបន្នប្រកបដោយគុណភាព ត្រូវតែមានកិច្ចសហការល្អរវាងគ្រូបង្រៀន គ្រួសារ និងសហគមន៍ដែរ(ក្រសួង អយក, ២០១៨)។

**សូចនាករទាំងប្រាំមួយសម្រាប់ការអប់រំបរិយាបន្នប្រកបដោយគុណភាព៖**

**១.ការផ្តល់ការគាំទ្រសមស្របដល់កុមារពិការ**

**២.ការដាក់បញ្ចូលកុមារក្នុងលក្ខណៈបរិស្ថានស្របនឹងអាយុ**

**៣.ការមិនឱ្យមានកុមារពិការច្រើនពេកនៅក្នុងថ្នាក់រៀនពិសេស ឬថ្នាក់រៀនទូទៅ**

**៤.ការធានាថាកុមារពិការបានចូលរួមគ្រប់សកម្មភាព**

**៥.ការសហការរវាងគ្រូបង្រៀន គ្រួសារ និងសហគមន៍**

**៦.ការបណ្តុះបណ្តាល និងបំប៉នគ្រូបង្រៀនដែលបង្រៀនកុមារពិការ។**

### ២. ៥. ១ ការផ្តល់គាំទ្រសមស្របដល់កុមារពិការ

ការផ្តល់ការគាំទ្រសមស្របដល់កុមារពិការរួមមាន(ក្រសួង អយក, ២០១៨)៖

- ផ្តល់សម្ភារៈជំនួយ និងឧបករណ៍ជំនួយដូចជា រទេះរុញ ឧបរណ៍ជំនួយស្តាប់ ដៃឬជើងសិប្បនិម្មិត
- កែសម្រួលបរិស្ថាន និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាលារៀនដូចជា ជម្រាប ផ្លូវចូល ទីធ្លាសាលា ថ្នាក់រៀន បង្កាន់ដៃ បង្គន់...។
- គាំទ្រផ្នែកបង្រៀនដូចជា កិច្ចការផ្ទាល់មាត់សម្រាប់កុមារដែលពិបាកមើល ឬកិច្ចការគូរសម្រាប់កុមារដែលពិបាកស្តាប់ ការប្រើក្តារខៀនទំនាក់ទំនងសម្រាប់សិស្សកុមារពិបាកនិយាយ និងពិបាកស្តាប់ឱ្យអង្គុយតុខាងមុខ និងផ្តល់សម្ភារៈ សិក្សាផ្សេង"
- ការគាំទ្រផ្នែកឥរិយាបថដូចជា ការផ្តល់រង្វាន់ដល់កុមារដែលមានឥរិយាបថ សមរម្យ និងវិន័យល្អ។

ជាទូទៅកុមារពិការភាគច្រើនទទួលបានជោគជ័យក្នុងការសិក្សាអាស្រ័យលើការគាំទ្រសមស្រប។ កុមារពិការខ្លះទៀតមិនត្រូវការការទ្រទាំងអស់នោះទេ។ ការគាំទ្រទាំងនេះត្រូវតែសមស្របទៅនឹងតម្រូវការរបស់កុមារព្រមទាំងអាស្រ័យលើកត្តាបុគ្គលផងដែរដូចជា៖

-ជម្រាល រទេះរុញ និងការអង្គុយតុមុខ គឺជាការគាំទ្រសមស្របសម្រាប់កុមារដែលពិការជើង

-ឧបករណ៍ជំនួយស្តាប់ និងការអង្គុយតុមុខសមស្របសម្រាប់កុមារមានបញ្ហាស្តាប់

-ការគាំទ្រខ្លះដូចជា ការឱ្យអង្គុយតុមុខ និងការផ្តល់រង្វាន់អាចផ្តល់ផលប្រយោជន៍ជាច្រើនដល់កុមារពិការ(ក្រសួង អយក, ២០១៨)។

## ២. ៥. ២ ការដាក់បញ្ចូលក្នុងលក្ខណៈបរិស្ថានស្របនឹងអាយុ

ដោយសារតែគោលបំណងមួយ ក្នុងចំណោមគោលបំណងទាំងឡាយនៃការអប់រំបរិយាបន្ន គឺជួយឱ្យកុមារពិការ និងមិនពិការធ្វើជាមិត្តនឹងគ្នាពិតជាមានសារៈសំខាន់ណាស់ក្នុងការផ្ដល់ឱកាសឱ្យកុមារពិការរៀននៅក្នុងថ្នាក់ និងសាលារៀនជាមួយកុមារមិនពិការដែលមានវ័យស្របាលគ្នា។ ករណីខ្លះយើងអាចដាក់កុមារពិការមានអាយុច្រើនក្នុងថ្នាក់ឬសាលារៀនជាមួយកុមារមិនពិការមានអាយុតិចជាង ព្រោះគេទើបចូលរៀនជាលើកដំបូង(ក្រសួង អយក, ២០១៨) ។ ជាទូទៅកុមារអាយុច្រើនអាចមានអារម្មណ៍ខ្មាសអៀនចំពោះកុមារដែលមានអាយុតិចជាង រីឯកុមារអាយុតិចជាងរារែកក្នុងការធ្វើជាមិត្ត ឬអាចនិយាយចំអកដល់កុមារពិការនោះ (ក្រសួង អយក, ២០១៨) ។

## ២. ៥. ៣ ការមិនឱ្យមានកុមារពិការច្រើនពេកនៅក្នុងថ្នាក់រៀនទូទៅ

ការដាក់កុមារពិការពីរ ឬបីនាក់ក្នុងថ្នាក់រៀនទូទៅគឺជាការអនុវត្តការអប់រំបរិយាបន្នយ៉ាងត្រឹមត្រូវ។ សកម្មភាពនេះផ្ដល់ឱកាសឱ្យកុមារចងមិត្តនឹងគ្នា ហើយកុមារមិនពិការនិងគ្រូបង្រៀនអាចជួយពួកគេបានដោយមិនចំណាយពេលវេលាច្រើន(ក្រសួង អយក, ២០១៨) ។

គ្រូបង្រៀនត្រូវឱ្យកុមារពិការអង្គុយឆ្លាស់គ្នាជាមួយកុមារមិនពិការហើយមិនត្រូវឱ្យកុមារពិការទាំងអស់អង្គុយជាមួយគ្នា។ ការឱ្យកុមារអង្គុយបែបនេះ គឺផ្ដល់ឱកាសឱ្យកុមារទាំងអស់ក្លាយជាមិត្តនឹងគ្នា និងរៀនពីគ្នាទៅវិញទៅមក ដោយសារកុមារមិនពិការអាចជួយកុមារពិការបាន។ នៅក្នុងថ្នាក់សមាហរណកម្មកុមារទាំងអស់ជាកុមារពិការ។ កុមារដែលពិការភ្នែកអាចទទួលបានចំណេះដឹងតាមរយៈការស្ទាបរូបភាព។ ដូច្នេះការដាក់កុមារពិការភ្នែកនៅក្នុងថ្នាក់មួយឱ្យរៀនប្រើឧបករណ៍ស្ទាប គឺជាដំណោះស្រាយល្អ។ ដូចគ្នានេះដែរកុមារកុមារថ្លង់អាចទទួលចំណេះដឹងពីការរៀនភាសាសញ្ញាពួកគេត្រូវបានដាក់ឱ្យរៀននៅថ្នាក់ជាមួយគ្នាផងដែរ។

## ២. ៥. ៤ ការធានាថាកុមារពិការបានចូលរួមគ្រប់សកម្មភាព

ការបង្រៀនដែលឱ្យកុមារពិការទាំងអស់បានចូលរួមគ្រប់សកម្មភាពធ្វើឱ្យពួកគេគិតថា ពួកគេក៏ជាសមាជិកម្នាក់នៅក្នុងថ្នាក់រៀនមួយដែរ។ កុមារមិនពិការនឹងទទួលយកកុមារពិការធ្វើជាមិត្តប្រសិនបើកុមារពិការចូលរួមសកម្មភាពនៅក្នុងថ្នាក់រៀន។ ឧទាហរណ៍ កុមារមិនពិការ និងកុមារពិការបានឆ្លើយនឹងសំណួររបស់គ្រូជាមួយគ្នា។

ប្រសិនបើអ្នកមិនច្បាស់ថាតើកុមារពិការអាចឆ្លើយបានឬមិនបាន សូមចាប់ផ្ដើមដោយសួរសំណួរងាយៗជាមុនសិនដូចដែលអ្នកបានធ្វើជាមួយកុមារដទៃ។ កុមារមានទំនុកចិត្តពេលណាគេអាចនឹងឆ្លើយសំណួរកាន់តែពិបាកបន្ថែមទៀតនៅពេលដែលអ្នកដឹងថាគេអាចឆ្លើយបាន(ក្រសួង អយក, ២០១៨) ។

ក្នុងករណីគ្រូឱ្យកុមារធ្វើកិច្ចការនៅលើក្ដាខៀនត្រូវហៅកុមារពិការផង បើកុមារពិការត្រូវការអ្នកជូនមកក្ដាខៀន អ្នកត្រូវរកមិត្តរួមថ្នាក់ជាជំនួយ។

វិធីច្រើនយ៉ាងដែលត្រូវផ្លាស់ប្ដូរសកម្មភាពមួយចំនួនដើម្បីឱ្យកុមារពិការអាចចូលរួមបានដូចជា៖

- ពេលដែលកុមារមិនពិការធ្វើកិច្ចការនៅលើក្ដាខៀន អ្នកអាចឱ្យកុមារពិការប្រាប់ចម្លើយផ្ទាល់មាត់នៅនឹងកន្លែង។
- ប្រសិនបើកុមារពិការមានការលំបាកក្នុងការគូរ គូស ឬគូរ គូសឃើត គ្រូបង្រៀនត្រូវដាក់សំណួរឱ្យឆ្លើយ២ ឬ៣តិចជាងកុមារដទៃទៀត។

- ប្រសិនបើអ្នកឱ្យកុមារប្រាប់អ្វីដែលអ្នកគូរ គូសលើក្ដារខៀន ហើយមានកុមារម្នាក់ដែលលំបាកក្នុងការនិយាយគ្រូគួរឱ្យកុមារនោះមកកាន់ក្ដាខៀន រួចចង្អុលរូបឱ្យកុមារដទៃទៀតនៅក្នុងថ្នាក់ថាតាម (ក្រសួង អយក, ២០១៨)។

## ២.៥.៥ ការសហការរវាងគ្រូ គ្រួសារ និងសហគមន៍

មានតែក្រុមគ្រួសារទេដែលស្គាល់កុមារច្បាស់។ ឪពុក ម្ដាយត្រូវដឹងពីចំណុចខ្លាំង និងចំណុចខ្សោយរបស់កុមារ ចំណែកឯគ្រូបង្រៀនវិញបានត្រឹមតែជួយឱ្យកុមារសិក្សាជំនាញផ្សេងៗប៉ុណ្ណោះ(ក្រសួង អយក, ២០១៧)។

ការចំណាយពេលវេលាខ្លះជាមួយឪពុកម្ដាយ គឺដើម្បីស្វែងយល់ពីកុមារ និងជួយគ្រូបង្រៀនបានច្រើននៅពេលបង្រៀន។

ការផ្ដល់ព័ត៌មានដល់មាតាបិតាសិស្សអំពីលទ្ធផលសិក្សារបស់សិស្ស មានសារៈសំខាន់ណាស់ ព្រោះមាតាបិតាអាចមានមោទនភាពចំពោះអ្វីដែលកូនខ្លួនសម្រេចបាន ហើយគាត់អាចជួយផ្ដល់ឱកាសដល់កូនរបស់គាត់ឱ្យប្រើប្រាស់បំណិនថ្មីនៅផ្ទះផងដែរ(ក្រសួង អយក, ២០១៨)។

## ២.៥.៦ ការបណ្ដុះបណ្ដាល និងបំប៉នគ្រូបង្រៀនកុមារពិការ

គ្រូបង្រៀនត្រូវការបណ្ដុះបណ្ដាលដើម្បីបង្រៀនកុមារនៅក្នុងការងារអប់រំទូទៅ។ ដូចគ្នានេះដែរគ្រូបង្រៀនក៏ត្រូវការការបណ្ដុះបណ្ដាលផងដែរដើម្បីបង្រៀនកុមារពិការ។ ការបណ្ដុះបណ្ដាលជាមូលដ្ឋានដើម្បីលើកកម្ពស់ការយល់ដឹងអំពីពិការភាពទស្សនៈការអប់រំបរិយាបន្ន និងប្រភេទពិការផ្សេងៗ ព្រមទាំងផ្ដល់វិធីសាស្ត្រទូទៅសម្រាប់ការបង្រៀនកុមារពិការនៅក្នុងថ្នាក់រៀន។ គ្រូបង្រៀនខ្លះនឹងទទួលការបណ្ដុះបណ្ដាលពិសេសដើម្បីបង្រៀនកុមារដែលត្រូវការរៀនបំណិនជាក់លាក់ ដែលមិនមានក្នុងការបង្រៀននៅថ្នាក់ទូទៅ(ក្រសួង អយក, ២០១៨)។ បំណិនទាំងនេះរួមមាន៖

- ការបណ្ដុះបណ្ដាលពីអក្សរប្រៃយ៍ និងការបណ្ដុះបណ្ដាលពីការតម្រង់ទិស និងបន្លាស់ទីសម្រាប់បង្រៀនកុមារពិការភ្នែក។
- ការបណ្ដុះបណ្ដាលពីការអប់រំកុមារថ្លង់ និងភាសាសញ្ញាកម្ពុជា គឺសម្រាប់បង្រៀនកុមារថ្លង់
- បណ្ដុះបណ្ដាលពីការអប់រំពិសេសសម្រាប់បង្រៀនកុមារដែលមានបញ្ហាបញ្ញាផងដែរ។ (ក្រសួង អយក, ២០១៨)

## ២.៦ តួនាទីគ្រូបង្រៀនក្នុងការរៀបចំសាលារៀនអប់រំបរិយាបន្ន

គ្រូបង្រៀនមានតួនាទីសំខាន់ណាស់ក្នុងការធានាឱ្យមានការអប់រំបរិយាបន្នប្រកបដោយគុណភាព និងប្រសិទ្ធភាព។ គ្រូបង្រៀនត្រូវមានឆន្ទៈទទួលយកការកុមារពិការ និងគិតពីតម្រូវការរបស់កុមារ រៀបចំផែនការ និងរៀបចំថ្នាក់រៀន។ គ្រូបង្រៀនជាគំរូល្អដល់សិស្ស។ កុមារមិនពិការត្រូវទទួលយក និងបង្ហាញនូវការគោរពចំពោះកុមារពិការដោយសារកុមាររៀនតាមឥរិយាបថវិជ្ជមានរបស់គ្រូបង្រៀន(ក្រសួង អយក, ២០១៨)។

**តួនាទីគ្រូបង្រៀនក្នុងការរៀបចំសាលារៀនអប់រំបរិយាបន្ន**

គ្រូបង្រៀនមានតួនាទីសំខាន់ណាស់ក្នុងការអនុវត្តការអប់រំបរិយាបន្នដោយជោគជ័យ។ ដោយមានការគាំទ្រពីនាយកសាលា គ្រូបង្រៀនអាចជួយរៀបចំសាលារៀន ដើម្បីទទួលស្វាគមន៍កុមារគ្រប់ៗគ្នា។ គ្រូបង្រៀនអាចៈ

- ***ស្វែងរកការគាំទ្រៈ*** គឺជាការនិយាយ ឬប្រព្រឹត្តជួសមុខឱ្យកុមារពិការ ដើម្បីធានាថាសិទ្ធិកុមារត្រូវបានការពារ។
- ***ដើរតួនាទីជាគំរូៈ*** គឺជាការប្រើឥរិយាបថ អាកប្បកិរិយាផ្ទាល់ខ្លួនបង្ហាញវិធីការពារសិទ្ធិកុមារ និងធានាសិទ្ធិរបស់ពួកគេត្រូវបានការពារ(ក្រសួង អយក, ២០១៨) ។

## ២. ៦. ១ ការបង្កលក្ខណៈឱ្យសិស្សមានពិការភាពមករៀន

### ២. ៦. ១. ១ តួនាទីស្វែងរកការគាំទ្រ

ក្នុងនាមអ្នកស្វែងរកការគាំទ្រ គ្រូក៏ជាសមាជិកគណៈកម្មការទ្រទ្រង់សាលារៀន ហើយបានជួយធ្វើផែនទីខ្នងផ្ទះផងដែរ។ ការងារនេះផ្តល់ព័ត៌មានអំពីចំនួនកុមារដែលដល់អាយុចូលរៀនក្នុងសាលារៀន តើមានកុមារប៉ុន្មាននាក់បានទៅសាលារៀន និងប៉ុន្មាននាក់មិនទៅសាលារៀន ហើយមានមូលហេតុអ្វី(ក្រសួង អយក, ២០១៨)។

ដូច្នេះគ្រូបង្រៀនត្រូវជួយពន្យល់ពីសារប្រយោជន៍នៃការអប់រំ និងលើកទឹកចិត្តក្រុមគ្រួសារឱ្យបញ្ជូនកូនទៅសាលារៀន ដោយមានកិច្ចសហការពីគណៈកម្មការទ្រទ្រង់សាលារៀន ប្រធានភូមិ និងអាជ្ញាធរដែនដី។ កុមារមួយចំនួនមិនបានទៅរៀនពីព្រោះពួកគេក្រីក្រពេក មិនចេះនិយាយភាសាខ្មែរ រស់នៅឆ្ងាយពីសាលារៀន ត្រូវជួយធ្វើការងារក្នុងក្រុមគ្រួសារអាយុច្រើនពេក ឬមានភាពពិការ។ ប្រសិនបើកុមារមិនទៅសាលារៀនដោយសារភាពពិការនោះគ្រូបង្រៀន និងគណៈកម្មការទ្រទ្រង់សាលារៀនអាចជួយតាមវិធីដូចខាងក្រោមៈ

- ពិនិត្យបញ្ជីកំណត់អត្តសញ្ញានប្រភេទពិការ។
- ជម្រាបឪពុកម្ដាយ ឬអាណាព្យាបាលពីគោលនយោបាយជាតិដែលធានាថា កុមារពិការទាំងអស់ទទួលបានការអប់រំ និងអាចទទួលបានផលប្រយោជន៍ពីការអប់រ ទោះបីមានភាពពិការក៏ដោយ។ លើកទឹកចិត្តឪពុកម្ដាយ អាណាព្យាបាលឪបញ្ជូនកូនទៅរៀនសហការជាមួយអង្គការជនពិការ ដើម្បីទទួលបានព័ត៌មាន និងការគាំទ្រៗ ។ល។
- រិះរកវិធីជួយកុមារពិការដែលត្រូវការការគាំទ្រដើម្បីបានទៅរៀន។
- ធ្វើទំនាក់ទំនងជាមួយអង្គការ ស្ថាប័នផ្សេងៗ ដែលអាចផ្តល់ធនធានតាមត្រូវការរបស់កុមារ ដើម្បីឱ្យគេអាចមករៀន។
- ធានាថាគ្រូបង្រៀនក្នុងថ្នាក់ដែលមានកុមារពិការ ត្រូវបានទទួលការបណ្តុះបណ្តាលផ្នែកការអប់រំបរិយាបន្នមុនការចូលរៀនរបស់កុមារពិការ(ក្រសួង អយក, ២០១៨)។

| **តើកុមារពិការត្រូវការជំនួយអ្វីខ្លះ?** | **តើអ្វីខ្លះដែលអាចធ្វើបាន?** |
|---|---|
| **កុមារមានបញ្ហាចលនា** | |
| ប្រសិនបើដឹងថា កុមារត្រូវការអវៈយវៈសិប្បនិម្មិត ឧបករណ៍ទ្រទ្រង់អវៈយវៈ រទេះរុញ ការព្យាបាល ឬការវះកាត់ | សូមធ្វើទំនាក់ទំនងភ្នាក់ងារណាមួយដើម្បីដឹងថាកុមារមានបញ្ហាចលនាត្រូវការឧបករណ៍ជំនួយឬអ្នកជាចឱ្យឪពុកម្តាយឬអាណាព្យាបាលទៅមន្ទីរពេទ្យបង្អែកតាមមូលដ្ឋាន។ |
| ប្រសិនបើកុមារត្រូវការរទេះរុញ | សាលារៀនត្រូវមានជម្រាល(ស្តង់ដា កម្ពស់១០សង់ទីម៉ែត្រ ប្រវែង ១.២ម៉ែត្រ) ដើម្បីសម្រួលការចេញចូលរបស់កុមារក្នុងអគារ សាលារៀន និងថ្នាក់រៀន។ ប្រសិនបើសាលារៀនគ្មានជម្រាល គ្រូបង្រៀនអាចស្នើនាយក នាយិកាសាលាប្រើកញ្ចប់ថវិកាវដ្តដើម្បីសង់ជម្រាល ឬស្នើសមាជិកសហគមន៍បរិច្ចាគថវិកាសាងសង់ជម្រាល តាមរយៈគណៈកម្មការទ្រទ្រង់សាលារៀន។ ជម្រាលឫស្សី មិនត្រូវការចំណាយច្រើនទេ និងអាចប្រើប្រាស់រហូតដល់រយៈពេល២ឆ្នាំ។ ជម្រាលបេតុងត្រូវការចំណាយច្រើន ប៉ុន្តែប្រើបានយូរ។ ករណីខ្លះអ្នកអាចទាក់ទងអង្គការផ្សេងៗដូចជាអង្គការ កម្ពុជាត្រាសដែលនឹងសង់ជម្រាលជូនដោយឥតគិតថ្លៃ។ |
| ប្រសិនបើកុមារត្រូវការជិះរទេះរុញទៅសាលារៀន | បំផុសនិងលើកទឹកចិត្តមិត្តរួមថ្នាក់ ឬសិស្សធំៗនៅបឋមសិក្សាឱ្យជួយ។ នៅសាលារៀន នាយកសាលា ឬនាយិកាសាលាដាក់កុមារពិការឱ្យជិះមកជាមួយ ទាំងទៅទាំងមក។ រទេះរុញរបស់កុមារនោះទុកនៅសាលារៀន។ ករណីខ្លះអង្គការផ្សេងៗអាចនឹងផ្តល់ជូនមធ្យោបាយធ្វើដំណើរ ឬរៀបចំរទេះរុញចំនួនពីរ។ |
| **កុមារមានបញ្ហាមើល** | |
| ប្រសិនបើដឹងថាកុមារមានបញ្ហាមើលនោះ កុមារអាចត្រូវការវ៉ែនតា កែវពង្រីង ការព្យាបាល ឬការវះកាត់ | សូមធ្វើការទំនាក់ទំនងទីភ្នាក់ងារណាមួយដែលអាចជួយ និងដើម្បីឱ្យដឹងថាមានកុមារមានបញ្ហាមើលត្រូវការឧបករណ៍ជំនួយ ឬអាណាព្យាបាលអាចនាំកុមារទៅរកសេវាព្យាបាលបានត្រឹមត្រូវ។ |
| ប្រសិនបើកុមារត្រូវការយានជំនិះទៅសាលារៀន ដោយសារគេមិនអាចទៅសាលារៀនដោយខ្លួនឯង | បំផុសលើកទឹកចិត្តកុមារអាយុច្រើនជាងឱ្យជួយ។ |
| ប្រសិនបើកុមារងងឹងភ្នែកទាំងស្រុងត្រូវការរៀនអក្សរប្រៃយ៍ ស្លេត និងស្តាយឡាស | សូមទំនាក់ទំនងវិទ្យាស្ថានជាតិអប់រំពិសេស និងវិទ្យាល័យអប់រំពិសេសទាំង៥ ដែលនៅជិត។ |

| | |
|---|---|
| **កុមារមានបញ្ហាស្តាប់** | |
| ប្រសិនដឹងថាកុមារមានបញ្ហាស្តាប់ កុមារអាចត្រូវការឧបរកណ៍ជំនួយការស្តាប់ | សូមទំនាក់ទំនងទីភ្នាក់ងារណាមួយដែលអាចដឹងថាកុមារមានបញ្ហាស្តាប់ត្រូវការឧបករណ៍ជំនួយ ឬអាណាព្យាបាលអាចនាំកុមារទៅរកមន្ទីរពេទ្យដែលមានឯកទេសបានត្រឹមត្រូវ។ |
| ប្រសិនកុមារមានបញ្ហាស្តាប់កម្រិតធ្ងន់ ឬមិនអាចស្តាប់បានទាំងស្រុង ដែលតម្រូវឱ្យកុមាររៀនភាសាសញ្ញា | សូមទំនាក់ទំនងវិទ្យាស្ថានជាតិអប់រំពិសេស និងវិទ្យាល័យអប់រំពិសេសទាំង៥ ដែលនៅជិត។ |
| **កុមាមានបញ្ហានិយាយ** | |
| ប្រសិនបើដឹងថាកុមារមានបញ្ហានិយាយ នោះកុមារត្រូវការធ្វើលំហាត់និយាយ ឬអាចកុមារអាចត្រូវការវះកាត់ | មន្ទីរពេទ្យបង្អែកណាមួយមានសេវាគាំទ្រលើបញ្ហានេះ វិទ្យាស្ថានជាតិអប់រំពិសេស អង្គការដៃគូនានាដែលធ្វើការងារនេះ ។ |
| **កុមារមានបញ្ហាសតិបញ្ញា** | |
| ប្រសិនបើដឹងថាកុមារមានបញ្ហាសតិបញ្ញា | សូមធ្វើការទំនាក់ទំនងមន្ទីរពេទ្យបង្អែក ឬអង្គការណាមួយដែលអាច ផ្តល់ការគាំទ្រ ប្រឹក្សាយោបល់ និងសេវាព្យាបាល។ |

(ក្រសួង អយក, ២០១៨)

## ២.៦.១.២ តួនាទីជាគំរូ

ក្នុងនាមជាអ្នកគំរូ គ្រូបង្រៀនត្រូវៈ

- ចុះសួរសុខទុក្ខ និងចងមិត្តភាពជាមួយក្រុមគ្រួសារកុមារនៅតាមសហគមន៍។ ក្រុមគ្រួសារមួយចំនួនហាក់ដូចជាស្ថិតនៅដាច់ដោយឡែក នៅពេលដែលមានកូនពិការ ពីព្រោះជួនកាលក្រុមគ្រួសារដទៃមិនសួរពីសុខទុក្ខ ឬអញ្ជើញពួកគេចូលរួមក្នុងពិធីផ្សេងៗនោះទេ។
- ចូលរួមក្នុងយុទ្ធនាការប្រមូលកុមារចូលរៀន និងផ្តល់ឱកាសដល់ក្រុមគ្រួសារដែលមានកូនពិការគ្រប់អាយុឱ្យមកចុះឈ្មោះចូលរៀនបានមុនគេ។ សកម្មភាពនេះក៏លើកទឹកចិត្តផងដែរដល់បុគ្គលិកសាលារៀនទាំងអស់ឱ្យចូលរួមផ្សព្វផ្សាយការអនុវត្តអប់រំបរិយាបន្ន ចៀសវាងការទទួលសុខត្រូវរបស់គ្រូម្នាក់ ឬពីរនាក់។
- ជួបគ្រួសារកុមារពិការដែលរៀននៅក្នុងថ្នាក់ និងមានទំនាក់ទំនងជាមួយពួកគេ។
- ទទួលយកកុមារពិការឱ្យចូលរៀននៅក្នុងថ្នាក់រៀន និងស្ម័គ្រចិត្តចូលរួមវគ្គបណ្តុះបណ្តាលការអប់រំបរិយាបន្ន(ក្រសួង អយក, ២០១៨) ។

### ២. ៦. ២ ការជួយកាត់បន្ថយការរើសអើងចំពោះកុមារពិការ

គ្រូបង្រៀនអាចជួយប្តូរអាកប្បកិរិយាមិនល្អរបស់កុមារមិនពិការមកលើកុមារពិការ

#### ២. ៦. ២. ១ តួនាទីស្វែងរកការគាំទ្រ

ក្នុងនាមជាអ្នកស្វែងរកការគាំទ្រ គ្រូបង្រៀនត្រូវ៖

១. រារាំង និងបញ្ឈប់កុមារមិនពិការ ឬគ្រូដទៃទៀតនិយាយ សម្លុត ឬស្តែងចេញជាអំពើហិង្សាចំពោះកុមារពិការ។

២. សុំថ្នាក់រៀននៅជាន់ខាងក្រោមដើម្បីឱ្យកុមារមានបញ្ហាចលនាមិនចាំបាច់ឡើងជណ្តើរ។

៣. ជ្រើសរើសកុមារស្ម័គ្រចិត្តមិនពិការចំនួន៤ ឬ៥នាក់សម្រាប់ជួយកុមារពិការនៅតាមសួនកុមារជូនទៅបង្គន់អនាម័យ ឬកន្លែងបរិភោគអាហារ។

៤. បង្កើតល្បែង និងបង្កឱកាសឱ្យកុមារពិការ និងមិនពិការក្លាយជាមិត្តភ័ក្តនឹងគ្នា។ អាចដឹងពីបញ្ហាបន្ថែមដែលកុមារពិការប្រឈម និងសហការជាមួយគណៈកម្មការទ្រទ្រង់សាលារៀនរៀបចំបង្គន់អនាម័យឱ្យមានជម្រាល និងបង្កាន់ដៃដើម្បីបង្កលក្ខណៈងាយស្រួល។ គ្រូបង្រៀនអាចនិយាយជាមួយនាយក នាយិកាសាលា ដើម្បីធានាថា បង្គន់សម្រាប់កុមារីពិការប្រើប្រាស់មានលក្ខណៈងាយស្រួល។

#### ២. ៦. ២. ២ តួនាទីគំរូ

ក្នុងនាមជាអ្នកគំរូ គ្រូបង្រៀនត្រូវ៖

១. ប្រព្រឹត្តជាមួយកុមារពិការដោយការគោរព។

២. ចៀសវាងការសម្លុត ស្តែងចេញជាអំពើហិង្សា បន្ទាប ឬសើចចំអកដល់កុមារពិការឡើយ ជាពិសេសនៅពេលពួកគេមានការពិបាកក្នុងការធ្វើសកម្មភាពអ្វីមួយដោយសារភាពអន់ខ្សោយរបស់កគេ។

៣. និយាយជាមួយកុមារពិការដោយប្រើភាសាសមរម្យចៀសវាងប្រើឈ្មោះប្រភេទនៃភាពពិការ។

៤. ជជែកលេងជាមួយកុមារពិការនៅក្នុងសាលារៀន

៥. ឱ្យកុមារពិការចូលរួមគ្រប់សកម្មភាពរបស់សាលារៀន(ក្រសួង អយក, ២០១៨)។

### ២. ៧- តួនាទីគ្រូបង្រៀនក្នុងការរៀបចំថ្នាក់រៀនបរិយាបន្ន

គ្រូបង្រៀនក៏អាចរៀបចំថ្នាក់រៀនអប់រំបរិយាបន្ន ដើម្បីទទួលយកកុមារពិការដែរ។ គ្រូគឺជាគំរូដល់កុមារ។ ប្រសិនបើគ្រូបង្ហាញការគោរព និងការទទួលយកកុមារពិការនោះកុមារមិនពិការក៏ធ្វើដូចដែរ។ កុមារមិនពិការនឹងមិនសើចចំអកកុមារពិការ ហើយផ្ទុយទៅវិញពួកគេនឹងក្លាយជាមិត្តភក្តិ។ វិធីនេះនឹងបង្កើតបានជាបរិយាបកាសមានការគោរព និងស្វាគមន៍គ្នាដែលផ្តល់ប្រយោជន៍ដល់កុមារគ្រប់ៗគ្នា។ កុមារទាំងអស់គឺជាអ្នកដឹកនាំនៅពេលអនាគត។ អ្វីដែលគេរៀននៅថ្ងៃនេះ គេនឹងអនុវត្តក្នុងជីវិតរស់នៅនាពេលអនាគត។ គ្រូបង្រៀនអាចរៀបចំកុមារថ្នាក់អប់រំបរិយាបន្នទាំងអស់ ឱ្យមានអាកប្បកិរិយាវិជ្ជមាន។ ការប្រើប្រាស់បំណិនគ្រប់គ្រងថ្នាក់រៀនបានល្អ មានសារៈសំខាន់ណាស់ក្នុងការយល់ដឹងពីភាពខុសគ្នារវាងការរៀបចំថ្នាក់រៀន និងការគ្រប់គ្រងកុមារ(ក្រសួង អយក, ២០១៨)។

## ២.៧.១ អាកប្បកិរិយាវិជ្ជមាន

ការឱ្យកុមារពិការមួយ ឬពីរនាក់នៅក្នុងថ្នាក់ដែលមានកុមារមិនពិការចំនួន៥០នាក់ ហាក់ដូចជាបន្ថែមការទទួលខុសត្រូវចំពោះគ្រូបង្រៀន។ គ្រូអាចឆ្លើយតបនឹងតម្រូវការរបស់កុមារម្នាក់ និងតម្រូវការរបស់កុមារទាំងអស់ដោយទន់ភ្លន់ និងប៉ិនប្រសប់ ដើម្បីឱ្យគេប្រើប្រាស់ធនធានដែលមានប្រកបដោយប្រសិទ្ធភាព។

ក្នុងនាមជាអ្នកស្វែងរកការគាំទ្រ គ្រូបង្រៀនត្រូវ៖

• ប្រើវិធីបង្រៀន "មិត្តជួយមិត្ត" និងជ្រើសរើសកុមារមិនពិការស្ម័គ្រចិត្តនៅក្នុងថ្នាក់ ឬកុមារវៃឆ្លាតនៅក្នុងសាលារៀនឱ្យជួយកុមារពិការ។ កិច្ចការនេះអាចជាការអានសង្កេតរូបភាពជូនកុមារមានបញ្ហាចលនា ឬបញ្ហាមើលទៅបង្គន់អនាម័យ ហើយអាចឱ្យកុមារវៃឆ្លាតចូលរួមជួយកុមារពិការដោយណែនាំពីរបៀបលេង និងការលេងសម្ភារៈផ្សេងៗ។

• ស្នើឱ្យមានវគ្គបណ្តុះបណ្តាលផ្នែកអប់រំបរិយាបន្ន ឬជំនាញពិសេសដូចជា អក្សរប្រៃយ៍ និងភាសាសញ្ញា ជាដើម។

• ជួបជាមួយគ្រូដទៃទៀតដោយទៀងទាត់ដើម្បីពិភាក្សាបញ្ហាទាំងឡាយ និងបង្កើតទំនុកចិត្តលើសមត្ថភាពរបស់ខ្លួន។ ការពិភាក្សាពីបញ្ហាផ្សេងៗ ក្នុងពេលបម្រើការងារជាគ្រូបង្រៀនគឺមានប្រសិទ្ធភាពជាការស្ថិតនៅជាគុរុសិស្សដែលមានតែទ្រឹស្តី។

• អញ្ជើញសមាជិករបស់អង្គការជនពិការ ឬជនពិការដែលមានស្នាដៃ និងបទពិសោធនមកកាន់ថ្នាក់រៀន ដើម្បីធ្វើជាវាគ្មិន។ ការធ្វើជាគំរូល្អ ជួយឱ្យកុមារពិការមានទំនុកចិត្តលើខ្លួនឯង និងជួយឱ្យកុមារមិនពិការដឹងថាជនពិការក៏មានលទ្ធភាព និងសមត្ថភាពផងដែរ។

ក្នុងនាមជាគំរូ គ្រូបង្រៀនត្រូវ៖

- ចាំថាកុមារទាំងអស់រួមទាំងកុមារពិការ មានសិទ្ធិទទួលបានការអប់រំ
- ចងចាំថា កុមារទាំងអស់ រួមទាំងកុមារពិការ មានសមត្ថភាពក្នុងការរៀន ហើយវាជាការទទួលខុសត្រូវរបស់គ្រូបង្រៀនដែលត្រូវដឹង។
- អនុវត្តគោលវិធីកុមារ សិស្សមជ្ឈមណ្ឌលឱ្យកាន់តែសកម្ម។
- ចងចាំថាកុមាររៀនតាមកម្រិត និងវិធីខុសគ្នា។
- អាចផ្តល់ឱកាសដល់កុមារពិការចូលរួមទទួលខុសត្រូវក្នុងការដឹកនាំសកម្មភាពជាក្រុមតូច នៅក្នុងថ្នាក់រៀន។
- បង្កើតឱ្យមានការប្រាស្រ័យទាក់ទងល្អជាមួយក្រុមគ្រួសារកុមារពិការដើម្បីផ្តល់ការគាំទ្របន្ថែមទៀតក្នុងករណីចាំបាច់(ក្រសួង អយក, ២០១៨)។

## ២.៧.២ ការរៀបចំថ្នាក់រៀនឱ្យបានល្អ

ក្រៅពីមានអាកប្បកិរិយាបើកទូលាយ និងសមរម្យចំពោះកុមារពិការ គ្រូបង្រៀនអាចរៀបចំថ្នាក់រៀន និងជួយសម្រួលបន្ថែមទៀតដល់កុមារទាំងអស់ឱ្យមានមិត្តភាព និងការសិក្សាប្រកបដោយប្រសិទ្ធភាព។ ពេលអ្នករៀបចំតុ កៅអីក្នុងថ្នាក់រៀន សូមយកចិត្តទុកដាក់លើទីតាំងដែលអ្នកឱ្យកុមារពិការអង្គុយឱ្យស្របតាមកម្រិត និងប្រភេទពិការរបស់គេ។ ឧ. ចំពោះកុមារដែលមានបញ្ហាមើលមួយចំនួនត្រូវឱ្យអង្គុយក្បែរបង្អួចមានពន្លឺ។

កុមារពិការដែលប្រើទេះរុញ ត្រូវអង្គុយនៅជួរមុខជិតច្រកទ្វារដើម្បីងាយស្រួលធ្វើដំណើរចេញចូល។ កុមារមានបញ្ហាស្ដាប់ត្រូវឱ្យអង្គុយនៅខាងមុខជិតគ្រូ។

ពេលគ្រូធ្វើកិច្ចតែងការបង្រៀនត្រូវគិតថា ពេលណាគួរដាក់សកម្មភាពឱ្យកុមារធ្វើការងារជាក្រុមតូច ធំ ឬបុគ្គល។ ទន្ទឹមនឹងនោះដែរ គ្រូត្រូវពិចារណាលើការរៀបចំសកម្មភាពសមស្របសម្រាប់កុមារពិការ។

ពេលបង្រៀនមេរៀនដល់កុមារទាំងអស់ គ្រូត្រូវនៅទល់មុខកុមារគ្រប់ពេលដើម្បីជួយដល់កុមារមានបញ្ហាស្ដាប់ឱ្យបានឮកាន់តែច្បាស់ពីអ្វីដែលគ្រូបាននិយាយ។ ប្រសិនបើគ្រូសួរសំណួរ សូមសួរសំណួរម្ដងហើយម្តងទៀតដើម្បីឱ្យកុមារដែលមានបញ្ហាស្ដាប់បានឮអ្វីដែលគ្រូសួរ និងអាចឆ្លើយបាន។ ពេលគ្រូឱ្យកុមារធ្វើការងារជាក្រុមតូចៗ សូមបែងចែកកុមារពិការនៅគ្រប់ក្រុម ដូច្នេះក្រុមនីមួយៗ មានតែកុមារពិការម្នាក់តែប៉ុណ្ណោះ។ វិធីបែបនេះកុមារមិនពិការអាចមានឱកាសធ្វើសកម្មភាពជាមួយកុមារពិការ ហើយអាចជួយកុមារពិការផងដែរបើចាំបាច់(ក្រសួង អយក, ២០១៨)។

### ២.៧.២ ការគ្រប់គ្រងឥរិយាបថកុមារ

ឥរិយាបថកុមារអាចគ្រប់គ្រងតាមវិធីច្រើនបែបដូចជា៖

- ការគ្រប់គ្រងឥរិយាបថកុមារតាមរយៈរង្វាន់
- ការគ្រប់គ្រងឥរិយាបថកុមារតាមរយៈផែនការវិន័យ(ក្រសួង អយក, ២០១៨)។

## ២.៨ ផែនការអប់រំសម្រាប់កុមារ

### ២.៨.១ ការប្រមូលព័ត៌មាន

- មើលឡើងវិញនូវរាល់ព័ត៌មានរបស់កុមារពិការ (ចំណុចខ្លាំង ចំនុចខ្សោយរបស់កុមារ)
- ធ្វើការអង្កេតចំពោះកុមារពិការ
- មើលការរៀនបច្ចុប្បន្នរបស់កុមារនៅក្នុងថ្នាក់
- បូកសរុបព័ត៌មានរបស់កុមារ(ក្រសួង អយក, ២០១៨)។

### ២.៨.២ ការប្រឹក្សាជាមួយដៃគូពាក់ព័ន្ធ

- ធ្វើការពិភាក្សាជាមួយមាតាបិតា អាណាព្យាបាល ឬអ្នកថែទាំកុមារដើម្បីមានការចូលរួម(ឪពុក ម្តាយ អាណាព្យាបាល ឬអ្នកថែទាំ)
- ពិភាក្សាជាមួយគ្រូដទៃនៅក្នុងសាលា ឬជាមួយអ្នកជំនាញដើម្បីជួយកុមារ(ក្រសួង អយក, ២០១៨)។

### ២.៨.៣ ធ្វើផែនការអប់រំសម្រាប់បុគ្គល

- រកមើលចំណុចខ្លាំងរបស់កុមារពិការ តម្រូវការ និងការចូលចិត្តរបស់គេ
- កំណត់គោលដៅ និងការរំពឹងទុកជាមួយមេរៀន (តើអាចជួយកុមារពិការបានអ្វីខ្លះ?)
- កំណត់តម្រូវការសម្រាប់ការអប់រំ (មេរៀន បរិយាកាស ការគាំទ្រ និងធនធាន) (ក្រសួង អយក, ២០១៨)។

**២. ៨. ៤ ការអនុវត្តផែនការអប់រំសម្រាប់បុគ្គល**

- សរសេរបញ្ចូលព័ត៌មានក្នុងទម្រង់ផែនការ
- អនុវត្តកម្មវិធីតាមការបង្រៀន
- តាមដានការរីកចម្រើនរបស់កុមារ
- ធ្វើការកែតម្រូវគោលដៅ ការរំពឹងទុក យុទ្ធវិធី និងការកែប្រែផ្សេងៗ(ក្រសួង អយក, ២០១៨) ។

**២. ៨. ៥ ការមើលផែនការឡើងវិញ និងការរកវិធីសាស្ត្រកែប្រែថ្មី**

- បង្ហាញលទ្ធផលការសិក្សារបស់កុមារពិការ
- កែប្រែផែនការអប់រំបន្តជាមួយការគាំទ្រពីផ្នែកអប់រំ និងដៃគូពាក់ព័ន្ធ
- កំណត់ពេលវេលាសម្រាប់ការជួយកុមារបើមានតម្រូវការ(ក្រសួង អយក, ២០១៨) ។

# ជំពូកទី៣
# វិធីសាស្ត្រនៃការស្រាវជ្រាវ

## ៣. ១ ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ

ការស្រាវជ្រាវនេះ ត្រូវបានរៀបចំធ្វើឡើងដោយប្រើទិន្នន័យបរិមាណវិស័យ និងគុណវិស័យដែលបានយកមកវិភាគ ដើម្បីស្វែងការអប់រំប្រែកបដោយបរិយាបន្នទៅលើកុមារពិការនៅកម្ពុជា នៅតាមវិទ្យាល័យអប់រំពិសេសទាំង៥ ភ្នំពេញថ្មី ច្បារអំពៅ កំពង់ចាម បាត់ដំបង និងសៀមរាប។

## ៣. ២ ទីកន្លែងស្រាវជ្រាវ

ការសិក្សានេះ ជ្រើសរើសយករាជធានី ខេត្តចំនួន៥ ដែលជាទីតាំងសម្រាប់ធ្វើការប្រមូលទិន្នន័យ។ ដូចដែលបានរៀបរាប់ក្នុងគោលបំណងនៃការស្រាវជ្រាវ នឹងសិក្សាអំពីប្រសិទ្ធភាពនៃការអប់រំប្រែកបដោយ បរិយាបន្នដែលបានអនុវត្តល្អៗ និងបញ្ហាប្រឈមនានាដែលមានការលំបាកក្នុងការផ្តល់សេវាអប់រំកុមារមានពិការភាពនៅវិទ្យាល័យអប់រំពិសេសទាំង៥ និងដើម្បីអាចរកជាយុទ្ធសាស្ត្រទៅរកការអនុវត្តការអប់រំបរិយាប្ន នៅសាលារៀនចំណេះទូទៅនៅប្រទេសកម្ពុជា។

ដោយផ្អែកទៅលើកត្តា ភូមិសាស្ត្រសាលា ភេទ កម្រិតនៃការអប់រំទូទៅ និងការអប់រំពិសេសជាមួយកុមារពិការ បទពិសោធន៍ សេវាគាំទ្រ និងកម្មវិធីស្ពានចម្លង និងការគាំទ្រពីសហគមន៍ អ្នកអាណាព្យាបាល វិធីសាស្ត្រស្រាវជ្រាវនេះត្រូវបានប្រើប្រាស់បែបបរិមាណវិស័យ និងគុណវិស័យព្រមទាំងបូកផ្សំជាមួយនឹងព័ត៌មានពីការអង្កេតផ្ទាល់របស់អ្នកស្រាវជ្រាវ ទៅលើស្ថានភាពជាក់ស្តែងរបស់វិទ្យាល័យអប់រំពិសេសទាំងនោះ។

## ៣. ៣ ការជ្រើសរើសសំណាក

ការសិក្សាស្រាវជ្រាវនេះត្រូវបានរៀបចំជាលក្ខណៈបរិមាណវិស័យ និងគុណវិស័យដែល មានការចូលរួមពីភាគីពាក់ព័ន្ធដូចជា នាយក គ្រូតាមជំនាញពិការ បុគ្គលិកការិយាល័យ អ្នកថែទាំក្មេង និងអ្នកផ្តល់សេវាគាំទ្រផ្សេងៗ។ ភាគសំណាកសម្រាប់ការស្រាវជ្រាវនេះរួមមាននាយក នាយិកា និងនាយករង នាយិការង សរុបចំនួន ១៤នាក់ លោកគ្រូ-អ្នកគ្រូ និងបុគ្គលិកនានា សរុប ចំនួន ១០៣នាក់ នៅតាមវិទ្យាល័អប់រំពិសេសទាំង៥ ។

| តួនាទី | ភ្នំពេញថ្មី | | | ច្បារអំពៅ | | កំពង់ចាម | | | សៀមរាប | | | បាត់ដំបង | | | | សរុបរួម | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ភេទ | | សរុប | ភេទ | | សរុប | ភេទ | | សរុប | ភេទ | | សរុប | ភេទ | | សរុបរួម | ភេទ | | សរុបរួម |
| | ប្រុស | ស្រី | | ប្រុស | ស្រី | | ប្រុស | ស្រី | | ប្រុស | ស្រី | | ប្រុស | ស្រី | | ប្រុស | ស្រី | |
| គណៈគ្រប់គ្រង | 2 | 0 | 2 | 1 | 1 | 2 | 2 | 0 | 2 | 2 | 0 | 2 | 13 | 10 | 23 | 8 | 2 | 10 |
| គ្រូទទួលបន្ទុកថ្នាក់ | 1 | 10 | 11 | 5 | 6 | 11 | 7 | 7 | 14 | 7 | 7 | 14 | 1 | 1 | 2 | 21 | 38 | 59 |
| គ្រូឯកទេសតាមមុខវិជ្ជា | 4 | 3 | 7 | 1 | 0 | 1 | 3 | 1 | 4 | 3 | 1 | 4 | 4 | 6 | 10 | 16 | 5 | 21 |
| បុគ្គលិក | 0 | 2 | 2 | 0 | 1 | 1 | 0 | 1 | 1 | 0 | 1 | 1 | 2 | 0 | 2 | 1 | 3 | 4 |
| គ្រូជំនួយ និងកិច្ចសន្យា | 1 | 2 | 3 | 1 | 0 | 1 | 1 | 0 | 1 | 1 | 0 | 1 | 1 | 0 | 1 | 2 | 2 | 4 |
| បុគ្គលិកផ្សេងៗ | 0 | 1 | 1 | 0 | | | | | | | | | 1 | 0 | 1 | 3 | 2 | 5 |
| | 8 | 18 | 26 | 8 | 8 | 16 | 13 | 9 | 22 | 13 | 9 | 22 | 9 | 7 | 16 | 51 | 52 | 103 |

## ៣. ៤ ឧបករណ៍ស្រាវជ្រាវ

ចំពោះឧបករណ៍ស្រាវជ្រាវ អ្នកសិក្សាស្រាវជ្រាវ បានរៀបចំបង្កើតកម្រងសំណួរដែលជា លក្ខណៈកម្រិតចម្លើយ និងសំណួរទម្រង់បើកសម្រាប់នាយក លោកគ្រូ អ្នកគ្រូ និងបុគ្គលិកនានា។ កម្រងសំណួរមាន២ប្រភេទត្រូវបានបង្កើតឡើងដើម្បីប្រមូលទិន្នន័យរួមមាន ៖

កម្រងសំណួរសម្រាប់នាយកសាលា សម្រាប់លោកគ្រូ អ្នកគ្រូ និងសម្រាប់បុគ្គលិកផ្សេងៗដែលចូលរួមគាំទ្រការអប់រំនៅក្នុងវិទ្យាល័យអប់រំពិសេសទាំង៥ ។ ក្នុងការសិក្សាស្រាវជ្រាវនេះ យើងប្រើប្រាស់កម្រងសំណួរចំនួន១៥ច្បាប់សម្រាប់នាយក ១០៣ច្បាប់សម្រាប់គ្រូបង្រៀន និងបុគ្គលិកសិក្សា ។ ក្នុងការបង្កើតកម្រងសំណួរនេះយើងខ្ញុំបានរៀបចំតាក់តែង ខ្លឹមសារ កម្រងសំណួរ ស្របនឹងសូចនាករសំខាន់ចំនួន៦នៃការអនុវត្តការអប់រំប្រកដោយបរិយាបន្នសម្រាប់កុមារមានពិការភាព។

## ៣. ៥ កម្រងសំណួរ និងគោលបំណងនៃកម្រងសំណួរ

### ៣. ៥. ១ កម្រងសំណួរសម្រាប់នាយក

កម្រងសំណួរសម្រាប់នាយក បែងចែកចេញជាពីរគឺ កម្រងសំណួរទម្រង់បិទ

និងកម្រងសំណួរសម្រាប់សម្ភាស ៖

**ក. កម្រងសំណួរទម្រង់បិទបែងចែកជាពីរផ្នែកគឺ៖**

- **ផ្នែកទី១** ព័ត៌មានទូទៅ

- **ផ្នែកទី២** ក.ការអនុវត្តការអប់រំប្រកបដោយបរិយាបន្ន

**ខ. កម្រងសំណួរសម្រាប់សម្ភាស** គឺចង់វាស់ស្ទង់មតិរបស់លោកនាយកពីការអនុវត្តការអប់រំចំពោះកុមារពិការ និងការប្រឈមនានា។

### ៣. ៥. ២ កម្រងសំណួរសម្រាប់គ្រូ

កម្រងសំណួរសម្រាប់នាយក បែងចែកចេញជាពីរគឺ កម្រងសំណួរទម្រង់បិទ
និងកម្រងសំណួរសម្រាប់សម្ភាស ៖
**ក. កម្រងសំណួរទម្រង់បិទបែងចែកជាពីរផ្នែកគឺ៖**

- **ផ្នែកទី១** ព័ត៌មានផ្ទាល់ខ្លួន ក្នុងផ្នែកនេះមាន៧សំណួរ ។ អ្នកស្រាវជ្រាវចង់ទីតាំងសាលា ដឹងអំពីភេទ កម្រិតវប្បធម៌ទូទៅ និងជំនាញអប់រំពិសេស បទពិសោធន៍ការងារអ្នកបំពេញកម្រងសំណួរ ។

- **ផ្នែកទី២** ការអនុវត្តការអប់រំប្រកបដោយបរិយាបន្នតាមសូចនាករចង្អុលបង្ហាញចំនួន៦ ៖

(១) ការផ្តល់សេវាគាំទ្រសមស្របដល់កុមារពិការ

(២) ការដាក់បញ្ចូលកុមារក្នុងលក្ខណៈបរិស្ថាននឹងអាយុ

(៣) ការកំណត់និយាមចំនួនគ្រូ គ្រូជំនួយ ចំនួនសិស្ស និងប្រភេទពិការ

(៤) ការសម្របសម្រួលកុមារពីសាលាពិសេសទៅសាលាទូទៅ

(៥) ការធានាថាកុមារពិការទទួលបានការចូលរួមគ្រប់សកម្មភាព

(៦) ការសហការណ៍រវាងគ្រូបង្រៀន គ្រួសារ និងសហគមន៍

**ខ. កម្រងសំណួរសម្រាប់សម្ភាស** គឺចង់វាស់ស្ទង់មតិរបស់លោកនាយកពីការអនុវត្តការអប់រំចំពោះកុមារពិការ និងការប្រឈមនានា។

## ៣. ៦ ដំណើរការប្រមូលទិន្នន័យ

បន្ទាប់ពីកម្រងសំណួរមានការឯកភាពពីគ្រូដឹកនាំ និងទទួលបានលិខិតឧទ្ទេសនាមពីវិទ្យាស្ថានជាតិអប់រំ លេខ : ១១៩ វជអ.ផក ចុះថ្ងៃ សុក្រ ១៤ កើត ខែ ពិសាខ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការចាត់តាំងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ នៃវិទ្យាស្ថានជាតិអប់រំឲ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅតាមរាជធានី ខេត្តនានា។ និងលិខិតជូនដំណឹងរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ : ១៨៨៥ អយក.វជអ ចុះថ្ងៃ ព្រហស្បតិ៍ ១៤ កើត ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ១៨ ខែ មេសា ឆ្នាំ២០១៩ ស្តីពីការស្នើទៅប្រធានមន្ទីរអប់រំយុវជន និងកីឡារាជធានី ខេត្តនានា សុំជួយសម្រួលដល់ការចុះស្រាវជ្រាវប្រមូលទិន្នន័យ នៅតាមរាជធានី ខេត្តនានា ***(មើលឧបសម្ព័ន្ធទី ១)***។ មូលហេតុនៃការស្នើសុំទៅមន្ទីរអប់រំយុវជន និងកីឡាខេត្តនានា ដោយសារតែសាលាគោលដៅយកមកធ្វើការស្រាវជ្រាវទាំងនេះស្ថិតនៅក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់មន្ទីរអប់រំយុវជន និងកីឡា រាជធានី-ខេត្ត ។ បន្ទាប់ពីទទួលបានការឆ្លើយតបពីមន្ទីរអប់រំយុវជន និងកីឡារាជធានីភ្នំពេញ ខេត្តសៀមរាប បាត់ដំបង ពិសេសខេត្តកំពង់ចាមបានអនុញ្ញាតិតាមរយៈលិខិតឧទ្ទេសនាមលេខ : ៨៧៥/១៩ ឧទន.រប ចុះថ្ងៃ អង្គារ ១០ រោច ខែ ពិសាខ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០១៩ ស្តីពីការសម្រួលដល់ការចុះប្រមូលទិន្នន័យនៅតាមក្រុង ស្រុកគោលដៅ ក្នុងខេត្ត កំពង់ចាមមក អ្នកសិក្សាស្រាវជ្រាវបានរៀបចំផែនការដោយធ្វើការទំនាក់ទំនងទៅសាលាគោលដៅដោយផ្ទាល់ ដើម្បីជួបពិភាក្សាជាមួយនាយកសាលាក្នុងគោលបំណងកំណត់កាលបរិច្ឆេទជួបសិស្សដើម្បីបំពេញកម្រងសំណួរដែលបានត្រៀមទុកជាមុន ធ្វើយ៉ាងណាមិនឱ្យប៉ះពាក់ដល់ការបង្រៀន និងការរៀនរបស់សិស្ស ***(មើលឧបសម្ព័ន្ធទី ២)***។ ដំណើរការទាំងមូលបានពិភាក្សាជាមួយថ្នាក់ដឹកនាំសាលា អំពីគោលបំណង និងផែនការទាំងមូលនៃការសិក្សាស្រាវជ្រាវ ។ ក្រោយពីនាយកសាលាបាន ពិនិត្យលិខិតអនុញ្ញាតពីមន្ទីរអប់រំយុវជន និងកីឡាក្នុងកិច្ចការស្រាវជ្រាវនេះរួចហើយគាត់ក៏បានអនុញ្ញាតឲ្យរៀបចំការប្រមូលទិន្នន័យ ទៅតាមផែនការដែលឯកភាពអ្នកស្រាវជ្រាវ។ ចុងក្រោយអ្នកស្រាវជ្រាវ បានជួបលោកនាយកនាយិកាសាលារៀន និងដើម្បីសុំការអនុញ្ញាតក្នុងការចុះប្រមូលទិន្នន័យព្រមទាំងសម្ភាសលើសំណាកដែលមាននាយក លោកគ្រូ អ្នកគ្រូ និងបុគ្គលិកគាំទ្រនានាក្នុងសាលារៀន ។

## ៣. ៧ ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យដែលទទួលបាន តាមរយៈការបំពេញកម្រងសំណួរ អ្នកស្រាវជ្រាវប្រើ ប្រាស់កម្មវិធី SPSS ដើម្បីបញ្ចូល និងវិភាគទិន្នន័យ និងប្រើកម្មវិធី Ms. Excel ដើម្បីបង្ហាញតារាង និងតារាងក្រាហ្វិក ក្នុងការ

វិភាគបែបបរិមាណវិស័យ ដែលបង្ហាញពីកម្រិតចម្លើយនៃ សកម្មភាពនានា ដែលពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃនៃការអប់រំប្រកបដោយបរិយាបន្នទៅលើកុមារពិការដោយគិតជាចំនួនធម្យម និងភាគរយ ។ ចំណែកសំណួរបើកវិញជាសំណួរបែបគុណវិស័យ យើងខ្ញុំវិភាគដោយប្រើប្រាស់កម្មវិធី Ms. Word ។ ដូច្នេះនៅក្នុងការវិភាគចម្លើយចំពោះរាល់សំណួរទាំងអស់ ត្រូវបានធ្វើការវិភាគ គឺអាស្រ័យទៅលើប្រភេទនៃសំណួរ ថាតើវាជាប្រភេទសំណួរបើក ឬសំណួរបិទ ។

## ៣. ៨ ក្រមសីលធម៌នៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវនេះ ដើម្បីរក្សាបាននូវក្រមសីលធម៌ យើងបានរៀបចំលិខិត ដើម្បីសុំការអនុញ្ញាតពីថ្នាក់ដឹកនាំនៃមន្ទីរអប់រំ យុវជន និងកីឡា ដើម្បីបានផ្តល់ដំណឹងបន្តទៅ ដល់គណៈគ្រប់គ្រងសាលារៀន ។ នៅគ្រប់ការជួបនៃការចុះប្រមូលជាមួយ នាយក គ្រូ យើងតែងតែជម្រាប ពួកគាត់អំពីក្រមសីលធម៌របស់អ្នកសិក្សាស្រាវជ្រាវ ដែលរក្សានូវការសម្ងាត់ នូវរាល់ចម្លើយរបស់នាយក គ្រូ ដែលមិនបានបង្ហាញពីឈ្មោះរបស់អ្នកចូលរួមឆ្លើយពិតប្រាកដនោះទេ ដើម្បីទាមទារឱ្យបានចម្លើយដែលពិតប្រាកដ ។

# ជំពូកទី៤
# លទ្ធផលនៃការស្រាវជ្រាវ

ក្នុងជំពូកនេះ អ្នកសិក្សាស្រាវ នឹងបង្ហាញពីលទ្ធផលស្រាវជ្រាវ ទៅតាមផ្នែកនីមួយនៃកម្រងសំណួរ តាមរយៈតារាង ស្ថិតិ ក្រាហ្វិក និងសេចក្តីសន្និដ្ឋានផ្នែកនីមួយផងដែរ។

## ៤.១ ស្ថានភាពទូទៅ

តារាងទី១៖ សមាសភាពអ្នកចូលរួមផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវ

| តួនាទី | ភ្នំពេញថ្មី | | | ព្រែកអំពៅ | | កំពង់ចាម | | | សៀមរាប | | | បាត់ដំបង | | | | សរុបរួម | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ភេទ | | សរុប | ភេទ | | សរុប | ភេទ | | សរុប | ភេទ | | សរុប | ភេទ | | សរុបរួម | ភេទ | | សរុបរួម |
| | ប្រុស | ស្រី | | ប្រុស | ស្រី | | ប្រុស | ស្រី | | ប្រុស | ស្រី | | ប្រុស | ស្រី | | ប្រុស | ស្រី | |
| គណៈគ្រប់គ្រង | 2 | 0 | 2 | 1 | 1 | 2 | 2 | 0 | 2 | 2 | 0 | 2 | 13 | 10 | 23 | 8 | 2 | 10 |
| គ្រូទទួលបន្ទុកថ្នាក់ | 1 | 10 | 11 | 5 | 6 | 11 | 7 | 7 | 14 | 7 | 7 | 14 | 1 | 1 | 2 | 21 | 38 | 59 |
| គ្រូឯកទេសតាមមុខវិជ្ជា | 4 | 3 | 7 | 1 | 0 | 1 | 3 | 1 | 4 | 3 | 1 | 4 | 4 | 6 | 10 | 16 | 5 | 21 |
| បុគ្គលិក | 0 | 2 | 2 | 0 | 1 | 1 | 0 | 1 | 1 | 0 | 1 | 1 | 2 | 0 | 2 | 1 | 3 | 4 |
| គ្រូជំនួយ និងកិច្ចសន្យា | 1 | 2 | 3 | 1 | 0 | 1 | 1 | 0 | 1 | 1 | 0 | 1 | 1 | 0 | 1 | 2 | 2 | 4 |
| បុគ្គលិកផ្សេងៗ | 0 | 1 | 1 | 0 | | | | | | | | | 1 | 0 | 1 | 3 | 2 | 5 |
| | 8 | 18 | 26 | 8 | 8 | 16 | 13 | 9 | 22 | 13 | 9 | 22 | 9 | 7 | 16 | 51 | 52 | 103 |

តារាងទី២ គ្រូមានជំនាញអប់រំពិសេ និងគ្រូមិនមានការបណ្តុញបណ្តាលជំនាញអប់រំពិសេស

| គ្រូជំនាញអប់រំពិសេស | ការបណ្តុះបណ្តាលជំនាញពិការ | | សរុប |
|---|---|---|---|
| | មិនបាន | បាន | |
| ផ្នែកពិការភ្នែក | ០ | ១២ | ១២ |
| ផ្នែកគ ថ្លង់ | ៥ | ៣២ | ៣៧ |
| មុខវិជ្ជាឯកទេសផ្សេងៗ | ២២ | ៣២ | ៥៤ |
| សរុប | ២៧ | ៧៣ | ១០៣ |

តាមតារាងទី២ បានបង្ហាញថានៅវិទ្យាល័យអប់រំពិសេសទាំង៥ មានគ្រូដែលមានជំនាញអប់រំពិសេសលើពិការភាពចំនួនតិចនៅឡើយប្រមានជា៤៨%។ តែទន្ទឹមនឹងនេះក្តីជាពិសេសគ្រូដែលមានជំនាញមុខវិជ្ជាផ្សេងៗ

ត្រូវបានកំពុងបំប៉ន និងបណ្តុះបណ្តាលលើជំនាញអប់រំពិសេសបន្ថែមទៀតដែរដូចជាអក្សរប្រៃយ៍ និងភាសាសញ្ញា ដើម្បីសម្របសម្រួលកុមារដែលមានពិការភាពអាចបន្តការសិក្សានៅថ្នាក់បន្តបន្ទាប់បាន ហើយមានតែគ្រូចំនួន២៣% ប៉ុណ្ណោះដែលមិនទាន់បានបំណ្តុះបណ្តាលជំនាញអប់រំពិសេស។ ឆ្លើយតបនឹងការរកឃើញនេះ វិទ្យាស្ថានជាតិអប់រំពិសេស បានកំពុងបណ្តុះបណ្តាលគ្រូដែលមានមុខវិជ្ជាឯកទេស មកបណ្តុះបណ្តាលជំនាញអប់រំពិសេសបន្ថែមប្រមាណជា២០នាក់ក្នុងមួយឆ្នាំៗ និងគ្រូដែលកំពុងបម្រើការនៅតាមវិទ្យាល័យអប់រំពិសេសទាំង៥ ក្នុងមួយឆ្នាំ២ដង នូវជំនាញនៃការបង្រៀន និងជំនាញលើពិការភាពបន្ថែមជារៀងរាល់ឆ្នាំ។ នេះបង្ហាញថា ការកសាងសមត្ថភាពគ្រូជំនាញអប់រំពិសេសនៅតាមវិទ្យាល័យអប់រំពិសេសនឹងអាចបំពេញតាមតម្រូវការទាន់ពេលក្នុងពេលឆាប់ៗនេះ។

## ៤. ២ ការផ្តល់ការគាំទ្រសមស្របដល់កុមារពិការ

### ៤. ២. ១ ប្រព័ន្ធកំណត់អត្តសញ្ញាណ និងការបញ្ជូនរកសេវាគាំទ្រផ្សេងៗ

ការផ្តល់ការគាំទ្របានសមស្រប គឺជាការដកនូវឧបសគ្គដែលបានរាំងនានា ដើម្បីអាចអោយកុមារមានពិការភាពអាចមកទទួលសេវាអប់រំ និងបន្តការសិក្សាថ្នាក់បន្តបន្ទាប់បានដែលមានលក្ខណៈបរិយាបន្នបាន។ ក្នុងយន្តការដំបូងបង្អស់នៃ នៃការធ្វើឱ្យសម្រេចបាននូវការអប់រំដល់កុមារ គឺការចុះឈ្មោះចូលរៀន ការកំណត់អត្តសញ្ញញាឱ្យបានត្រឹមត្រូវ និងការបែងចែកកុមារពិការឲ្យបានសមស្របទៅនឹងបរិស្ថានសិក្សា។

តារាងទី៣ ការទទួលចុះឈ្មោះចូលរៀន និងការកំណត់អត្តសញ្ញាណកុមារមានពិការភាព



តាមតារាងដែលបានបង្ហាញនេះ នៅវិទ្យាល័យអប់រំពិសេសបានធ្វើការកំណត់អត្តសញ្ញាកុមារដែលមានពិការភាពដែលបានមកចុះឈ្មោះចូលរៀនដោយសាលាផ្ទាល់ ជាក់ស្តែងសាលាបានអនុវតការកំណត់អត្តសញ្ញាណដល់ទៅ៨១.៦% ។ តាមទិន្នន័យនេះក៏បានបង្ហាញថា កុមារដែលមានពិការភាពនៅកម្ពុជាមិនទាន់បានកំណត់បានត្រឹមត្រូវនៅឡើយទេ មុនពេលដែលពួកគេត្រូវបានបញ្ជូនមកសាលារៀន។ បើតាមការសម្ភាសជាមួយនាយកសាលាអប់រំពិសេបាត់ដំបង កំពង់ចាម និងសៀមរាប បានបញ្ជាក់ថា ទោះជាការកំណត់អត្តសញ្ញាណត្រូវបានធ្វើដោយសាលាក្តី ក៏សាលាត្រូវបញ្ជូលកុមារទៅមន្ទីរសុខាភិបាលដើម្បីសុំលិខិតបញ្ជាក់ពិការភាពរបស់កុមារ និងកម្រិតពិការភាពផងដែរ។ បច្ចុប្បន្នការកំណត់អត្តសញ្ញាត្រូវបានទទួលឱ្យកុមារចុះឈ្មោះចូលរៀនតែកុមារមានពិការភាពតែចំនួនពីរប្រភេទប៉ុណ្ណោះនៅវិទ្យាល័យអប់រំពិសេស គឺកុមារពិការភ្នែក (កម្រិតធ្ងន់ និងទាំងស្រុង) និងកុមារគថ្លង់។ បន្ថែមពីនេះការចុះឈ្មោះចូលរៀនត្រូវបានផ្សព្វផ្សាយជាដោយសាលាប្រចាំ និងមានការចូលរួមគាំទ្រពីលោកគ្រូ អ្នកគ្រូ និងសមគមន៍។




តាមតារាងទី៤ បានបង្ហាញថា មានការផ្តល់ការគាំទ្រឧបករណ៍ជំនួយ និងសេវាគាំទ្រសុខភាពដល់កុមារដែលមានពិការជាញឹកញាប់ចំនួន៤១% និងជាប្រចាំ២៧% ។ តាមការឆ្លុះបញ្ចាំងនេះ កុមារដែលមានពិការភាពកំពុងសិក្សានៅក្នុងសាលាអប់រំពិសេសទាំង៥ កំពុងទទួលការយកចិត្តទុកដាក់យ៉ាងខ្លាំងពីសំណាក់អង្គការ ដៃគូពាក់ព័ន្ធ ហើយនេះជាការកាត់បន្ថយការលំបាករបស់គ្រួសារផ្ទាល់ ទាំងថវិកា និងសេវាព្យាបាលសុខភាពផងដែរ។

លើសពីនេះទៅទៀត សាលាអប់រំពិសេសជា សាលាដែលទទួលសិស្សស្នាក់នៅ និងផ្តល់សេវាគាំទ្រផ្សេងៗបន្ថែមជាច្រើនដូចជាការស្នាក់នៅរយៈពេល១០ខែក្នុង១ឆ្នាំ ជាមួយអាហារ៣ពេលក្នុង១ថ្ងៃ ការដឹកជញ្ជូនដោយរថយន្តសម្រាប់សិស្សនៅជិតសាលា និងសិស្សស្នាក់នៅសាលាដែលធ្វើការប្តូរវេនសិក្សា ជាមួយសាលាចំណេះទូទៅធម្មតា។ ថវិកាដែលដែលផ្តល់ការគាំទ្រទាំងនេះមានចំនួន២០០០០០(ម្ភៃម៉ឺនរៀល)ក្នុង១ខែ

(ផ្តល់១០ខែ ក្នុង១ឆ្នាំ)។ តាមទិន្នន័យការគាំទ្រនេះ បានបង្ហាញថាមានការខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការគាំទ្រ និងសម្របសម្រួលជាច្រើន ដើម្បីធានាថាសិស្សមានពិការភាពទាំងនោះទទួលបានសេវាគាំទ្រពេញលេញ និងកាត់បន្ថយបន្ទុករបស់គ្រួសារដែលមានកុមារមានពិការភាព។

### ៤. ២. ២ ហេដ្ឋារចនា និងបរិស្ថានសាលារៀន

ហេដ្ឋារចនាសម្ព័ន្ធសាលាគឺជាការគាំទ្រសំខាន់ក្នុងការគាំទ្រនូវការអប់រំ។ ហេដ្ឋារចនាសម្ព័ន្ធសាលារៀនមានដូចជា ផ្លូវដើរ ជម្រាល ជណ្ដើ បន្ទប់ទឹក ទីធ្លាសាលាផ្សេងៗក្នុងសាលា។

តារាងទី៥ ការរៀបចំហេដ្ឋារចនា និងបរិស្ថានសាលារៀន




តាមដ្យាក្រាមខាងលើនេះ បានបង្ហាញថាសាលាបានរៀបចំហេដ្ឋារចនាសម្ព័ន្ធ និង បរិស្ថានសាលារៀនល្អស្មើនឹង៨៦% ដោយក្នុងនោះ២៥%បានរៀបចំតាមបទដ្ឋានគំរូដែលបានកំណត់ និង៦១%បន្តទៀតកំពុងបន្តរៀបចំបន្តដើម្បីឱ្យបានត្រឹមត្រូវទៅនឹងគំរូបទដ្ឋាន។ តាមលទ្ធផលនេះឆ្លុះបញ្ចាំងថា បរិស្ថានសាលារៀនមានភាពល្អប្រសើ ដែលឆ្លើយតាមទៅនឹងការគាំទ្រសមស្របការអប់រំបរិយាបន្ន។



តាមតារាងទី៦ បានបង្ហាញថាគ្រូជំនាញអប់រំពិសេសបានធ្វើការប្រឹក្សាយោបល់ជាមួយសិស្សដែលមានពិការភាព ស្មើនឹង៧៣% ។ នេះជាលក្ខណៈពិសេសដែលគ្រូទាំងអស់បានខិតខំប្រឹងប្រែងជួយសិស្សបន្ថែមតាមរយៈការប្រឹក្សាយោបល់បន្ថែមពីការលំបាកនានាដែលសិស្សពិការមាន ពីសុខភាពនិងបម្រែបម្រួលអារម្មណ៍ និងតម្រូវការផ្សេងៗទៀត។ ការធ្វើបែបនេះ បានធ្វើឱ្យការគាំទ្រ និងការអន្តរាគមន៍ជួយកុមារមានពិការភាពទាន់ពេលវេលាជាប្រចាំ។

## ៤. ៣ ការដាក់បញ្ចូលកុមារក្នុងលក្ខណៈបរិស្ថានស្របនឹងអាយុ

ការរៀបចំថ្នាក់រៀនរបស់សិស្សដែលមានពិការភាពត្រូវបានធ្វើឡើងផ្សេងៗ អាស្រ័យ ទៅតាមប្រភេទពិការ កម្រិតពិការ អាយុ និងការឆ្លងវេនសិក្សាជាមួយសិស្សដទៃទៀត នៅសាលារៀនចំណះទូទៅធម្មតា ដោយមានការសម្របសម្រួលពីគ្រូដែលមានជំនាញអប់រំពិសេស។




តាមតារាងទី៧ បានបង្ហាញថាការរៀបចំសិស្សភាគច្រើននៃគឺរៀបចំតាមអាយុ និងប្រភេទពិការភាពស្មើនឹង៤១%។ ការរៀបចំក្រុមសិស្សដែលមានពិការតាមអាយុ និងពិការដូចនេះ បានធ្វើឱ្យមានការងាយស្រួលដល់គ្រូ ក្នុងការបង្រៀនសិស្សពិការមួយប្រភេទដូចគ្នា ពិសេសអាចឱ្យសិស្សអាចធ្វើការងារ ឬពិភាក្សាជាដៃគូបានងាយ។ បន្ថែការមានការរៀបចំតាមការចាំបាច់ជាក់ស្តែងផងដែរ ប្រសិនបើកុមារមានពិការភាពលើសពីមួយប្រភេទ ក្នុងករណីនេះថ្នាក់រៀននោះនឹងត្រូវការគ្រូជំនួយជាពិសេសផងដែរ ដើម្បីអាចជួយសម្រួលគ្រូបន្ទុកថ្នាក់ក្នុងការដឹកនាំរៀន និងបង្រៀន។

## ៤. ៤ ការកំណត់ចំនួនសិស្សនៅក្នុងថ្នាក់រៀន

ការរៀបចំសិស្សមានពិការភាពតាមអាយុ និងប្រភេទពិការរហូតទៅដល់៤១% តែទោះជាយ៉ាងក្តី ការអប់រំកុមារពិការត្រូវបានកំណត់ជាសាលាពិសេស ថ្នាក់បរិយាន្ន និងថ្នាក់សមាហរណកម្ម(ចំនួន៥នាក់យ៉ាងតិច)។ តាមនិយាមថ្នាក់រៀនរបស់វិទ្យាល័យអប់រំពិសេស **សិស្សពិការភ្នែក រឺសិស្សគថ្លង់ រៀននៅវិទ្យាល័យអប់រំពិសេស** ត្រូវបានកំណត់ចំនួនចាប់ពី៣(បី) ដល់៧(ប្រាំពីរ)នាក់ក្នុង១ថ្នាក់ ត្រូវប្រើប្រាស់គ្រូ១នាក់ ក្នុងករណីគ្រូនោះមានពិការភាពត្រូវមានគ្រូដែលធម្មតា១នាក់ទៀត ចំពោះសិស្សពិការភាព១ប្រភេទ ។ **សម្រាប់ថ្នាក់សមាហរណកម្ម សិស្សពិការភ្នែក រឺសិស្សគថ្លង់** សិស្សចាប់ពី៣(បី) ដល់៥(ប្រាំ)នាក់ក្នុង ១ថ្នាក់ សិចំពោះស្សពិការភាព១ប្រភេទ ។

**សម្រាប់សិស្សសតិបញ្ញា រៀននៅសាលាអប់រំពិសេស រឺថ្នាក់សមាហរណកម្ម** ត្រូវបានកំណត់សិស្សចំនួន៧(ប្រាំពីរ)នាក់ ត្រូវប្រើប្រាស់គ្រូចំនួន២(ពីរ)នាក់ ក្នុងករណីសិស្សក្នុងថ្នាក់លើសចំនួន៧(ប្រាំពីរ)នាក់ ត្រូវបំបែកជាពីរថ្នាក់ ប្រើប្រាស់គ្រូចំនួន៤(បួន)នាក់ ចំពោះសិស្សពិការភាព១ប្រភេទ ។

**សម្រាប់សិស្សសតិបញ្ញា រៀននៅសាលាអប់រំពិសេស រឺថ្នាក់សមាហរណកម្ម ហើយមានពិការភាពច្រើនប្រភេទ** ត្រូវបានកំណត់សិស្សចំនួន៣(បី)នាក់ ត្រូវប្រើប្រាស់គ្រូ២នាក់ក្នុង១ថ្នាក់ ។

## ៤.៥ ការធានាថាកុមារពិការបានចូលរួមគ្រប់សកម្មភាព

ការផ្លាស់ប្តូរវិរិយាបទ និងការគាំទ្រក្នុងការចូលរួមគ្រប់សកម្មភាពសិក្សា គឺជាគាំទ្រាការផ្តល់សិទ្ធកុមារពិការ។ ដើម្បីឱ្យការអប់រំកុមារទទួលបានលទ្ធផលល្អ ការធ្វើសកម្មភាពកុមារគឺជាមូលដ្ឋានគ្រឹះ ដែលចូលរួមសម្រេចបានវត្ថុបំណងនៃមេរៀន។ ទោះជាយ៉ាងណាក្តីកុមារពិការក៏ត្រូវការអនុវត្តសកម្មភាពដូចសិស្សទូទៅដែរ ដោយអនុវត្តលើញ្ញាណណាមួយដែលមិនពិការភាព។

### ៤.៥.១ ការបញ្ជូន និងសម្របសម្រួលកុមារ សាលាអប់រំពិសេស និងសាលាទូទៅធម្មតា

ជាទូទៅសិស្សដែលពិការភ្នែកត្រូវបញ្ជូនចូលរៀនឆ្លាស់វេន ជាមួយសិស្សទូទៅនៅថ្នាក់ទី៣ និងសិស្សគ ថ្លង់




តារាងទី៨ ការបញ្ជូនកុមាររៀនឆ្លាស់វេនពីសាលាអប់រំពិសេ ទៅសាលាចំណេះទូទៅធម្មតា

ត្រូវបានបញ្ជូនមួយសិស្សនៅសាលាទូទៅនៅថ្នាក់ទី៥។ ការធ្វើរបៀបនេះ គឺបង្កលទ្ធភាពសិស្សដែលមានពិការភាពអាចរៀននិងចូលរួមនៅជាមួយសិស្សទូទៅបាន។

តាមតារាងទី៨ ស្តីពីការបញ្ជូនសិស្សមានពិការភាពរៀនឆ្លាស់វេនរវាងសាលាអប់រំ ពិសេសនឹងសាលាចំណេះទូទៅ បានបង្ហាញថា៧៦% នៃការចូលរៀនរបស់កុមារគឺស្របគ្នា ទៅនឹងកម្រិតថ្នាក់នៃសាលាអប់រំពិសេស។ តាម លទ្ធផលនេះបង្ហាញថាកុមារពិការអាចមានសមត្ថភាពរៀនទាន់ដូចកុមារទូទៅដែរ។ ប្រសិនបើសិស្សមានការលំបាក សិស្សនឹងស្នើសុំគ្រូជំនួយ និងគ្រូបកប្រែសញ្ញាជួយហេតុសិស្សអាចរៀនជាមួយសិស្សទៅបាន។ សិស្សពិការភ្នែកត្រូវ បញ្ជូនចូលរៀនឆ្លាស់វេនជាមួយសិស្សទូទៅនៅថ្នាក់ទី៣ និងសិស្សគ ថ្លង់ ត្រូវបានបញ្ជូនមួយសិស្សនៅសាលាទូទៅនៅថ្នាក់ទី៥។ ការធ្វើរបៀបនេះ គឺបង្កលទ្ធភាពសិស្សដែលមានពិការភាព អាចរៀននិងចូលរួមនៅជាមួយសិស្សទូទៅបាន។ ដែលឡែកមានប្រមាណជា២១% មានការមិនសមស្របទៅនឹងថ្នាក់អប់រំពិសេស នេះអាចដោយកត្តាសិស្សដែលមានពិការភាពចូលរៀនយឺត និងរៀនយឺតដោយមូលហេតុមានពិការភាពច្រើន ឬកត្តាផ្សេងៗ។

### ៤. ៥. ២ ផែនការអប់រំជាបុគ្គល

ការអប់រំជាបុគ្គលគឺជាតម្រូវការចាំបាច់បំផុតរបស់សិស្សដែលមានពិការភាព។ តាមតារាងទី៨ បង្ហាញនេះពីចំនួនរយៈដែលគ្រូត្រូវគាំទ្រដល់សិស្សដែលមានពិការភាពបន្ថែមលើសពីសិស្សធម្មតា។




តារាងទី៩ ការជួយសិស្សជាការអប់រំបុគ្គលសម្រាប់សិស្សពិការម្នាក់ក្នុងថ្នាក់អប់រំទូទៅ

ខាងលើនេះបានបង្ហាញថាគ្រូសម្រមសម្រួលសិស្សពិការក្នុងថ្នាក់ទូទៅម្នាក់ចាប់ពី៦ទៅ១០នាទីក្នុង១ថ្ងៃ មានចំនួន៣៥% ពី១ទៅ៥នាទីមានចំនួន២៩% និងពី១១ទៅ១៥នាទីមានចំនួន២១%។ តាមលទ្ធផលនេះគឺជាការអនុវត្តសមស្របតាមការកំណត់សូចនាករថ្នាក់អប់រំបរិយាបន្នដែលបានកំណត់ថា នៅក្នុងថ្នាក់រៀនធម្មតាត្រូវមិនពីចំនួន៣នាក់ក្នុងមួយថ្នាក់ឡើយ។

### ៤. ៥. ៣ ឥរិយាបថគាំទ្រក្នុងថ្នាក់រៀន

ក្រោយពីសិស្សមានពិការភាពត្រូវបញ្ជូន ឱ្យទៅសិក្សាមួយពេលជាមួយសិស្សធម្មតាទូទៅ។ ឥរិយាបថនៃការទទួលយកពីលោកគ្រូ អ្នកគ្រូសាលាចំណេះទូទៅ និងសិស្សានុសិស្ស ធម្មតា គឺទាមទារឱ្យមានការសម្របសម្រួល និងទទួលយកនូវកង្វះខាតនៃពិការភាពរបស់សិស្សពិការ។




តាមតារាងទី១០ បង្ហាញថាគ្រូបានអនុវត្តការកាត់បន្ថយការរើសអើងពិការភាព ដល់ទៅ ៥៨.៣% នៃការផ្តល់ឱកាស និងលើកទឹកចិត្ត។ នេះបង្ហាញថា កុមារមានពិការភាពត្រូវបានយកចិត្តទុកដាក់ពីគ្រូសាលាចំណោះទូទៅ ដែលជាវិធីសាស្ត្រមួយ ដើម្បីលុបបំបាត់ការរើសអើង តាមរយៈឱ្យកុមារមានពិការភាពបានចូលរួម និងបញ្ចេញសមត្ថភាពដូចកុមារទូទៅដែរ។ ក្នុងពេលដែលការផ្តល់ជាគំរូស្មើនឹង៣២% ។ ហើយការកំណត់បទបញ្ញាធ្វើអនុវត្តនោះ បានត្រឹមតែ៩.៧%ប៉ុណ្ណោះ។

## ៤.៦ ការសហការរវាងគ្រូបង្រៀន គ្រួសារ និងសហគមន៍

ការនាំយកកុមារដែលមានពិការភាពពីគ្រួសារ មកសាលារៀនគឺជាការដោះនូវឧបសគ្គមួយ ប៉ុន្តែការមិនមានន័យថាកុមារទាំងនេះ ប្រាកដអាចចូលរៀនបាននៅឡើយទេ។ នេះជាការទាមទារមួយដ៏សំខាន់សម្រាប់កិច្ចសហប្រតិបត្តិការរវាងគ្រួសារដែលមានកូនមានពិការភាព លោកគ្រូ អ្នកគ្រូ និងសហគមន៍គាំទ្របន្ថែម។ ការចូលរួមពីមាតាបិតាគឺជាគន្លឹះ ដែលបន្សីគ្នានូវការអនុវត្តការសិក្សា ការរស់នៅពីសាលាពិសេស និងក្រុមគ្រួសាររបស់គេ។ នេការអាចធ្វើឱ្យមាតាបិតា យល់ដឹងបន្ថែមនូវវិធីសាស្ត្រគាំទ្រផ្សេងដែរ។



តាមតារាងទី១១ បានបង្ហាញថាការចូលរួមពិភាក្សា នឹងប្រឹក្សាយោបល់ត្រូវបានធ្វើឡើងលុះត្រាតែមានការចាំបាច់តែប៉ុណ្ណោះ ស្មើនឹង៦៥%។ យ៉ាងណាមិញ ការចូលរួមនេះនៅតែមិនទាន់អនុវត្តបានល្អនៅឡើយទេ ប្រសិនបើមិនមានការកំណត់មួយច្បាស់លាស់នូវការណាត់ជួបតាមផែនការកំណត់របស់សាលានៅឡើយ។ ការមិនបានធ្វើការណាត់ជួបពិភាក្សានេះ មានកត្តាជាច្រើនដូចជាមាតាបិតារបស់ពួកគេជាគ្រួសារក្រីក្រដែលមិនអាចមកទទួលប្រឹក្សាយោបល់ផ្សេងៗបាន។

## ៤. ៧ ការបណ្តុះបណ្តាល និងបំប៉នគ្រូបង្រៀនដែលបង្រៀនកុមារពិការ

តារាង១២ ការបំប៉នសមត្ថភាពគ្រូបង្រៀនកុមារពិការ%




តាមតារាង១២ បានបង្ហាញថាការបំប៉នដល់គ្រូបង្រៀនសិស្សមានពិការភាព ត្រូវបានធ្វើឡើងច្រើនពីថ្នាក់ជាតិ ស្មើនឹង២៧.២ ពីរដងក្នុងមួយឆ្នាំ(ដោយវិទ្យាស្ថានជាតិអប់រំពិសេស និងនាយកដ្ឋានអប់រំពិសេស) និងដៃគូស្មើនឹង៤៣.៧ ពីរដងក្នុងមួយឆ្នាំ(ដោយដៃគូអភិវឌ្ឍ ពិសេសអង្គការគ្រួសារថ្មី) ជាលទ្ធផលនេះបង្ហាញថាគ្រូនៅវិទ្យាល័យ អប់រំពិសេសត្រូវបានបំប៉នសមត្ថភាពជាប្រចាំ។តែទោះជាយ៉ាងនេះក្តី ឃើញថាសមត្ថភាពស្តីពីពិការភាពនៅថ្នាក់ខេត្ត និងស្រុកមិនទាន់អាចបំប៉ន សមត្ថភាពគ្រូទាក់ទងនឹងពិការភាពបាននៅឡើយ។

## ៤.៨ សរុបបញ្ហា

យោងតាមលទ្ធផល នៃការសិក្សាស្រាវជ្រាវ យើងអាចកំណត់នូវចំណុចល្អ ដែលអនុវត្តបានប្រសិទ្ធភាពនៃការអប់រំប្រកបដោយបរិយាបន្ននៅតាមវិទ្យាល័យអប់រំពិសេស៖

-គ្រូទទួលបានវគ្គបំប៉នសមត្ថភាពទាំងវិធីសាស្ត្របង្រៀន និងការយល់ដឹងបច្ចេកទេសស្តីពីពិការភាពជារៀងរាល់ឆ្នាំ(យ៉ាងតិច២ដង ក្នុង១ឆ្នាំ)។

-ការរៀបចំបរិស្ថានសិក្សា និងហេដ្ឋារចនាសម្ព័ន្ធសាលារៀនអនុវត្តបានត្រឹមត្រូវស្របតាមតម្រូវការសិស្សដែលមានពិការភាព(គ ថ្លង់ និងពិការភ្នែក)។

-កម្មវិធីសិក្សាត្រូវបានអនុវត្តតាមក្រសួងអប់រំ យុវជន និងកីឡា ដោយប្រើប្រាស់នូវភាសាសញ្ញាសម្រាប់សិស្សគថ្លង់ និងអក្សរប្រៃយ៍ សម្រាប់សិស្សខ្សោយគំហើញ និងពិការភ្នែក។

-ការកំណត់អត្តសញ្ញាណ និងការគាំទ្រទៅរកសេវាបញ្ជូន ត្រូវបានអនុវត្តជាប្រចាំ ដើម្បីធ្វើអន្តរាគមន៍ទាន់ពេល។

-ការបញ្ជូនកុមារដែលមានពិការភាពពីថ្នាក់អប់រំពិសេសទៅថ្នាក់រៀនធម្មតាត្រូវបានអនុវត្តត្រឹមត្រូវដោយមានការគាំទ្រ និងសម្របសម្រួលជាប្រចាំរវាងគ្រូអប់រំពិសេស និងគ្រូទូទៅ។

-ផែនការអប់រំ ជាបុគ្គលត្រូវបានអនុវត្តជាពិសេសដើម្បីជំរុញការសិក្សារបស់សិស្សម្នាក់ៗបានល្អប្រសើរ។

-ការប្រឹក្សាយោបល់ រវាងគ្រូ គ្រូថែទាំសុខភាព និងសិស្សមានពិការជាប្រចាំតាមការចាំបាច់របស់សិស្សនីមួយៗ។

ប៉ុន្តែក្នុងការអនុវត្តការអប់រំកុមារមានពិការភាពនៅវិទ្យាល័យអប់រំពិសេសក៏មានការប្រឈមផងដែរ ដូចជា៖

-ការចំណាយខ្ពស់សម្រាប់ការគាំទ្រការសិក្សារបស់កុមារមានពិការភាព
(សិស្សពិការ១ =សិស្សទូទៅ ១២២នាក់)។

-សម្ភារៈសិក្សាមានតម្លៃថ្លៃ និងពិបាកផលិតសម្រាប់លោកគ្រូ អ្នកគ្រូដោយមូលហេតុផលិតនៅក្រៅប្រទេស។

-កម្មវិធីសិក្សា មិនទាន់បានសម្របសម្រួល ដោយហេតុថាសិស្សរៀននៅអនុវិទ្យាល័យឡើងទៅ ត្រូវការរៀនច្រើនម៉ោង ។ ដូចនេះការសិក្សាត្រូវយកម៉ោងសាលាចំណោះទូទៅធម្មតាជាគោល និងម៉ោងសាលាពិសេសត្រូវជួយគាំទ្រ និងជំរុញបន្ថែមតាមកម្មវិធីសាលាធម្មតា។

-ធនធានមនុស្សដែលយល់ដឹងពីពិការភាពនៅមានចំនួនតិច (ថ្នាក់កណ្តាល និងសាលា) ត្រូវការផ្សព្វផ្សាយ និងបំប៉នបន្ថែម ដើម្បីអាចលើកផែនការគាំទ្រសាលាពិសេស។

-ការចូលរួមពីសំណាក់មាតាបិតា និងសហគមន៍មានចំនួនតិចតួច (ព្រោះគ្រួសារក្រីក្រ និងខ្វះការយល់ដឹង)។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវនេះ បានធ្វើឡើងនៅតាមវិទ្យាល័យអប់រំពិសេសទាំងប្រាំ នៅក្នុងប្រទេសកម្ពុជា (វិទ្យាល័យអប់រំពិសេសភ្នំពេញថ្មី ច្បារអំពៅ កំពង់ចាម សៀមរាប និងវិទ្យាល័យអប់រំពិសេសបាត់ដំបង)។ ការសិក្សាស្រាវជ្រាវនេះ នឹងផ្តោតទៅលើការអនុវត្តការអប់រំកុមារពិការប្រកបដោយបរិយាបន្ន ដែលផ្អែកតាមសូចនាករសំខាន់ៗចំនួនប្រាំមួយ ដើម្បីរកឱ្យឃើញពីការអនុវត្តល្អ បញ្ហាប្រឈមនានា និងយុទ្ធសាស្ត្រគាំទ្របន្ថែម ដែលអាចយកទៅអនុវត្តការផ្តល់សេវាអប់រំសម្រាប់កុមារពិការនៅសាលា ចំណេះទូទៅឱ្យកាន់តែប្រសើរឡើង។

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ បានបង្ហាញថាការអប់រំប្រកបដោយបរិយាបន្ននៅតាមវិទ្យាល័យអប់រំពិសេសមានលក្ខណៈល្អ ដោយមានការគាំទ្រជាច្រើនទាំងការស្តានីតិសម្បទា ការគាំទ្រសុខភាព ការពិនិត្យតាមដាន និងការអន្តរគមន៍ទាន់ពេល ក្រៅពីនេះមានការយកចិត្តទុកដាក់ជាច្រើនពីសំណាក់ដៃគូអភិវឌ្ឍនានា ដែលធ្វើឱ្យនិន្នាការគាំទ្រការអប់រំកុមារពិការនៅកម្ពុជាកាន់តែប្រសើរឡើង។

ផ្អែកទៅលើលទ្ធផលនៃការសិក្សាស្រាវជ្រាវបានរកឃើញថា ការអនុវត្តការអប់រំជាមួយកុមារមានពិការភាពឃើញថា ៖

១. គ្រូបង្រៀន ត្រូវបានទទួលការបំប៉នទាំង បច្ចេកទេសបង្រៀន និងចំណេះលើបំណិនពិការភាពជារៀងរាល់ឆ្នាំ។ សម្រាប់ការបំប៉នជាប្រចាំឆ្នាំនេះ គឺជាការកសាងធនមនុស្ស ក្នុងការពង្រីកការអប់រំដល់កុមារដែលមានពិការភាពឱ្យបានទូលំទូលាយ និងប្រសើរឡើង។ តែទោះជាយ៉ាងនេះក្តី គ្រូបង្រៀនមុខវិជ្ជាសាស្ត្រ នៅមធ្យមសិក្សានៅតែជាក្តីកង្វល់ ក្នុងការបណ្តុះបណ្តាលមិនទាន់នឹងតម្រូវការគ្រូនៅតាមវិទ្យាល័យអប់រំពិសេសទាំង៥ និងនិនាការណ៍គោលដៅអប់រំ។ ជាការដោះស្រាយនោះ គ្រូបង្រៀនមុខវិជ្ជាសាស្ត្រម្នាក់ៗ ត្រូវបង្រៀនពីថ្នាក់ទី៧ ដល់ទី១២។

២. កម្មវិធីសិក្សាត្រូវបានអនុវត្តស្របតាមកម្មវិធីសិក្សាសាលាចំណេះទូទៅ។ ដោយក្នុងនោះ សិស្សពិការភ្នែកចាប់ពីថ្នាក់ទី៣ និងសិស្សគថ្លង់ចាប់ពីថ្នាក់ទី៥ ត្រូវទៅរៀនឆ្លងវេនបន្ថែមជាមួយសិស្សធម្មតាដែលមានការសម្របសម្រួលពីគ្រូអប់រំពិសេស។ ការធ្វើបែបនេះបានផ្តល់ឱកាសសិស្សដែលមានពិការភាពអាចចូលរស់នៅ សិក្សា និងទំនាក់ទំនងជាមួយសង្គមជាតិទាំងមូលបាន។ ដោយឡែកការអនុវត្តកម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សានៅតែជាបញ្ហាប្រឈមសម្រាប់កុមារដែលមានពិការភាព ដូចជា ចំនួនម៉ោងសិក្សាច្រើន ចំនួនមុខវិជ្ជានិងគ្រូច្រើន និងការគាំទ្រ សម្របសម្រួលពីគ្រូអប់រំពិសេសនៅមានកម្រិតតិចតួច។ ការអនុវត្តកម្មវិធីសិក្សានៅសាលាអប់រំពិសេសបានត្រឹមតែបន្ថែមលើចំណុចខ្វះខាតដែលសិស្សមានពីសាលាធម្មតាតែប៉ុណ្ណោះ។

ម្យ៉ាងវិញទៀតកម្មវិធីសិក្សាមិនទាន់មានភាពបត់បែន និងឆ្លើយតមតាមតម្រូវការនៃប្រភេទពិការនៅឡើយ ទាំងវត្ថុបំណងមេរៀន ការបណ្តុះបំណិន ជំនាញ ជំនាញវិជ្ជជីវៈ និងការសម្របសម្រួលក្នុងការពិនិត្យ

តាមដានសមត្ថភាពសិស្ស។ ក្នុងនោះដោយសិស្សមានពិការភាពត្រូវចូលរួមប្រឡងជាមួយការប្រឡងសិស្សទូទៅធម្មតា តាមពេលវេលាដូចនឹងសិស្សទូទៅដែរ។

៣. ហេដ្ឋារចនាសម្ព័នសាលារៀន ត្រូវបានរៀបចំបានល្អប្រសើ ដែលមានលក្ខណៈពិសេសដែលអាចឱ្យសិស្សពិការភ្នែកអាចប្រើប្រាស់បាន ទោះមិនទាន់បានសមស្របតាមស្តង់ដាដែលបានកំណត់សម្រាប់អ្នកសិក្សាដែលមានពិការភាពនៅឡើយ។ ការគាំទ្រលើការកសាងហេដ្ឋារចនាសម្ព័ន្ធនេះទាមទារនូវការចំណាយថវិកាខ្ពស់ ដែលសាលាអប់រំពិសេសទាំងប្រាំមិនអាចធ្វើបាន។

៤. ការចូលរួមគាំទ្រមាតាបិតា និងសហគមន៍ជួយការសិក្សាសិស្ស មានការគាំទ្រតិចតួចនៅឡើយ ដោយសាលាអប់រំពិសេសទទួលសិស្សពីគោលដៅឆ្ងាយៗពីសាលា ដែលមាតាបិតាភាគច្រើនជាក្រុមគ្រួសារដែលជួបការលំបាក ក្រីក្រ និងខ្វះការយល់ដឹង។ នេះជាបន្ទុកទាំងស្រុងសាលា(ក្រសួង)ក្នុងការស្វែងរកការគាំទ្រផ្សេងៗដែលអាចជួយកុមារឱ្យទាន់ពេល។

៥. សិស្ស និងសេវាជួយសិស្ស ត្រូវបានអនុវត្តយ៉ាងល្អទាំងក្នុងសាលានិងក្រៅសាលា។ ក្រោមកិច្ចសហប្រតិបត្តិការជាមួយអន្តរក្រសួង ដៃគូអភិវឌ្ឍនានា ការផ្តល់ឧបករណ៍ជំនួយ ការរកសេវគាំទ្រ ការស្នាក់នៅហុបចុក និងការដឹកជញ្ជូនត្រូវបានអនុវត្តទាន់ពេលវេលា និងល្អប្រសើ ដែលសាលាទូទៅមិនអាចធ្វើបាន។ ពិសេសទៅទៀត ការសម្របសម្រួលសិស្សរៀនឆ្លងទៅសាលាទៅ ការរៀបចំថ្នាក់ដំបូង(ថ្នាក់ណែនាំពីការរៀបចំខ្លួនឯងដល់សិស្សមានពិការភាព និងផែនការអប់រំជាបុគ្គលជាប្រចាំផងដែរ។

## ៥. ២ សំណូមពរ

ទោះជាយ៉ាងនេះក្តីការអប់រំនៅតាមវិទ្យាល័យអប់រំពិសេសនៅមានការចំណាយ សម្ភារសិក្សាមានតម្លៃខ្ពស់ដែលហេតុផលទាមទារនូវការគាំទ្រ និងការចូលរួមរបស់រាជរដ្ឋាភិបាល ដៃគូរអភិវឌ្ឍ និងសហគមន៍បន្ថែមទៀត។

តាមរយៈការអប់រំនេះ អ្នកស្រាវជ្រាវអាចសន្និដានបានថា ធនធាន និងការអនុវត្តការអប់រំនៅវិទ្យាល័យអប់រំពិសេសទាំង៥ គឺជាគំរូល្អ ដែលអាចយកអនុវត្តតាមសាលាទូទៅក្នុងការប្រែក្លាយការអប់រំប្រែកបដោយបរិយាបន្នសម្រាប់កុមារពិការនៅតាមសាលាសាធារណៈទូទៅបានក្នុងពេលអនាគត៕

អ្នកសិក្សាស្រាវជ្រាវមានសំណូមពរមួយចំនួនដូចជា ៖

- ថ្នាក់ក្រសួងអប់រំ យុវជន និងកីឡា គួរបន្តជ្រើសរើសគ្រូដែលមានឯកទេសស្រាប់ទៅបណ្តុះបណ្តាលដែលឆ្លើយតបនឹងតម្រូវការចាំបាច់តាមវិទ្យាល័យអប់រំពិសស។
- ថ្នាក់ក្រសួងអប់រំ យុវជន និងកីឡាគួរតែមានការផ្សព្វផ្សាយ ទូលំទូលាយ ដល់មន្ទីរអប់រំរាជធានី ខេត្តការិយាល័យអប់រំខណ្ឌ ស្រុក សាលារៀន និងសហគមន៍អំពីការអប់រំកុមារដែលមានពិការភាព បន្ថែម។
- ថ្នាក់ក្រសួងអប់រំ ថ្នាក់មន្ទីរអប់រំ ថ្នាក់ការិយាល័យអប់រំ ត្រូវស្វែងយល់បន្ថែម និងស្វែងរកសាលាគាំទ្រដល់វិទ្យាល័យអប់រំពិសសេទាន់ពេលវេលា។
- នាយកសាលារៀនត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការចុះត្រួតពិនិត្យតាមដានធ្វើអធិការអេចិន្ត្រៃយ៍លើការបង្រៀន និងរៀនរបស់គ្រូសិស្សជាប្រចាំ ដោយមានផែនការច្បាស់លាស់ក្នុង ឆ្នាំសិក្សានីមួយៗ។

- នាយកសាលារៀនខិតខំពង្រឹងកិច្ចសហប្រតិបត្តិការ និងស្វែងរកការគាំទ្រពីសហគមន៍ និងមាតាបិតាសិស្សឱ្យបានបន្ថែម។

**សំណូមពរសាលាចំណោះទូទៅធម្មតា**

-ពង្រឹងសមត្ថភាពលើការយល់ដឹងពីពិការភាព ដូចជាប្រភេទនិងកម្រិតពិការភាព ការកំណត់អត្តសញ្ញាណបឋម និងការរកសេវាគាំទ្រ និងបញ្ជូន។

-បំប៉នពីពិធីសាស្ត្រជួយសិស្សដែលមានពិការភាព តាមរយៈការសម្របសម្រួលពេលវេលា ការវាយតម្លៃសមត្ថភាព និងផែនការអប់រំជាបុគ្គល។

-បង្កើនការគាំទ្រពីសហគមន៍ មាតាបិតា តាមរយៈផែនការឃុំសង្កាត់។

# ឯកសារយោង


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ច្បាប់អប់រំ ឆ្នាំ២០១៧
- ក្រសួងអប់រំ យុវជន និងកីឡា, គោលនយោបាយស្តីពីការអប់រំបរិយាបន្ន, ឆ្នាំ២០១៨
- ក្រសួងអប់រំ យុវជន និងកីឡា, ផែនការសកម្មភាពស្តីពីការអប់រំបរិយាបន្នឆ្នាំ២០១៨-២០២៣, ឆ្នាំ២០១៩
- ក្រសួងអប់រំ យុវជន និងកីឡា, ផែនការយុទ្ធសាស្ត្រស្តីពីការអប់រំ២០១៤-២០១៨, ឆ្នាំ២០១៤
- ក្រសួងអប់រំ យុវជន និងកីឡា, យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា២០១៨-២០២៣, ឆ្នាំ២០១៩
- ក្រសួងអប់រំ យុវជន និងកីឡា, ឯកសារស្តីពីការអប់រំបរិយាបន្ន, ឆ្នាំ២០១៧
- ក្រសួងអប់រំ យុវជន និងកីឡា, ឯកសារលើកកម្ពស់ការបណ្តុះបណ្តាលគ្រូបង្រៀនស្តីពីការអប់រំបរិយាបន្ន, ឆ្នាំ២០១៧
- យុទ្ធសាស្ត្រអ៊ីនឈាន់, ឆ្នាំ២០១២
- ក្រុមប្រឹក្សាសកម្មភាពជនពិការ, ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៤-២០១៨, ឆ្នាំ២០១៤
- ក្រសួងអប់រំ យុវជន និងកីឡា, ការអប់រំបញ្ចូលគ្នា, ឆ្នាំ២០១២
- ក្រសួងអប់រំ យុវជន និងកីឡា, ឯកសារជំនួយសម្រាប់ការអនុវត្តប្រព័ន្ធកំណត់អត្តសញ្ញាណ និងសេវាបញ្ជូនកុមារពិការ, ឆ្នាំ២០១៥
- ក្រសួងអប់រំ យុវជន និងកីឡា, ការអប់រំកុមារពិការសតិបញ្ញា, ឆ្នាំ២០១៨
- ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល, វេទិកាថ្នាក់ជាតិលើកទី៦ ស្តីពីការអប់រំបរិយាបន្ន, ឆ្នាំ២០១៧
- ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល, របាយការណ៍ស្តីពីកម្មវិធីអន្តរាគមន៍របស់អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការក្នុងវិស័យអប់រំ, ឆ្នាំ២០១៧
- ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល, ការវាយតម្លៃអំពីការទទួលបានការអប់រំរបស់កុមារពិការនៅកម្រិតបឋមសិក្សានៅកម្ពុជា, ឆ្នាំ២០១៨
- អង្គការជនពិការអន្តរជាតិ, ពិការភាពរបស់កុមារនៅកម្ពុជា, ២០១២
- អង្គការស៊ីប៊ីអឹម, ភាពងាយស្រួលក្នុងការដាក់បញ្ចូលពិការភាព ,២០១២
- UNICEF, Convention on The Rights of The Child and Its Optional Protocols, 2009
- United Nations, General Comment on Accessibility, 2014
- Ministry of Education Youth and Sport, Cambodia, Understanding Student with Disabilities, 2016
- UNESCO, Teaching Children with Disabilities in Inclusive Settings, 2009
- UNICEF, Children with Disabilities, 2018
- UNICEF-MoEYS, Rolling Work Plan 2019-2020, 2019
- RTI Press, School and Classroom Disabilities Inclusion Guide, 2017

- UNICEF and IIEP UNESCO for reference during the Technical Round Table on Disability Inclusive Education Sector Planning 2018
- UNICEF, Inclusive Early Childhood Development and Disability, 2015
- Surendra Singh. (2017). National Manual on Teaching Children with intellectual Disabilities, Learning Disabilities and Autism Spectrum Disorder, Save the children in Cambodia. 8-19

# ឧបសម្ព័ន្ធទី ១៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំយុវជន និងកីឡា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងអប់រំ យុវជន និងកីឡា

លេខ [illegible] អយក.[illegible]

*ថ្ងៃព្រហស្បតិ៍ [illegible] ខែចេត្រ ឆ្នាំ[illegible] សក ព.ស.២៥៦២*

*រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមេសា ឆ្នាំ២០១៩*

**ជម្រាបមក**

**លោកនាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**

**លោកនាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម**

**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦។

**យោង** ៖ កម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ឆ្នាំសិក្សា២០១៨-២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកនាយក និងលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ចំនួន៤១នាក់ ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្ត ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩។

អាស្រ័យហេតុនេះ សូមលោកនាយក និងលោកប្រធានជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមលោកនាយក និងលោកប្រធានទទួលនូវការរាប់អានពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**ចម្លងជូន៖**

- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- សាលារាជធានី-ខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
  "ដើម្បីជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ : ១១៩ ខជអ.ឥក

## លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ នៅវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងបាត់ដំបង សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្តនានា ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩៖

| ល.រ | គោត្តនាម និងនាម | ភេទ | សាលាគរុកោសល្យ និង រាជធានី-ខេត្ត |
|---|---|---|---|
| ១ | កុយ វ៉ាឡង់ទីណា | ប | ខេត្តកំពង់ធំ |
| ២ | គុជ សំអឿល | ប | ខេត្តស្វាយរៀង |
| ៣ | ឃិន សម្បត្តិ | ប | ខេត្តតាកែវ |
| ៤ | ឯន ណាវី | ប | រាជធានីភ្នំពេញ |
| ៥ | ង៉ែត ភ័រុធ | ប | ខេត្តតាកែវ |
| ៦ | ងួន ផល្លី | ស | ខេត្តបាត់ដំបង |
| ៧ | ឆន ឈាង | ប | សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម |
| ៨ | ឆាយ បូនី | ស | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង |
| ៩ | ជា គត | ប | ខេត្តតាកែវ |
| ១០ | ជា វណ្ណារ៉ា | ប | ខេត្តកំពង់ឆ្នាំង |
| ១១ | ញ៉ែត សំអុល | ប | ខេត្តតាកែវ |
| ១២ | ទឹម ពិន្ទុ | ប | រាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ស្ពឺ កំពង់ធំ ស្ទឹងត្រែង ឧត្តរមានជ័យ និងខេត្តមណ្ឌលគិរី |
| ១៣ | ទុយ សុវណ្ណារិទ្ធ | ប | រាជធានីភ្នំពេញ ខេត្តកំពង់ចាម បាត់ដំបង និងខេត្តសៀមរាប |
| ១៤ | ធាម ហេង | ប | ខេត្តក្រចេះ |
| ១៥ | ប៉ុម សូគ៌ា | ប | ខេត្តកណ្តាល |
| ១៦ | ផុន វណ្ណៈ | ប | ខេត្តកណ្តាល |
| ១៧ | ផូ សុវណ្ណ | ប | រាជធានីភ្នំពេញ |



អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តមភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥-២៣) ២១៥/៨៨៤ គេហទំព័រ www.nie.edu.kh

| | | | |
|---|---|---|---|
| ១៨ | ពុត ពិសី | ប | ខេត្តកំពត |
| ១៩ | ពេជ្រ វង្សី | ស | ខេត្តត្បូងឃ្មុំ |
| ២០ | ភោគ តុលា | ប | ខេត្តស្វាយរៀង |
| ២១ | លី កុសល | ប | ខេត្តកំពង់ចាម |
| ២២ | លីម សេងហួត | ប | ខេត្តបាត់ដំបង |
| ២៣ | លុន ហ៊ាប | ប | ខេត្តកំពង់ចាម |
| ២៤ | លុយ គីមសាន | ប | ខេត្តកណ្ដាល |
| ២៥ | វ៉ា សុភក្តិ | ប | ខេត្តព្រៃវែង |
| ២៦ | សន តារាស្មី | ប | ខេត្តកណ្ដាល |
| ២៧ | ស៊ើយ វង្សស៊ុ | ប | ខេត្តស្ទឹងត្រែង |
| ២៨ | សាម សុនិត | ប | ខេត្តកំពង់ចាម |
| ២៩ | សុទ្ធ ស្រីនាង | ស | ខេត្តកំពង់ស្ពឺ |
| ៣០ | សៀង គីមឈៀន | ប | ខេត្តកណ្ដាល |
| ៣១ | ស្រី មៅ | ប | រាជធានីភ្នំពេញ |
| ៣២ | ហ៊ែល ម៉ូណូ | ប | រាជធានីភ្នំពេញ |
| ៣៣ | ហៃយ ចម្លង | ស | រាជធានីភ្នំពេញ |
| ៣៤ | ឡាយ វីរៈ | ប | ខេត្តឧត្តរមានជ័យ |
| ៣៥ | ឡុង ចំណាន | ប | ខេត្តកំពង់ចាម |
| ៣៦ | អ៊ិន ចាន់ថា | ប | ខេត្តស្វាយរៀង |
| ៣៧ | អ៊ីវ សុធិ | ប | រាជធានីភ្នំពេញ |
| ៣៨ | អ៊ឹម សិរីវឌ្ឍ | ប | ខេត្តតាកែវ |
| ៣៩ | អ៊ុក រិទ្ធិ | ប | ខេត្តសៀមរាប |
| ៤០ | អុន សេងទ្រី | ប | ខេត្តកំពង់ធំ |
| ៤១ | អៀង គីមឈាន | ប | ខេត្តកំពង់ចាម |

ថ្ងៃសុក្រ ១៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័កព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៩

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុខន្ធរា

**កន្លែងទទួល៖**

-សាលារាជធានី-ខេត្តពាក់ព័ន្ធ
-អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
-មន្ទីរ អ.យ.ក រាជធានី-ខេត្តពាក់ព័ន្ធ
"ដើម្បីសហការ"
-សាមីជន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

## ឧបសម្ព័ន្ធទី ២៖ លិខិតអនុញ្ញាតរបស់មន្ទីរអប់រំយុវជន និងកីឡាខេត្តកំពង់ចាម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តកំពង់ចាម**
**មន្ទីរអប់រំ យុវជន និងកីឡា**
លេខ: ...៨៧៥/១៩... ឧទន.រប

# លិខិតឧទ្ទេសនាម

**យោង ៖** លិខិតលេខ១៨៨៥.អយក.វជអ.ចុះថ្ងៃព្រហស្បតិ៍ ១៤ កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦។

និស្សិតថ្នាក់បិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ដែលនឹងប្រព្រឹត្តទៅចាប់ពី ថ្ងៃទី១០ ខែមិថុនា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ នៅ ក្រុងកំពង់ចាម- ស្រុកជើងព្រៃ- ស្រុកចំការលើ- ស្រុកកងមាស- ស្រុកបាធាយ និងស្រុកព្រៃឈរ ៖

| | | |
|---|---|---|
| ១ - លោក | **សាម សុនិត** | និស្សិត |
| ២ - លោក | **លុន ហ៊ាប** | និស្សិត |
| ៣ - លោក | **លី កុសល** | និស្សិត |
| ៤ - លោក | **អៀង គឹមឈាន** | និស្សិត |
| ៥ - លោក | **ឡុង ចំណាន** | និស្សិត |
| ៦ - លោក | **ទុយ សុវណ្ណារិទ្ធ** | និស្សិត |

ថ្ងៃអង្គារ...១០.រោច. ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
កំពង់ចាម ថ្ងៃទី..២៨... ខែឧសភា ឆ្នាំ២០១៩
**ជ. ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត**
**អនុប្រធាន**

**ដួង_សុផាត**

**កន្លែងទទួល ៖**
*-ការិ.អ.យ.ក ក្រុង/ស្រុក កំពង់ចាម,ជើងព្រៃ,ចំការលើ កងមាស,បាធាយ និងព្រៃឈរ*
*"ដើម្បីជូនជ្រាបជាព័ត៌មាន"*
*-គ្រឹះស្ថានសិក្សាពាក់ព័ន្ធ*
*«ដើម្បីសហការ»*
*-សាមីខ្លួន "ដើម្បីអនុវត្ត"*
*- កាលប្បវត្តិឯកសារ ៖ ការិ.រដ្ឋបាល*

លិខិតឧទ្ទេសនាម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំ យុវជន និងកីឡា
ខេត្តកំពង់ចាម
ការិយាល័យរដ្ឋបាល

## កំណត់បង្ហាញលិខិតចូល

<u>អង្គភាពផ្ញើ</u> ៖ ក្រសួង អយក ........ លេខ 1885 អយក.[illegible]
ចុះថ្ងៃទី 18 ខែ 05 ឆ្នាំ ២០19។

<u>ខ្លឹមសារ</u> ៖ [illegible]

| ប្រធាន ឬអនុប្រធានការិយាល័យរដ្ឋបាល | មន្ត្រីរៀប និងឯកសារ |
|---|---|
| គោរពជូនលោកប្រធានមន្ទីរពិនិត្យ និងចាត់ចែងឱ្យការិយាល័យជំនាញក្រោមឱវាទ "<u>ដើម្បីអនុវត្ត</u>" | ជូនលោកប្រធាន ឬអនុប្រធានការិយាល័យរដ្ឋបាល ដើម្បីពិនិត្យ និងផ្តល់យោបល់ជូនលោកប្រធានមន្ទីរ |
| ថ្ងៃទី 28 ខែ 05 ឆ្នាំ ២០19 | ថ្ងៃទី 28 ខែ 05 ឆ្នាំ ២០19 |
| ហត្ថលេខា | ហត្ថលេខា |
| [signature] [illegible] | [signature] [illegible] |

**ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ចាម**

[illegible]

ថ្ងៃទី 28 ខែ 05 ឆ្នាំ ២០19

ហត្ថលេខា

[signature]

**ឧបសម្ព័ន្ធទី ៣៖ កម្រងសំណួរ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**

**កម្រងសំណួរ**
**សម្រាប់លោកគ្រូ អ្នកគ្រូ**

| |
|---|
| កម្រងសំណួរសម្រាប់ស្រាវជ្រាវលើប្រធានបទ<br>ស្ដីពី៖ការអប់រំប្រកបដោយបរិយាបន្នទៅលើកុមារពិការវិទ្យាល័យអប់រំពិសេសទាំង៥ |

**សូមគោរពជូន**

**លោក/លោកស្រី បង្រៀននៅវិទ្យាល័យអប់រំពិសេសទាំង៥**

គោលបំណងនៃការស្រាវជ្រាវនេះ ធ្វើឡើងដើម្បីស្វែងរកការអនុវត្តការអប់រំលើកុមារពិការរបស់វិទ្យាល័យអប់រំពិសេសទាំង៥។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការរបស់**លោក លោកស្រី** ក្នុងការបំពេញកម្រងសំណួរនេះ បើទោះបីជាមានការមមាញឹកក្នុងការងារយ៉ាងណាក៏ដោយ។ កម្រងសំណួរនេះនឹងត្រូវរក្សាជាការសម្ងាត់និងយកមកប្រើសម្រាប់តែការស្រាវជ្រាវនេះតែប៉ុណ្ណោះ។

ផ្នែកទី១ ព័ត៌មានទូទៅ

សាលារៀន

១-ឈ្មោះសាលារៀន ........................................

២.ភេទ ប្រុស ☐ ស្រី ☐

៤.កម្រិតវប្បធម៌ទូទៅ.......................................................................................

៤.កម្រិតបណ្ដុះបណ្ដាលវិជ្ជាជីវៈ........................................ឯកទេស..............................៥.លោកគ្រូអ្នកគ្រូជា......

ក.☐គណៈគ្រប់គ្រង(នាយក/នាយករង)

ខ.☐គ្រូទទួលបន្ទុកថ្នាក់

គ.☐គ្រូមុខវិជ្ជា........................(ឧ. គណិតវិទ្យា...)

ឃ.☐អ្នករដ្ឋបាល បុគ្គលិកការិយាល័យ

ង.☐គ្រូកិច្ចសន្យា

ច.▢គ្រូបង្រៀនស្ម័គ្រចិត្ត/គ្រូបណ្ដោះអាសន្ន/កម្មសិក្សាការី

ឆ.▢ផ្សេងទៀត

៦. មុនទទួលបានតួនាទីបច្ចុប្បន្ន តើលោក លោកស្រីបានឆ្លងកាត់វគ្គអប់រំដែលទាក់ទងនឹងពិការភាពដែរ ឬទេ ?

▢ក.មិនធ្លាប់

▢ខ. ធ្លាប់ (បញ្ជាក់វគ្គបណ្ដុះបណ្ដាលៈ..........................................)

៧.បទពិសោធន៍ ជាគ្រូបង្រៀន

ក.▢តិចជាង៣ឆ្នាំ ខ.▢៣-៥ឆ្នាំ គ. ▢ ៦-១០ឆ្នាំ

ឃ.▢១១-១៥ឆ្នាំ ង▢១៦-២០ឆ្នាំ ច.▢ ច្រើនជាង២០ឆ្នាំ

**ផ្នែកទី២** ការផ្ដល់ការគាំទ្រសមស្របដល់កុមារពិការ

៨.តើលោក លោកស្រីទទួលចុះឈ្មោះសិស្សពិការចូលរៀនដោយបានកំណត់នូវអត្តសញ្ញាណពិការភាពទេ ?

ក.▢មិនកំណត់អត្តសញ្ញាណសិស្សពិការ

ខ.▢បានកំណត់អត្តសញ្ញាណសិស្សពិការ ដោយសាលា

គ.▢បានកំណត់អត្តសញ្ញាណសិស្សពិការដោយតាមអន្តរក្រសួង

៩.តើលោក លោកស្រីបានធ្វើផែនទីខ្នងផ្ទះឬផែនទីសិក្សាសម្រាប់សិស្សពិការដែឬទេ ?

ក.▢មិនបាន

ខ.▢បានធ្វើតាមប្រភេទពិកា

គ. ▢បានធ្វើគ្រប់ប្រភេទពិការ

១០.តើលោក លោកស្រីបានការបញ្ជូនកុមារពិការទៅរកការព្យាបាល ឬអន្តរាគមន៍ផ្សេងដល់ស្ថាប័នពាក់ព័ន្ធ ដែរឬទេ ?

ក.▢មិនបានបញ្ជូន

ខ.▢មិនបានបញ្ជូនតែព្យាបាលនិងអន្តាគមន៍ដោយសាលាដោយខ្លួនឯងផ្ទាល់

គ.▢បានបញ្ជូនរកការព្យាបាល និងអន្តរាគមន៍ទាំងក្នុងសាលា និងស្ថានប័នពាក់ព័ន្ធ

១១.តើមានការផ្ដល់ឧបករណ៍ជំនួយ ដូចជារទេះរុញ ឧបករណ៍ជំនួយការស្ដាប់ ដៃ/ជើងសិប្បនិម្មិត...បានយ៉ាងដូចម្ដេច?

ក.▢គ្មាន ខ.▢ម្ដងម្កាល គ.▢ទៀងទាត់ ឃ.▢អចិន្ត្រៃយ៍

១២.តើលោក លោកស្រីបានរៀបចំផ្លូវដើ ច្រកចូល ជម្រាល ឱ្យមានភាពរាបស្មើដែលងាយស្រួលកុមារពិការអាចដើរបានទេ?

ក.▢គ្មាន ខ.▢មានមិនទាន់សមស្រប គ.▢មានស្របតាមគំរូណែនាំ

១៣.តើលោក លោកស្រីមានរៀបចំបន្ទាប់ទឹក សម្រាប់កុមារពិការដែរឬទេ?

ក.▢គ្មាន ខ.▢មានមិនទាន់បានសមស្រប គ.▢មានស្របតាមគំរូណែនាំ

១៤.តើសាលាបានផ្តល់ការគាំទ្រមធ្យោបាយធ្វើដំណើរដល់កុមារពិការដូចម្តេច?

ក.▢គ្មាន ខ.▢ម៉ូតូ គ.▢រម៉ក(កង់បី) ឃ.▢ឡាន

១៥.តើលោក លោកស្រីបានរៀបចំការផ្តល់អាហារឧបត្ថម្ភដល់កុមារពិការដូចម្តេច?

ក.▢១ថ្ងៃ១ពេល ខ.▢១ថ្ងៃ២ពេល
គ.▢១ថ្ងៃ៣ពេល ឃ▢១ថ្ងៃលើស៣ពេល

១៦.តើសាលាបានរៀបចំកន្លែងស្នាក់នៅកុមារពិការដូចម្តេច?

ក.▢រួមគ្នា ខ.▢ចែកតាមភេទនិងអាយុ ឃ.▢តាមប្រភេទពិការ

១៧.ក្នុងមួយឆ្នាំ តើសិស្សពិការទទួលបានការផ្តល់ការត្រួតពិនិត្យសុខភាពយ៉ាងដូចម្តេច?

ក.▢គ្មាន ខ.▢១ដង គ.▢២ដង
ឃ.▢៣ដង ង.▢លើស៣ដង

១៨. នៅក្នុងថ្នាក់រៀនជាមួយសិស្សទូទៅធម្មតា តើការបញ្ជូនគ្រូជំនួយ គ្រូបកប្រែឱ្យជួយសិស្សពិការដូចម្តេចយ៉ាងដូចម្តេច?

ក.▢គ្មាន ខ.▢តាមការស្នើសុំសិស្សពិការ
គ.▢តាមការស្នើសុំគ្រូសាលាទូទៅ ឃ.▢ត្រូវធ្វើជាប្រចាំថ្ងៃ

១៩.តើការប្រឹក្សាយោបល់របស់សាលាដល់កុមារពិការត្រូវបានអនុវត្តយ៉ាងដូចម្តេច?

ក.▢មិនមាន ខ.▢តាមការស្នើសុំរបស់កុមារ
គ.▢តាមការមើលឃើញបញ្ហាចាំបាច់របស់កុមារ ឃ.▢តាមកាលវិភាគដែលបានកំណត់

២០.តើក្នុងមួយសប្តាហ៍ លោកគ្រូ អ្នកគ្រូចំណាលយពេលប៉ុន្មានម៉ោងសម្រាប់សកម្មភាពខាងក្រោម?

២០.១.រៀបំថ្នាក់ ................ម៉ោង/សប្តាហ៍

២០.២.បង្រៀន ................ម៉ោង/សប្តាហ៍

២០.៣.ជួយសម្របសម្រួល/បកប្រែនៅសាលារដ្ឋទូទៅ................ម៉ោង/សប្តាហ៍

២០.៤.រៀបចំកិច្ចតែងការ និងផលិតសម្ភារឧបទេស ................ម៉ោង/សប្តាហ៍

២០.៥.សកម្មភាពរដ្ឋបាល ....................ម៉ោង/សប្តាហ៍

២០.៦.ជួបជាមួយមាតាបិតាសិស្ស ....................ម៉ោង/សប្តាហ៍

២០.៧.ប្រឹក្សាយោបល់ជាមួយសិស្ស/បំប៉នសិស្សយឺត ....................ម៉ោង/សប្តាហ៍

**ផ្នែកទី៣**.ការដាក់បញ្ចូលកុមារក្នុងលក្ខណៈបរិស្ថានស្របនឹងអាយុ

២១.តើការរៀបចំថ្នាក់រៀនរបស់កុមារពិការត្រូវបានរៀបចំយ៉ាងដូចម្តេច?

ក.▢តាមអាយុសិស្ស ខ.▢តាមប្រភេទពិការ គ.▢តាមអាយុនិងប្រភេទពិការ

ឃ.▢តាមតម្រូវការចាំបាច់

២២.តើសាលារបស់អ្នកបានបញ្ជូនកុមារពិការទៅរៀនថ្នាក់ធម្មតាស្របនឹងថ្នាក់អប់រំពិសេស?

ក.▢មិនបានបញ្ជូនស្របតាម ខ. ▢បានបញ្ជូនស្របសាលាអប់រំពិសេស

គ.▢តាមស្ថានភាពជាក់ស្តែង

២៣.តើលោកអ្នកបានសម្របសម្រួលឱ្យកុមារពិការមានមិត្តភ័ក្តមិនពិការដូចម្តេច?

ក.▢អង្គុយជាដៃគូរជាមួយសិស្សមិនពិការ ខ.▢អង្គុយជាក្រុមសិស្សពិការ

គ.▢មិនបានរៀបចំ

**ផ្នែកទី៤**.ការមិនឱ្យមានកុមារពិការច្រើនពេកនៅក្នុងថ្នាក់រៀនទូទៅ

២៤.តើចំនួនសិស្សពិការសិក្សានៅក្នុងថ្នាក់អប់រំពិសេសគួរមានចំនួនសមស្របប៉ុន្មានក្នុងមួយថ្នាក់?

ក.▢៤ទៅ៨នាក់ ខ.▢៩ទៅ១២នាក់

គ.▢១៣ទៅ១៦នាក់ ឃ.▢១៧ទៅ២០នាក់

២៥.តើចំនួនសិស្សពិការសិក្សានៅក្នុងថ្នាក់ធម្មតាជាមួយសិស្សទូទៅ មានចំនួនសមស្របប៉ុន្មានក្នុងមួយថ្នាក់?

ក.▢១នាក់ ខ.▢២នាក់ គ.▢៣នាក់ ឃ.▢៤នាក់

២៦.ក្នុងមួយម៉ោងសិក្សា(៦០នាទី) អ្នកត្រូវចំណាយពេលដោយផ្ទាល់ជាមួយសិស្សពិការម្នាក់ៗ(ការជួយជាបុគ្គល) រយៈពេលប៉ុន្មាន?

ក.▢៥នាទី ខ.▢១០នាទី គ.▢១៥នាទី
ឃ.▢២០នាទី ង.▢លើស២០នាទី

**ផ្នែកទី៥.**ការធានាថាកុមារពិការបានចូលរួមគ្រប់សកម្មភាព

២៧.តើលោក លោកស្រីបានរៀបចំកិច្ចតែងការបង្រៀនដូចម្តេចចំពោះសិស្សពិការ?

ក.▢រៀបចំធម្មតាដូចកិច្ចតែងការសិស្សទូទៅ
ខ.▢រៀបចំធម្មតាដូចកិច្ចតែងការសិស្សទូទៅតែថែមការជួយកុមារពិការពេលសម្រាក/ចេញលេង
គ.▢រៀបចំដោយទុកពេលវេលាបន្ថែមសម្រាប់សកម្មភាពសិស្សពិការ

២៨. ក្នុងដំណើរការបង្រៀន តើសកម្មភាពរៀនរបស់សិស្សពិការណាមួយដែលមានប្រសិទ្ធភាពបំផុត?

ក.▢ជាបុគ្គល(តែឯង) ខ. ▢ជាគូរ គ.▢ជាក្រុម

២៩.តើការកាត់បន្ថយការរើសអើង និងជំរុញការចូលរួមចំពោះសិស្សពិការដូចម្តេចក្នុងសាលារៀនទូទៅ?

ក.▢ផ្តល់ឱកាសនិងលើកទឹកចិត្តដល់សិស្សពិការជាអាទិភាព
ខ.▢ផ្តល់ជាគំរូអនុវត្តល្អដើម្បីសិស្សទាំងអស់យល់និងទទួលយក
គ.▢កំណត់ជាបទបញ្ញាផ្ទៃក្នុង និងវិន័យក្នុងការគាំទ្រសិស្សពិការ

៣០.តើលោក លោកស្រីដាក់កិច្ចការឱ្យសិស្សធ្វើនៅផ្ទះចំនួនប៉ុន្មានដងក្នុងមួយសប្តាហ៍?

ក.▢១ទៅ២ដង ខ.▢៣ទៅ៥ដង
គ.▢៥ទៅ៦ដង ឃ▢លើសពី៦ដង

៣១.ជាមួយសិស្សពិការ តើលោកគ្រូ អ្នកគ្រូបានផ្តល់ពេល/ម៉ោងបន្ថែម លើសពីសិស្សធម្មតាប៉ុន្មានក្នុងការធ្វើការងារ/លំហាត់/សំណួរក្នុងថ្នាក់របស់ពួកគេ?

ក.▢២ទៅ៥នាទី ខ.▢៦ទៅ១០នាទី គ.▢លើសពី១០នាទី

**ផ្នែកទី៦**.ការសហការរវាងគ្រូបង្រៀន គ្រួសារ និងសហគមន៍

៣២.តើលោក លោកស្រីបានធ្វើការផ្សព្វផ្សាយដើម្បីប្រមូលកុមារពិការចូលរៀនដែរឬទេ?

ក.▢មិនបាន ខ▢ផ្សព្វផ្សាយដើមឆ្នាំសិក្សា

គ.▢ផ្សព្វផ្សាយច្រើនដង ឃ.▢ផ្សព្វផ្សាយជាប្រចាំ

៣៣.តើការតាមដានការវិវត្តន៍និងបម្រែបម្រួលនានារបស់កុមារត្រូវធ្វើឡើងយ៉ាងដូចម្តេច?

ក.▢រាងរាល់ខែ ខ.▢១ដងក្នុងមួយឆ្នាំ

គ.▢២ដងក្នុងមួយឆ្នាំ ឃ.▢តាមការចាំបាច់ជាក់ស្តែង

៣៤.តើការការជួប និងប្រឹក្សាយោបល់ជាមួយគ្រួសាររបស់កុមារពិការ និងការជំរុញលើកទឹកចិត្ត និងការគាំទ្រផ្សេងត្រូវឡើងដូចម្តេច?

ក.▢ម្តងក្នុង១ឆ្នាំ ខ.▢២ដងក្នុងមួយឆ្នាំ

គ. ▢៣ដងក្នុងមួយឆ្នាំ ឃ.▢តាមការចាំបាច់ជាក់ស្តែង

**ផ្នែកទី៧**.ការបណ្តុះបណ្តាល និងបំប៉នគ្រូបង្រៀនដែលបង្រៀនកុមារពិការ

៣៥. តើសាលាមានការកំណត់នូវលក្ខខណ្ឌជ្រើសរើសគ្រូបង្រៀនតាមជំនាញពិការមកបង្រៀនដូចម្តេច?

ក.▢គ្មាន ខ.▢មានតាមជំនាញ(បណ្តុះបណ្តាលក្រោយ) គ.▢មានតាមជំនាញពិការជាមុន

៣៦. តើគ្រូបង្រៀនទទួលបានបំប៉នសមត្ថភាពទាក់ទងនឹងមុខវិជ្ជា ឬបច្ចេកទេសប្រងៀនសិស្សកុមារពិការដូចម្តេចក្នុង ១ឆ្នាំ?

| ទទួលការបំប៉នពី | មិនដែលសោះ | ១ដង | ២ដង | ៣ដង | លើស៣ដង |
|---|---|---|---|---|---|
| ៣៦.១.ថ្នាក់ក្រសួង | | | | | |
| ៣៦.២.ថ្នាក់មន្ទីរ | | | | | |
| ៣៦.៣.ថ្នាក់ស្រុក | | | | | |
| ៣៦.៤.ថ្នាក់សាលារៀន | | | | | |
| ៣៦.៥.ដៃគូអភិវឌ្ឍ/ផ្សេងៗ | | | | | |

**ផ្នែកទី៨**.ការប្រឈមក្នុងការអនុវត្តការអប់រំបរិយាបន្នទៅលើកុមារពិការ

៣៧-តើត្រូវការជំនួយបច្ចេកទេសអ្វីខ្លះបន្ថែមទៀត ដើម្បីឱ្យការអនុវត្តកម្មវិធីការអប់រំបរិយាបន្នទៅលើកុមារពិការមានដំណើរការកាន់តែប្រសើរឡើង ?

..........................................................................................................................................

.......………………………………………………………………………………………………………….

៣៨.តើមានបញ្ហាប្រឈមអ្វីខ្លះក្នុងការអប់រំកុមារពិការ?

..........................................................................................................................................

.......………………………………………………………………………………………………………….

…………………………………………………………………….

ថ្ងៃ.........................ខែ............ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

……… ថ្ងៃទី…………ខែ … ឆ្នាំ២០១៩

អ្នកសម្ភាស

ហត្ថលេខាគ្រូ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**កម្រងសំណួរ**

## សម្រាប់នាយកសាលា

| |
|---|
| កម្រងសំណួរសម្រាប់ស្រាវជ្រាវលើប្រធានបទ<br>ស្តីពីៈការអប់រំប្រែកបដោយបរិយាបន្នទៅលើកុមារពិការនៅកម្ពុជា |

**សូមគោរពជូន**

**លោក/លោកស្រីនាយក/នាយិកាវិទ្យាល័យអប់រំពិសេសទាំង៥**

គោលបំណងនៃការស្រាវជ្រាវនេះ ធ្វើឡើងដើម្បីស្វែងរកការអនុវត្តការអប់រំលើកុមារពិការរបស់វិទ្យាល័យអប់រំពិសេសទាំង៥។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការរបស់លោក លោកស្រី នាយក នាយិកា ក្នុងការបំពេញកម្រងសំណួរនេះ បើទោះបីជាមានការមមាញឹកក្នុងការងារយ៉ាងណាក៏ដោយ។ កម្រងសំណួរនេះនឹងត្រូវរក្សាជាការសម្ងាត់និងយកមកប្រើសម្រាប់តែការស្រាវជ្រាវនេះតែប៉ុណ្ណោះ។

**ផ្នែកទី១ៈ ព័ត៌មានទូទៅ**
**សាលារៀន**

១-ឈ្មោះសាលារៀន ......................................... កូដសាលារៀន ........................... ទីតាំងសាលា ........................... ភូមិ ....................... ឃុំ/សង្កាត់ ........................ ស្រុក/ខណ្ឌ...................................... រាជធានី /ខេត្ត.................................

**គណៈគ្រប់គ្រង**

២-ឈ្មោះ ...................................

៣.ភេទ ប្រុស ☐ ស្រី ☐

៤.តួនាទី............................

៥.កម្រិតវប្បធម៌ទូទៅ.....................................................................................................

៦.កម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈ.........................................ឯកទេស..............................

៧. មុនទទួលបានតួនាទីបច្ចុប្បន្ន តើលោក លោកស្រីបានឆ្លងកាត់វគ្គគ្រប់គ្រងអប់រំដែលទាក់ទងនឹងពិការភាពដែរឬទេ ?

□ក.មិនធ្លាប់ □ខ. ធ្លាប់ (បញ្ជាក់វគ្គបណ្តុះបណ្តាលៈ.................

......................................................................................)

៨.បទពិសោធន៍ក្នុងកំឡុងពេលជាគ្រូបង្រៀន

☐ តិចជាង៣ឆ្នាំ ☐ ៣-៥ឆ្នាំ ៦-១☐ឆ្នាំ ១១-☐៥ឆ្នាំ

☐ ២០ឆ្នាំ ☐ ច្រើនជាង២០ឆ្នាំ

៩.បទពិសោធន៍ទទួលបន្ទុកគណៈគ្រប់គ្រង(ការអប់រំជាមួយកុមារមានពិការភាព)

☐ ១-២ឆ្នាំ ៣☐ឆ្នាំ ៦-១០ឆ្នាំ ☐ ១១-១៥ឆ្នាំ ☐

☐ ២០ឆ្នាំ ☐ ច្រើនជាង២០ឆ្នាំ

## គ្រូបង្រៀន និងបុគ្គលិក

១០-ចំនួនបុគ្គលិកសរុប...........នាក់ ស្រី.........នាក់

១១-ចំនួនបុគ្គលិកពិការសរុបៈ.........នាក់ ស្រីៈ.........នាក់

១២-ចំនួនគ្រូបង្រៀនសរុបៈ............នាក់ ស្រី..........នាក់

១៣-ចំនួនគ្រូមានពិការភាពៈ...........នាក់ ស្រី..........នាក់

## ហេដ្ឋារចនាសម្ព័ន្ធសាលារៀន

១៤-ចំនួនអគារសរុប........

១៥-ចំនួនអគារមានជម្រាល..............

១៦-ចំនួនបន្ទប់សរុប.................

១៧-ចំនួនបន្ទប់រៀនសរុប...............

១៨-ចំនួនបន្ទប់ទឹកសម្រាប់សិស្សពិការសរុប..................

## ស្ថិតិសិស្ស

១៩-ចំនួនសិស្សសរុប...............នាក់ ស្រី...............នាក់

| ពិការកាយសម្បទា | | | | | | | | | | ប.ផ្លូវចិត្ត | | ប.សតិបញ្ញា | | ផ្សេងៗ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ប.ចលនា | | ប.ស្តាប់ | | ប.និយាយ | | ប.មើល | | ប.សរីរាង្គក្នុង | | | | | | | |
| សរ | ស | សរ | ស | សរ | ស | សរ | ស | សរ | ស | សរ | ស | សរ | ស | សរ | ស |
| | | | | | | | | | | | | | | | |

## ផ្នែកទី២ .លក្ខណៈការអប់រំប្រកបដោយបរិយាបន្ន

| **២.១ អភិបាលកិច្ចសាលារៀន** | កម្រិតការអនុវត្ត | | | | | |
|---|---|---|---|---|---|---|
| | ល្អ | ល្អបង្គួរ | មធ្យម | តិចតួច | មិនមាន | មូលហេតុ |
| ២០-សាលាមានការកំណត់ចក្ខុវិស័យ និងបេសកម្មសម្រាប់ការអប់រំកុមារមានពិការភាពច្បាស់លាស់។ | | | | | | |
| ២១-គណៈគ្រប់គ្រងមានការបែងចែកតួនាទីបុគ្គលិក និងគ្រូបង្រៀនតាមប្រភេទពិការ និងកម្រិតថ្នាក់។ | | | | | | |
| ២២-សាលាបានប្រមូលសិស្សមានពិការភាពចូលរៀន ដោយបានកំណត់នូវអត្តសញ្ញាណពិការភាព។ | | | | | | |
| ២៣-គណៈគ្រប់គ្រងបានប្រើប្រាស់ផលធៀបគ្រូ សិស្សក្នុងការបែងចែកគ្រូតាមកម្រិតថ្នាក់ និងមុខវិជ្ជា។ | | | | | | |
| ២៤-សាលាមានការកំណត់នូវលក្ខខណ្ឌជ្រើសរើសគ្រូបង្រៀនតាមជំនាញពិការមកបង្រៀន។ | | | | | | |
| ២៥-សាលាមានការកំណត់នូវលក្ខខណ្ឌជ្រើសរើសគ្រូជំនួយដើម្បីជួយក្នុងការរៀន និងបង្រៀនសិស្សមានពិការភាព។ | | | | | | |
| ២៦-សាលាមានគណៈទ្រទ្រង់សាលាជាពិសេសមានការចូលរួមមាតាបិតាសិស្សមានពិការភាព។ | | | | | | |
| ២៧-សាលាមានក្រុមអ្នកជំនាញឯកទេសមកជួយ ឬបញ្ជូនកុមារទៅរកសេវាគាំទ្រទាន់ពេល។ | | | | | | |
| ២៨-សាលារៀនមានព្រឹត្តិបត្រ ឬប្រព័ន្ធទំនាក់ទំនងជាមួយមាតាបិតាសិស្ស។ | | | | | | |
| ២.២ ការរៀបចំសេវាគាំទ្រ និងហេដ្ឋារចនាសម្ព័នសាលារៀន | | | | | | |
| ២៩-សាលារៀបចំមធ្យោបាយដឹកជញ្ជូនកុមារដែលមានពិការភាពមកសាលារៀន។ | | | | | | |
| ៣០-ផ្លូវចូលសាលាមានភាពរាបស្មើ និងគ្មានឧបសគ្គ។ | | | | | | |
| ៣១-សាលាមានបញ្ជព័ត៌មានដែលងាយស្រួលមាតាបិតា និងសិស្សមានពិការភាពងាយទទួលបាន។ | | | | | | |
| ៣២-អគារសិក្សាមានជម្រាលសម្រាប់កុមារមានពិការឡើងចុះ បាន។ | | | | | | |
| ៣៣-ថ្នាក់រៀនរៀបចំឱ្យអ្នកដែលមានរទេះរុញ ឈើច្រត់ អាចផ្លាស់ទីដោយសុវត្ថិភាព និងអាចទៅកាន់កន្លែងផ្សេងៗនៅក្នុងថ្នាក់រៀន។ | | | | | | |
| ៣៤- កាំជណ្តើរ និងផ្លូវដើរមានលាបពណ៌ ឬគូសសញ្ញាសម្គាល់ដើម្បីឱ្យសិស្សមានពិការភាពដឹងបាន។ | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៣៥-បន្ទប់ទឹករៀបចំឡើងតាមស្តង់ដារសម្រាប់ជនពិការ។ | | | | | | |
| ៣៦-សាលាមានបំពាក់កណ្តឹងរោទ៍ ឬឧបករណ៍បញ្ជូនសំលេងសម្រាប់ជូនដំណឹង។ | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| **២.៣ ការដឹកនាំរៀន និងបង្រៀន** | | | | | | |
| ៣៧-សាលាអនុវត្តកម្មវិធីសិក្សាដូចសាលាចំណេះទូទៅធម្មតាបានទាន់ពេល។ | | | | | | |
| ៣៨-គ្រូរៀបចំសម្ភារបង្រៀនបានត្រឹមត្រូវតាមប្រភេទពិការ។ | | | | | | |
| ៣៩-សាលាមានគ្រូមុខវិជ្ជាតាមមុខវិជ្ជា(មធ្យមសិក្សា) ដែលអាចបង្រៀនសិស្សតាមប្រភេទពិការភាព។ | | | | | | |
| ៤០-គ្រូបានដឹកនាំការបង្រៀន និងរៀនបានត្រឹមត្រូវតាមវិធីសាស្ត្រផ្សេងៗដូចសាលាទូទៅ។ | | | | | | |
| ៤១-សិស្សមានពិការភាពត្រូវបានវាយតម្លៃលទ្ធផលសិក្សាបានត្រឹមត្រូវដូចសិស្សទូទៅ។ | | | | | | |
| ៤២-កម្មវិធីបំណិនជីវិត កីឡា ត្រូវបានបង្រៀនត្រឹមត្រូវដល់សិស្សមានពិការភាព។ | | | | | | |
| **២.៤ ការថែទាំ និងស្នាក់នៅ** | | | | | | |
| ៤៣-សិស្សមានពិការភាពទាំងអស់ត្រូវបានផ្តត់ផ្គង់អាហារហូបចុកជាប្រចាំថ្ងៃនៅសាលា។ | | | | | | |
| ៤៤-សិស្សមានពិការភាពទាំងអស់ស្នាក់នៅសាលា ដោយមានការមើលថែទាំយ៉ាងយកចិត្តទុកដាក់។ | | | | | | |
| ៤៥-សិស្សានុសិស្សទាំងអស់បានទទួលប្រាក់ឧបត្ថម្ភពិសេសជាប្រចាំខែ។ | | | | | | |
| ៤៦-សិស្សានុសិស្សទាំងអស់ត្រូវបានពិនិត្យសុខភាព ។ | | | | | | |

**ផ្នែកទី៣៖មតិយោបល់នាយកសាលា**

៤៧-តើការគ្រប់គ្រង និងការអនុវត្តកម្មវិធីការអប់រំបរិយាបន្នទៅលើកុមារពិការជួបបញ្ហាប្រឈមអ្វីខ្លះ ?

..............................................................................................................................................

..............................................................................................................................................

៤៨-តើត្រូវការជំនួយបច្ចេកទេសអ្វីខ្លះបន្ថែមទៀត ដើម្បីឱ្យការអនុវត្តកម្មវិធីការអប់រំបរិយាបន្នទៅលើកុមារពិការមានដំណើរការកាន់តែប្រសើរឡើង ?

..............................................................................................................................................

..............................................................................................................................................

៤៩-តើសាលារៀនមានផែនការអ្វីខ្លះ ដើម្បីកែលម្អកម្មវិធីអប់រំបរិយាបន្នទៅលើកុមារពិការនាពេលខាងមុខ?

..............................................................................................................................................

..............................................................................................................................................

ថ្ងៃ.........................ខែ...........ឆ្នាំ................ព.ស. ២៥៦...

......... ថ្ងៃទី............ខែ ... ឆ្នាំ...............

អ្នកសម្ភាស

នាយកសាលា

## ឧបសម្ព័ន្ធទី ៤៖ គណៈកម្មការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៤៦២៩ **អយក.** ប្រក

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វីរ៉ៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យូន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារុំម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត ស៊ិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារៈវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៩៦៣១ **អយក.** ១៩

(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម

**យោង** ៖-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការកណ្តាល** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-លោកស្រី ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-លោក ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-លោក ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤-លោក លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោក សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវមកបំពេញភារកិច្ចនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩ និងថ្ងៃបន្តបន្ទាប់ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# ឧបសម្ព័ន្ធទី ៤៖ ប្រកាសផ្ទេរសាលាកុមារពិការភ្នែក និងគថ្លង់ទាំង៥ ពីអង្គការគ្រួសារថ្មី ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

លេខ: ១៣១០ អយក.ប្រក

## ប្រកាស
## ស្ដីពី

**ការផ្ទេរសាលារៀនកុមារ គ ថ្លង់ ច្បារអំពៅ សាលាសម្រាប់កុមារ ពិការភ្នែក និង គ ថ្លង់ ខេត្តកំពង់ចាម សាលាសម្រាប់កុមារ ពិការភ្នែក និង គ ថ្លង់ ខេត្តបាត់ដំបង សាលាសម្រាប់កុមារ ពិការភ្នែក និង គ ថ្លង់ ភ្នំពេញថ្មី និងសាលាសម្រាប់កុមារ គ ថ្លង់ និងពិការភ្នែក ខេត្តសៀមរាប ពីអង្គការគ្រួសារថ្មីឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា**

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា២៨ នៃច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

- បានឃើញអនុក្រឹត្យលេខ ១១៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការបង្កើតវិទ្យាស្ថានជាតិអប់រំពិសេស
- បានឃើញប្រកាសលេខ ៧៩៤ អនក្រ.បក. ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ស្តីពីការបើកសាលារៀនកុមារ គ ថ្លង់ ច្បារអំពៅ
- យោងតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ១ ._**

ត្រូវបានផ្ទេរសាសាលារៀនកុមារ គ ថ្លង់ ច្បារអំពៅ សាលាសម្រាប់កុមារពិការភ្នែក និង គ ថ្លង់ ខេត្តកំពង់ចាម សាលាសម្រាប់កុមារពិការភ្នែក និង គ ថ្លង់ ខេត្តបាត់ដំបង សាលាសម្រាប់កុមារពិការភ្នែក និង គ ថ្លង់ ភ្នំពេញថ្មី និងសាលាសម្រាប់កុមារ គ ថ្លង់ និងពិការភ្នែក ខេត្តសៀមរាប ពីអង្គការគ្រួសារថ្មី ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្របតាមកិច្ចព្រមព្រៀងសហប្រតិបត្តិការចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ រវាងក្រសួងអប់រំ យុវជន និងកីឡាព្រះរាជាណាចក្រកម្ពុជា និងអង្គការគ្រួសារថ្មី។

**ប្រការ២ ._**

សាលារៀននីមួយៗដែលបានផ្ទេរមកក្រសួងអប់រំ យុវជន និងកីឡា មានទីតាំងដូចខាងក្រោម៖

សាលារៀនកុមារ គ ថ្លង់ ច្បារអំពៅ មានទីតាំងនៅក្នុងភូមិឫស្សីស្រស់ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

សាលាសម្រាប់កុមារពិការភ្នែក និង គ ថ្លង់ ខេត្តកំពង់ចាម មានទីតាំងភូមិ៦ សង្កាត់វាលវង់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម។

សាលាសម្រាប់កុមារពិការភ្នែក និង គ ថ្លង់ ខេត្តបាត់ដំបង មានទីតាំងភូមិកម្មករ សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

សាលាសម្រាប់កុមារពិការភ្នែក និង គ ថ្លង់ ភ្នំពេញថ្មី មានទីតាំងដីឡូលេខ ៥៥៩ ផ្លូវហាណូយ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

សាលាសម្រាប់កុមារ គ ថ្លង់ និងពិការភ្នែកខេត្តសៀមរាប មានទីតាំងភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។

**ប្រការ៣ ._**

បុគ្គលិកអប់រំ សិស្សានុសិស្ស ចលនទ្រព្យ និងអចលនទ្រព្យគ្រប់ប្រភេទ ត្រូវផ្ទេរមកឱ្យក្រសួងអប់រំ យុវជន និងកីឡាស្របតាមច្បាប់ និងនីតិវិធីជាធរមាន។ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តសាមីត្រូវទទួលខុសត្រូវលើការងារគ្រប់គ្រងគ្រឹះស្ថានសិក្សាខាងលើនេះស្របស្របតាមច្បាប់ និងនីតិវិធីជាធរមាន។

នាយកដ្ឋានអប់រំពិសេស និងវិទ្យាស្ថានជាតិអប់រំពិសេស ត្រូវជាសេនាធិការឱ្យក្រសួងអប់រំ យុវជន និងកីឡាលើការងារបច្ចេកទេសពាក់ព័ន្ធនឹងគ ថ្លង់ ពិការភ្នែក និងអ្នកសិក្សាពិការផ្សេងទៀត។

**ប្រការ៤ ._**

សាលារៀនកុមារ គ ថ្លង់ ច្បារអំពៅ និងសាលាសម្រាប់កុមារពិការភ្នែក និង គ ថ្លង់នីមួយៗ ត្រូវសហការជាមួយវិទ្យាស្ថានជាតិអប់រំពិសេស និងនាយកដ្ឋានអប់រំពិសេស ដើម្បីរៀបចំសំណុំបែបបទ និងសំណើសុំអាជ្ញាប័ណ្ណពីក្រសួងអប់រំ យុវជន និងកីឡាស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ៥ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៦ ._**

អគ្គនាយកនៃអគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋាន ទ្រព្យសម្បត្តិរដ្ឋ និងប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២ កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០១៧

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រប់អង្គភាពក្រោមឱវាទក្រសួង អ.យ.ក
- ដូចប្រការ៦
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ នា.នីតិកម្ម

បណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

៧/៧